សៀវភៅនៃការចែករំលែក
Sharing Book

# ១១៦ គតិបណ្ឌិតរបស់មាតាបិតា
## សម្រាប់
# ប្រៀនប្រដៅកូន



ជាវិធីនាំបុត្រធីតា
របស់លោកអ្នកទៅកាន់
ភាពជោគជ័យក្នុងជីវិត

www.elibraryofcambodia.org

# អារម្ភកថា

ជាទម្លាប់តាំងពីបុរាណមក ពាក្យប្រៀនប្រដៅរបស់ឪពុកម្តាយ គឺជាសម្បត្តិដ៏មានតម្លៃជាងសម្បត្តិអ្វីទាំងអស់ ហើយអ្នកដែលជាឪពុកម្តាយគ្រប់ៗគ្នាត្រូវបានទុកថា ជាតួនាទីដែលខ្លួនត្រូវតែអប់រំ ប្រដៅណែនាំ ទៅដល់កូនរបស់ខ្លួនឲ្យជ្រះថ្លាទាំងកាយកិរិយា ឬការសម្តី និងចិត្ត ហើយក៏ព្រមទាំងផ្តល់ជាកម្លាំងចិត្តដល់កូននៅពេលដែលជួបបញ្ហា ឬមួយក៏ស្តីបន្ទោសនៅពេលដែលកូនបានធ្វើខុស។

ចំណែកកូនក៏ត្រូវតែមានតួនាទីជាមនុស្សកតញ្ញូដឹងគុណ ចំពោះឪពុកម្តាយដែរដូចគ្នា និងយល់ព្រមប្រតិបត្តិតាមពាក្យទូន្មានប្រៀនប្រដៅរបស់គាត់ ហើយដោយទាល់តែបែបនេះ ទើបគ្រួសារមានភាពកក់ក្តៅទទួលបាននូវសេចក្តីសុខទាំងសងខាង។

ពាក្យសម្តីរបស់ឪពុកម្តាយនោះ គឺមានច្រើនណាស់ ដែលមិនអាចកត់ត្រាបានទាំងអស់ទេ ប៉ុន្តែនៅតែមានការកត់ត្រាខ្លះៗមកបាន ទើបបានកម្លាំងជំរុញចិត្តឲ្យសរសេរសៀវភៅនេះឡើងមកបាន ដូចជាការកត់ត្រាពាក្យសម្តី របស់ឪពុកម្តាយដែលប្រៀនប្រដៅកូនតាំងពីបុរាណមក ដោយពាក្យសម្តីនីមួយៗទាំងនោះ បានប្រមូលពីការបានឮ ស្តាប់ ឃើញ នៅតាមសៀវភៅផ្សេងៗ ហើយក៏យករៀបរៀងចងក្រងដើម្បីឲ្យមានភាពងាយស្រួលឲ្យអានឆាប់យល់។ ទាំងអស់នេះ គឺជាការចង់រក្សាមរតកពាក្យប្រៀនប្រដៅរបស់ឪពុកម្តាយទុក ដើម្បីជាការនាំផ្លូវទៅដល់ឪពុកម្តាយនាសម័យនេះ ឲ្យចេះប្រៀនប្រដៅដល់កូនរបស់ខ្លួនឲ្យចេះធ្វើជាមនុស្សល្អ ពូកែអាចចេះតស៊ូនៅក្នុងជីវិតដោយខ្លួនឯង ក៏ព្រមទាំងបង្រៀនកូនចេះពិចារណានូវពាក្យប្រៀនប្រដៅរបស់ឪពុកម្តាយរបស់ខ្លួនទៀតផង។

www.elibraryofcambodia.org

**១១៦គតិបណ្ឌិតរបស់មាតាបិតាសម្រាប់ប្រៀនប្រដៅកូន**

ប្រែសម្រួល និងពិនិត្យអក្ខរាវិរុទ្ធដោយ **ក្រុមការងារ Sharing Book**

កំណែកុំព្យូទ័រ និងរចនាក្របដោយ **គីង សេងឡុង**

អ្នកទីផ្សារ និងចែកចាយដោយ **ក្រុមការងារ Sharing Book**

រក្សាសិទ្ធិដោយគ្រឹះស្ថានបោះពុម្ពផ្សាយ Sharing Book

បោះពុម្ពឆ្នាំ ២០១៥

Sharingbookcambodia@gmail.com

Facebook.com/Sharingbookpublishing

លេខទូរស័ព្ទទំនាក់ទំនងជាវជុំ **០៨៦ ៧៦៦៦២១**

តម្លៃ ១២០០០ រៀល

លេខ ISBN 978 9924 9015 0 1

www.elibraryofcambodia.org

១៧.មិត្តដែលមានភាពស្មោះត្រង់អស់មួយជីវិត ៣១
១៨.ពូកែប្រឌិតរឿង ៣២
១៩.ការគ្រោះថ្នាក់មកពីការផឹកបារី ៣៣
២០.ចរិយាសង្គម ៣៤
២១.សេចក្តីប្រាថ្នារបស់ឪពុកម្តាយ ៣៥
២២.មន្តស្នេហ៍បបាកនិយម ៣៦
២៣.មនុស្សដែលគ្មានចិត្ត ៣៨
២៤.ទាសកររបស់អារម្មណ៍ ៤០
២៥.ការជ្រើសរើសសេពគប់មនុស្ស ៤១
២៦.ចិញ្ចឹមកូនឲបានល្អ ៤២
២៧.ស្រឡាញ់ច្រើនឲបន្ថយ ស្រឡាញ់តិចឲបន្ថែម ៤៤
២៨.ចិញ្ចឹមកូនឲធំ ៤៦
២៩.ការចេះប្រើមនុស្ស ៤៨
៣០.ការចេះក្រែងចិត្ត ៥០
៣១.ពូកពូកែរកុចរាល ៥២
៣២.ការចេះចាត់ចែងពេលវេលា ៥៣
៣៣.មន្តគាថាបន្ទន់ចិត្ត ៥៥
៣៤.ការដែលប្រកាន់ខ្លួន ៥៧
៣៥.អ្នកដែលស្រឡាញ់យើងស្មោះ ៥៩
៣៦.ឃើតខូចការ យូរខូចកិច្ច ៦១

www.elibraryofcambodia.org

# មាតិកា

## ជំពូកទី១


➤ «គតិបណ្ឌិតរៀនប្រដៅបង្រៀនកូនឲក្លាយជាមនុស្សល្អត្រឹមត្រូវ និងពូកែ»

១.គិតមុននិយាយ ២

២.តម្លៃនៃប្រាក់ ៤

៣.របៀបចងចិត្តមនុស្ស ៦

៤.ការរៀបចំលំដាប់ភាពសំខាន់ៗ ៨

៥.ការយកប្រៀបលើរុកដទៃ ១០

៦.របៀបវិន័យ ១២

៧.ឈ្លូកនៅក្នុងភក់ ១៤

៨.អំពើអបាយមុខ ១៦

៩.មនុស្សដែលគ្មានគោលដៅច្បាស់លាស់ ១៧

១០.ត្រូវចេះមានការសន្សំសំចៃ ១៩

១១.ស្មោះត្រង់ស៊ីមិនរលស់ បោកប្រាស់ស៊ីមិនបានយូរ ២១

១២.វិជ្ជា គឺជាទ្រព្យ ២៣

១៣.ចេះស្រឡាញ់បងស្រឡាញ់ប្អូន ២៥

១៤.គ្រួសារដែលមានភាពកក់ក្តៅ ២៦

១៥.ការចេះរក្សាចិត្តមនុស្ស ២៧

១៦.មានបានហើយ ចូរកុំភ្លេចខ្លួន ២៩


www.elibraryofcambodia.org

៥៧.ទម្លាប់របស់មនុស្សចាស់ ១០១
៥៨.ទុកសម្រាប់ធកូន ១០៣

## ជំពូកទី២

➢ «គតិបណ្ឌិតរៀនប្រដៅបង្រៀនកូនចេះតស៊ូនៅក្នុងជីវិតដោយខ្លួនឯង»

៥៩.ធ្ងន់ ឬក៏ស្រាល ក៏ត្រូវតស៊ូ ១០៥
៦០.បើសិនជាដួលត្រូវតែក្រោកឈរឡើង ១០៧
៦១.កុំរានអាល់រស់តរង្សឹម ១០៩
៦២.ការជួយដល់ខ្លួនឯង ១១១
៦៣.គុណបុណ្យនៃផលវិបាក ១១៣
៦៤.គួតស៊ូដ៏ពិតប្រាកដ ១១៥
៦៥.វិធីសាស្ត្រទប់ស្កាត់ទុក្ខ ១១៧
៦៦.ភាពមានះរឹងរូស ១១៩
៦៧.ប្រភពនៃការបង្កើតកម្លាំងចិត្ត ១២១
៦៨.ការគុំគួនសងសឹក ១២៣
៦៩.ភាពត្រឹមត្រូវ ១២៥
៧០.កុំត្រចៀកស្រាកពេក ១២៧
៧១.ប្រយ័ត្នពាក្យសម្តីផ្អែម ១២៨
៧២.កុំធ្វើជាមនុស្សគ្មានទឹកចិត្ត ១២៩
៧៣.ភាពលោភលន់ ១៣១

www.elibraryofcambodia.org

៣៧.យឺតជាការ យូរជាគុណ ៦៣

៣៨.ចិត្តដែលស្រស់ស្អាត ៦៥

៣៩.ភាពស្មោះត្រង់ ៦៧

៤០.សុខភាពរាងកាយ ៦៩

៤១.សុខភាពផ្លូវចិត្ត ៧១

៤២.បរិស្ថាន ៧៣

៤៣.ភាពកតញ្ញូជាថ្នាំប៉ូវកម្លាំង ៧៥

៤៤.សម្បត្តិរបស់អ្នកថ្លៃថ្នូរ ៧៧

៤៥.យកឈ្នះដោយមានហេតុផល ៧៩

៤៦.មនុស្សត្រចៀកស្រាល ៨១

៤៧.ធ្វើល្ងង់ខ្លះក៏ល្អដែរ ៨៣

៤៨.ស្នេហ៍ស្មោះមួយទល់នឹងមួយ ៨៥

៤៩.កុំយកតម្រាប់តាមអ្នកដទៃ ៨៧

៥០.បាបកម្មមានពិត ៨៩

៥១.ទឹកចិត្តមានតម្លៃជាងទឹកប្រាក់ ៩១

៥២.ថ្នាំប៉ូវបេះដូង ៩៣

៥៣.សង្ឃឹមជានឹងបានឃើញ ៩៤

៥៤.ការចេះសន្តោសប្រណី ៩៥

៥៥.រឿងលាក់នៅក្នុងចិត្ត ៩៧

៥៦.ល្អ អាក្រក់ ៩៩


www.elibraryofcambodia.org

៩៤.ស្គាល់មុខ ប៉ុន្តែមិនស្គាល់ចិត្ត ១៦៦

៩៥.ចិត្តគេ ចិត្តយើង ១៦៨

៩៦.ស្ដាប់ត្រចៀកម្ខាង ទុកម្ខាង ១៧០

៩៧.ភាពសុចរិតទៀងត្រង់ ១៧២

៩៨.គ្រោះភ័យបីយ៉ាង ១៧៤

៩៩.ឃើញគងចក្រថាជាផ្កាឈូក ១៧៦

១០០.ក្ដីស្រមៃ ១៧៨

១០១.មើលខ្លួនឯងចុះ ១៨០

១០២.ប្រាប់ខ្លួនឯងបាន ១៨២

១០៣.ត្រូវចេះសម្របខ្លួន ១៨៤

១០៤.ជ្រើសរើសតែអ្វីល្អ ១៨៦

១០៥.មិត្តស្មោះត្រង់ ១៨៨

១០៦.ចូរប្រើលុយ កុំឲ្យលុយប្រើយើងវិញ ១៩០

១០៧.តាមចិត្តរបស់ខ្លួនឯង ១៩២

១០៨.ភាពប្រកាន់ខ្ជាប់ ១៩៤

១០៩.ការវាយឫក និងការប្រកាន់ខ្លួន ១៩៦

១១០.មានសតិធ្វើកើតមានបញ្ញា ១៩៨

១១១.ការផ្ដល់កម្លាំងចិត្តឲ្យគ្នាទៅវិញទៅមក ២០០

១១២.ភាពកតញ្ញូចំពោះខ្លួនឯង ២០២

១១៣.ការតបស្នងសងគុណ ២០៤


www.elibraryofcambodia.org

៧៤.ការរិះគន់ តិះដៀល ១៣៣
៧៥.ជីវិតមានតម្លៃ ១៣៤
៧៦.មនុស្សមាត់អាក្រក់ ១៣៥
៧៧.មើលមនុស្សនៅក្នុងផ្លូវល្អ ឬផ្លូវអាក្រក់ ១៣៦
៧៨.ឱសថព្យាបាលចិត្ត ១៣៧
៧៩.ឱកាសហាសប្រាក់ ១៣៨
៨០.ភាពទទួលខុសត្រូវ ១៤០
៨១.សតិ ១៤២
៨២.ការឈឺចាប់នៅក្នុងចិត្ត ១៤៣
៨៣.ចិត្តទូលាយ ចិត្តចង្អៀត ១៤៤
៨៤.ការចាញ់អំពើអាក្រក់របស់ខ្លួនឯង ១៤៦
៨៥.ថៃក្បោពាក្យសម្តី ១៤៨
៨៦.សេចក្តីសុខពិត ឬសេចក្តីសុខក្លែងក្លាយ ១៥០
៨៧.ភ្លើងច្រណែន ១៥២
៨៨.សម្លឹងមើលឲបានវែងឆ្ងាយ ១៥៤
៨៩.ការត្រៀមខ្លួនទុករួចជាស្រេច ១៥៦
៩០.ការមានទឹកចិត្ត ១៥៨
៩១.ធ្វើអ្វីដែលមានប្រយោជន៍ ១៦០
៩២.រៀនឲបានច្រើន ប្រសើរជាងទៅសុំ ១៦២
៩៣.ធ្វើល្អបាន ប៉ុន្តែកុំជ្រុលពេក ១៦៤

www.elibraryofcambodia.org

# ជំពូកទី១

## គតិបណ្ឌិតប្រៀនប្រដៅ
## បង្រៀនកូនឲ្យក្លាយជាមនុស្សល្អត្រឹមត្រូវ និងពូកែ

«មនុស្សយើងអាចមានជីវិតដែលល្អ មានភាពរីកចម្រើន និងមានសេចក្ដីសុខបាន លុះត្រាតែបានចំណេះដឹង និងមានសមត្ថភាព ដោយហេតុនោះគឺត្រូវតែធ្វើជាមនុស្សពូកែ ឈ្លាសវៃ និងស្វែងរកចំណេះដឹងបន្ថែមជានិច្ច ប៉ុន្តែទោះបីយ៉ាងនេះ យើងគ្រាន់តែជាមនុស្សពូកែតែម្យ៉ាង មិនទាន់គ្រប់គ្រាន់នោះទេ យើងត្រូវធ្វើជាមនុស្សល្អត្រឹមត្រូវផងដែរ»

www.elibraryofcambodia.org

១១៤.បើសិនជាកាត់ចិត្តបាន មិនក្តៅក្រហាយនោះទេ ២០៦
១១៥.ការបរាជ័យដែលពិតប្រាកដ ២០៨
១១៦.មានការបន្ធូរបន្ថយខ្លះទៅនឹងសប្បាយចិត្ត ២១០

www.elibraryofcambodia.org

បែបនោះ តើមានប៉ុន្មាននាក់ដែលនិយាយល្អនោះ ធ្វើឲ្យកើតបានជាសាមគ្គីភាព និងធ្វើឲ្យគ្រប់គ្នាបានការសប្បាយចិត្ត? ប៉ុន្តែ យើងមិនអាចហាមមិនឲ្យគេនិយាយបានទេ គេនិយាយល្អ ឬមិនល្អយ៉ាងណា និយាយទៅអ្នកណាក៏ជាសិទ្ធិផ្ទាល់របស់គេនោះទេ ហើយបើគេនិយាយ គេត្រូវតែទទួលខុសត្រូវដោយផ្ទាល់ខ្លួន ដោយអ្វីដែលសំខាន់ កូនកុំទៅនិយាយដូចគេទៅបានហើយ។

ពិតជាមានច្បាស់ប៉ុននឹងនិយាយជាមិត្ត បើសិនជានិយាយពីអ្នកដទៃនោះ យើងត្រូវតែមានការប្រយ័ត្នប្រយែង ពីព្រោះយើងមិនស្គាល់គេច្បាស់នោះទេ មិនដឹងពីការក្នុងនឹកគិតរបស់គេច្បាស់ដូចជាខ្លួនរបស់គេនោះទេ ហើយបើយកគិតផ្ទាល់ខ្លួនឯងថា គេជាបែបនោះ គេជាបែបនេះ បើសិនយកទៅនិយាយអាក្រក់ពីគេ មើលទៅមិនមានភាពយុត្តិធម៌នោះទេ។

អ្វីដែលល្អបំផុត គឺកុំនិយាយពីអ្នកដទៃ ដោយមិនបានដឹងរឿងដែលពិតប្រាកដ ទោះបីជាដឹងមែនក៏មិនគួរនិយាយដែរ ហើយបើសិនជាចាំបាច់ត្រូវនិយាយ គួរតែនិយាយយ៉ាងមានសតិ ដោយប្រុងប្រយ័ត្ន ពីព្រោះតែការនិយាយពីអ្នកដទៃនោះ គឺជាការប្រថុយប្រថានចំពោះភាពជាសត្រូវនឹងគ្នា ហើយក៏មានបាបកម្មដែរ។

ប្រយ័ត្នប្រយែងទៅ

គឺល្អណាស់ទៅហើយ !

www.elibraryofcambodia.org

# ១.គិតមុននឹងនិយាយ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មាត់របស់មនុស្សយើងនោះ គឺនាំទាំងទុក្ខ និងទាំងសុខមកឲ្យយើង ហើយមានពាក្យដាស់តឿនជាច្រើនដែលទាក់ទងជាមួយមាត់ ដូចជា មានពាក្យស្លោកមួយថា **«ស្លាប់រស់ក៏ព្រោះតែមាត់»** ពេលដែលកូនទាក់ទងជាមួយនឹងអ្នកណា ធ្វើការនៅទីណាក៏ដោយ របស់ដែលត្រូវប្រយ័ត្នជាងគេបំផុតនោះ គឺមាត់។

ចូរទុកមាត់នៅក្នុងចិត្ត កុំទុកចិត្តនៅក្នុងមាត់ ដោយចង់និយាយអ្វីទុកក្នុងចិត្ត កុំនិយាយគ្រប់យ៉ាងតាមចិត្តដែលគិតអី និយាយច្រើនឱកាសខុសក៏មានកាន់តែច្រើន និយាយតិចខុសកាន់តែតិច ហើយពេលចាំបាច់ដែលត្រូវនិយាយ ក៏និយាយយ៉ាងមានសតិ និយាយល្មមៗ និយាយឲ្យល្អមានសីលធម៌ និងមានប្រយោជន៍ ដោយសម្ដីដែលខ្លាំងពេកនោះ ឮពេកនោះ និងសម្ដីដែលហួសពីការពិត គឺសុទ្ធតែអាចសម្លាប់អ្នកនិយាយដែលល្ងង់ខ្លៅបានទាំងអស់។

មនុស្សនៅក្នុងសម័យយើងនេះ ពូកែនិយាយ និងនិយាយបានច្រើនណាស់ ប៉ុន្តែ កូនពិចារណាមើលឲ្យបានច្បាស់ មនុស្សដែលពូកែនិយាយ

www.elibraryofcambodia.org

បានមួយរឿង ហើយសាកគិតមើលទៅថា តម្លៃសំបុត្រមើលកុនមួយតែ២ពាន់ប៉ុណ្ណោះ ដែលជាលុយពុកម៉ែធ្វើការពិតមួយថ្ងៃទម្រាំតែបានមក តើវាសមនឹងតម្លៃនៃការសប្បាយដែលកូនទទួលបាននោះទេ ឬក៏កូនចង់បានអ្វីម្យ៉ាង ដែលមិត្តភក្តិជាអ្នកមាន គេមាននោះ ប៉ុន្តែត្រូវប្រើលុយរាប់ពាន់ដែលពុកម៉ែខំធ្វើការដល់តែកន្លះខែ បែបនេះ តើត្រូវតែមានដូចគេដែរឬទេ? ។

បើសិនកូនចេះគិតនោះ កូននឹងស្គាល់ពីតម្លៃរបស់ប្រាក់ ហើយកូនក៏អាចគិតពីអនាគតបានវែងឆ្ងាយជាងគេ។

«សូមតែកូនគិតឲ្យបានច្បាស់

មុននឹងពេលចាយវាយ»

www.elibraryofcambodia.org

# ២.តម្លៃនៃមាសប្រាក់

កូនសម្លាញ់របស់ពុកម៉ែអើយ !

មាសប្រាក់ គឺជារបស់ដែលមានតម្លៃ ហើយរកវាបានមកមិនងាយស្រួលនោះទេ ដោយទម្រាំតែបាន ត្រូវប្តូរជាមួយនឹងញើសឈាមជាច្រើន រឿងមួយនេះដែរ កូនប្រហែលជាដឹងហើយ។

ដូច្នេះ លុយកាក់ដែលពុកម៉ែឲកូនចាយវាយនោះ កូនក៏ចាយវាយចុះ ប៉ុន្តែសូមតែប្រយ័ងទេ គឺកូនចាយឲស្គាល់ពីតម្លៃរបស់វា ហើយត្រូវតែដឹងថា វាបកនៅជាមួយនឹងយើងបានយ៉ាងម៉េច ហើយចាយយ៉ាងណា ទើបមានប្រយោជន៍នោះ មិនមែនមានហើយចាយឲអស់នោះទេ។

បើសិនជាចាយវាយដោយមានតម្លៃហើយ ចាំបាច់នោះ កូនក៏ចាយវាយទៅ មិនថាច្រើនប៉ុន្មានទេ ពុកម៉ែនឹងទៅរកឲកូនទាល់តែបាន ទោះបីជាត្រូវធ្វើការធ្ងន់ជាមុនយ៉ាងណាក៏ទ្រាំបានដែរ ដោយបើសិនជាលុយកាក់មួយសេនអាចធ្វើឲកូនមានអនាគតល្អនោះ កូនមិនបាច់ព្រួយបារម្ភចំពោះរឿងនេះទេ។

សូមដល់ប្រាប់តែបន្តិចថា មុនពេលចាយវាយលុយកាក់ សូមឈប់គិតពិចារណាបន្តិចថា សម ឬមិនសម ដែលដូចជា កូនចង់ទៅមើលកុន

www.elibraryofcambodia.org

ស្រលាញ់ដល់គេ យើងមិនលើកតម្កើងសរសើរដល់គេ ហើយថែមទាំងគាប សង្កត់ដល់ចិត្ត ទៅលើកតម្កើងអ្នកដទៃ ឲ្យអ្នកដទៃទៅគាបសង្កត់លើ គេ ហើយពេលដែលជួបប្រទះរឿងបែបនេះ អ្នកណាៗក៏នៅមិនបានយូរ នោះដែរ ដោយសូម្បីតែខ្លួនឯង បើសិនជួបប្រទះ ក៏ភ័យដូចតែគ្នាដែរ។

ពេលដែលដឹងបែបនេះហើយ យើងមិនគួរធ្វើបែបនោះទេ យើងត្រូវតែមើលអ្នកណាដែលមានភាពស្មោះត្រង់ ព្រមទាំងគ្មានល្បិចចំពោះយើង ដោយយើងគួរតែលើកតម្កើងសរសើរដល់គេ ឲ្យកិត្តិយសដល់គេ ឲ្យកម្លាំងចិត្តដល់គេ ជួយជ្រោមជ្រែងឲ្យគេមានភាពរីកចម្រើន និងផ្តល់ឱកាសឲ្យគេធ្វើការតាមសតិកម្លាំងរបស់គេ ហើយដោយយើងមើលពិចារណាហើយប្រាប់ដល់គេ នៅពេលណាដែលគេធ្វើខុស។

តែប៉ុណ្ណឹង ក៏យើងអាចចងសម្ព័ន្ធមិត្ត ចងចិត្តអ្នកដទៃបានហើយ ហើយដោយការចងចិត្តគេដោយវិធីទាំងនេះហើយ គេអាចទៅណារួច។

www.elibraryofcambodia.org

# ៣.របៀបចងចិត្តមនុស្ស

កូនសម្លាញ់របស់ពុកម៉ែអើយ !

នៅក្នុងព្រះពុទ្ធសាសនាបានបង្រៀនអំពីរបៀបចងចិត្តមនុស្ស ដែលមាន៤ប្រការគឺ ការចែករំលែកទុក និយាយល្អចំពោះគ្នា ចេះជួយដល់គ្នា និងធ្វើល្អចំពោះគ្នា ហើយទាំង៤ប្រការនេះ បើសិនអ្នកណាអាចបដិបត្តិតាមបាន ក៏អាចទូសទាញចិត្តអ្នកដទៃបានផងដែរ។

ប៉ុន្តែ ក៏សូមប្រាប់កូនបន្ថែមថា ក្រៅពីគួរមានការបដិបត្តិតាមលំដាប់ហើយនោះ គួរតែចៀសវាងអំពើបីប្រការទៀតគឺ កុំមើលស្រាលអ្នកដទៃ កុំគាបសង្កត់អ្នកដទៃ និងកុំលើកតម្កើងអ្នកដែលអន់ជាងគេ ឲអានមុខមាត់ជាងអ្នកដទៃនោះ ដោយទាំងបីយ៉ាងនេះ បើសិនជាយើងធ្វើចំពោះអ្នកណាគេនឹងមានការទាស់ទាល់អន់ចិត្ត ហើយក៏មានការរាថយ អស់កម្លាំងចិត្តដែលជួយរាល់ការងាររបស់យើង និងពេលដែលទ្រាំមិនបាន គេក៏ចាកចេញពីយើងទៅ ធ្វើឲយើងខាតកម្លាំងទៅដោយឥតប្រយោជន៍ ដែលគេនៅជួយយើងមានភាពស្មោះត្រង់ចំពោះយើង ដោយរៀងបែបនេះ គឺមានភាពទន់ជ្រាយខ្លាំងណាស់ ពីព្រោះគេព្រមលះបង់ជួយដល់យើងគ្រប់បែបយ៉ាង ប៉ុន្តែលទ្ធផលដែលគេបាននោះ គឺយើងបែរទៅជានិយាយសម្ដីមើល

www.elibraryofcambodia.org

ដោយអ្នកណាដែលមានភាពសំខាន់ចំពោះយើងយ៉ាងណា យើងគួរតែទៅទាក់ទង ឬទៅរកគេ គួរតែមើលថែអ្នកមុនក្រោយយ៉ាងណា ត្រូវតែរៀបចំតាមលំដាប់ឲ្យបាន ហើយឲ្យត្រូវ បើសិនមិនអញ្ចឹងទេ អាចនឹងមានភាពស្មុគស្មាញ ឬក៏ល្ហោះល្ហាយក៏ថាបាន។

សូម្បីតែមនុស្សនៅក្នុងគ្រួសាររបស់យើង ដែលដូចជា ឪពុកម្ដាយ កូន ភរិយា ស្វាមី ក្រុមទាំងសាច់ញាតិបងប្អូន មិត្តភក្តិ ក៏យើងត្រូវតែចាត់លំដាប់ភាពសំខាន់ និងចាំបាច់មុនក្រោយដែរ ហើយព្រមទាំងរឿងការពិផ្ចាត់ ការរស់នៅ ភាពកក់ក្ដៅខាងផ្លូវចិត្តរបស់មនុស្សម្នាក់ៗ គួរតែចាត់លំដាប់ភាពសំខាន់ និងទុកដូចគ្នាថា គួរបដិបត្តិចំពោះអ្នកណាមុន និងតិចច្រើនយ៉ាងណានោះ។

បើសិនជារៀបចំចាត់លំដាប់បាន ភាពចលាចល ស្មុគស្មាញ ការរន់ចិត្តអន់ថ្លើម ឬការប្រេះស្រាំនឹងពុំកើតមានឡើងនោះទេ។

«រៀនធ្វើទៅ មិនខាតអ្វីនោះទេ

មានតែធ្វើឲសុខកាយសប្បាយចិត្តថែមទៀត»

www.elibraryofcambodia.org

# ៤.ការរៀបចំលំដាប់ភាពសំខាន់។

កូនសម្លាញ់របស់ពុកម៉ែអើយ!

ពេលខ្លះយើងអាចមិនសប្បាយចិត្តនៅក្នុងការចាត់ចែងការងារ និង កិច្ចការផ្សេងៗរបស់យើង ដែលមើលទៅវាគ្មានរបៀបរៀបរយរញ៉េរញ៉ៃ ឬ អាចនិយាយបានថា ដែលមានភាពស្មុគស្មាញ កើតមកពីការចាត់លំដាប់ ភាពសំខាន់ៗមិនត្រូវ គឺដោយយើងមិនបានរៀបចំផែនការណ៍ ឬគិតទុក ជាមុនថា អ្វីដែលគួរធ្វើមុន និងអ្វីដែលគួរធ្វើក្រោយ ហើយបើសិនជាយើង គិតអ្វីបានមុនក៏ធ្វើ ដោយការងារនោះមិនចាំបាច់ត្រូវធ្វើ ទុកចាំធ្វើនៅពេល ក្រោយក៏បានដែរ នេះជាការផ្ដល់ភាពសំខាន់ចំពោះរបស់នោះដោយមិនចាំ បាច់ និងចំណែករឿងដែលចាំបាច់ត្រូវធ្វើមុន ប៉ុន្តែបែរជាយល់ថា មិន ចាំបាច់ត្រូវធ្វើ ទុកធ្វើនៅពេលក្រោយទៅវិញ វាទើបជាការធ្វើឲមានភាព ស្មុគស្មាញ ខ្លះក៏ធ្វើមិនហើយ ខ្លះក៏ធ្វើទាន់ទៀតផង។

ដូច្នេះ ការរៀបចំលំដាប់ទៅលើរបស់ដែលត្រូវធ្វើ ទើបជារឿងដែល ចាំបាច់បំផុត ហើយអ្វីដែលគួរធ្វើមុន អ្វីដែលគួរធ្វើក្រោយ ត្រូវតែគិតឲ បានច្បាស់ ដោយមិនចំពោះរឿងការងារនោះទេ សូម្បីតែរឿងមនុស្សក៏ចាំ បាច់ផងដែរ ត្រូវតែរៀបចំលំដាប់ភាពសំខាន់របស់មនុស្សម្នាក់ៗទុកដូចគ្នា

www.elibraryofcambodia.org

មនុស្សដែលចូលចិត្តយកប្រៀបលើអ្នកដទៃ ដោយភាពអាត្មានិយមនោះ គឺគេមិនដឹងនោះទេថា គេកំពុងតែបំផ្លាញប្រជាប្រិយភាពនៅក្នុងខ្លួនឯងរបស់គេចុះរលប់បន្តិចម្តងៗ ដោយមិនគួរគិតថា ការយកប្រៀបលើអ្នកដទៃបាននោះ ជាភាពឆ្លាតវៃ ឬជាសមត្ថភាព ប៉ុន្តែតាមការពិតនោះ ជាការបំផ្លាញខ្លួនឯងនោះទេ។

អ្នកខ្លះបាត់បង់ការជឿជាក់ទៅ គ្មានអ្នកណាគេគោរពកោតសរសើរ ឬក៏ស្តាប់តាមនោះទេ ដោយទាំងខ្លួនឯងមានអ្វីៗជាច្រើនលើសដែលល្អកែជាងអ្នកដទៃ ប៉ុន្តែបែរជាបាត់បង់ការជឿជាក់ទៅ ពីព្រោះទាំងនេះដោយសារតែការយកប្រៀបលើអ្នកដទៃនេះហើយ។

www.elibraryofcambodia.org

# ៥.ការយកប្រៀបលើអ្នកដទៃ

កូនសម្លាញ់របស់ពុកម៉ែអើយ !

ការដែលយើងនៅរួមគ្នាជាមួយនឹងអ្នកដទៃនោះ យើងមិនគួរខំប្រឹងយកប្រៀបលើគេនោះទេ ដោយការដែលយកប្រៀបលើអ្នកដទៃ ជាទង្វើមិនល្អនោះទេ ជាឬកពាដែលគួរឲ្យស្អប់ខ្ពើមបំផុត ទោះបីជាទទួលបានផលប្រយោជន៍អ្វីក៏ដោយ ក៏មិនគួរធ្វើនោះដែរ អ្នកដែលចូលចិត្តយកប្រៀបលើអ្នកដទៃនោះ គ្មានអ្នកណាចូលចិត្តនោះទេ សូម្បីតែយើងក៏មិនចូលចិត្តឲ្យអ្នកណាមកយកប្រៀបលើខ្លួនផងដែរ។

បើសិនយើងមិនចូលចិត្ត ក៏មិនគួរធ្វើបែបនេះចំពោះអ្នកណានោះដែរ ហើយក្រៅពីមិនធ្វើហើយថែមទាំងជួយដល់គេទៀតផង បែបនេះ ទើបជាមនុស្សដែលគួរឲ្យគោរព គួរឲ្យរាប់អាន។

មើលទៅចុះ អ្នកដែលចូលចិត្តយកប្រៀបលើមិត្តភ័ក្តិ ចូលចិត្តយកប្រៀបលើបងប្អូនឯងនោះ គួរឲ្យស្អប់ខ្ពើមយ៉ាងណា ហើយមានតែការមានយកចិត្តចំពោះគ្នាតែប៉ុណ្ណោះទេដែលប្រសើរបំផុត ទោះបីជាចាញ់ប្រៀបគេបន្តិចបន្តួចក៏មិនអីដែរ គិតថាយើងធ្វើឲ្យគេមានប្រយោជន៍ទៅចុះ ហើយយើងនឹងមានសេចក្តីសុខ។

www.elibraryofcambodia.org

ប៉ុន្តែកុំខ្វះរបៀបនៅក្នុងខ្លួនឯង ធ្វើអ្វីៗមានរបៀបទៅ រៀបចំរបៀបខ្លួនឯង ក្នុងរឿងពេលវេលាក្នុងការធ្វើការ ក្នុងការធ្វើកិច្ចការប្រចាំថ្ងៃ ដោយទីបំផុត យើងត្រូវចូលក្នុងសង្គម កំមិនចាំបាច់ធ្វើជាមនុស្សមានរបៀបពេកនោះទេ ប៉ុន្តែកុំចេះតែធ្វើអ្វីជ្រុលពេកទៅបានហើយ។

ត្រូវធ្វើជាមនុស្សប្រកាន់ភ្ជាប់នូវរបៀបវិធីយ៉ាងល្អ ប៉ុន្តែបើសិនកូនជាមនុស្សខ្ជិលខ្ជា គ្មានរបៀបវិញនោះ តើកូននឹងក្លាយទៅជាមនុស្សដែលគួរធុញទ្រាន់ ហើយនឹងមានមន្តស្នេហ៍នៅក្នុងកែវភ្នែកអ្នកដទៃបានយ៉ាងដូចម្ដេចទៅ? ។

www.elibraryofcambodia.org

# ៦.របៀបវិន័យ

កូនសម្លាញ់របស់ពុកម៉ែអើយ !

ចូផ្កាដែលអ្នកណាៗឃើញសរសើរថាស្អាតនោះ ស្ថិតនៅលើអ្នកធ្វើតេឭកែតុបតែង ដោយផ្កាប្រភេទខ្លះ ទោះបីជាមើលទៅមិនស្អាត ប៉ុន្តែបើសិនជាអ្នកតុបតែងមានស្នាដៃក៏អាចតុបតែងឲបានស្អាតបានផងដែរ ផ្ទុយទៅវិញ មិនថាផ្កាស្អាតយ៉ាងណានោះទេ ប៉ុន្តែបើសិនជាអ្នកតុបតែងគ្មានថ្វីដៃក៏ធ្វើឲចូផ្កានោះ មើលទៅធម្មតាគ្មានអ្វីគួរឲចាប់អារម្មណ៍សោះ។

របស់របរប្រើប្រាស់នៅក្នុងផ្ទះ អាចធ្វើឲផ្ទះមើលទៅស្អាតបានផងដែរ បើសិនជាម្ចាស់ផ្ទះចេះរៀបចំតុបតែង ដោយមនុស្សយើងក៏ដូចគ្នាផងដែរ ចង់ធ្វើជាមនុស្សល្អគួរឲស្រឡាញ់បាននោះ គឺត្រូវតែស្ថិតនៅលើម្ចាស់ខ្លួនចេះតុបតែងឲមានរបៀប ហើយមិនថាផ្កា របស់របរផ្សេងៗ ឬក៏មនុស្សយើង ដែលមើលទៅស្អាតបែបនោះបាន ក៏ព្រោះតែតុបតែងឲមានរបៀប ដោយការដែលមាន**របៀប** គឺជាឧបករណ៍តុបតែងឲរៀបរយ ស្រស់ស្អាត និងគួរឲចង់គយគន់។

ដូច្នេះហើយ ទើបមនុស្សយើងស្រឡាញ់បែបការមានរបៀបដើម្បីឲគ្រប់យ៉ាងមើលទៅស្រស់ស្អាត កូនអើយ ទោះបីខ្វះខាតអ្វីទៅខ្លះក៏ដោយ

www.elibraryofcambodia.org

មានប្រយោជន៍ដល់យើង យើងមិនគួរស្អប់ខ្ពើមនោះទេ គួរតែរៀនសូត្រ ប្រតិបត្តិដើម្បីបានជាប្រយោជន៍ដល់ខ្លួនយើង។

ដូចពេលដែលយើងត្រូវការផ្កាឈូក យើងត្រូវចូលទៅក្នុងស្រះទឹក ដោយបេះយកផ្កាឈូកហើយក៏យកតែផ្កាឈូកនោះមកទេ ហេតុអ្វីមិនចាំបាច់ត្រូវគិតថាផ្កាឈូកនោះដុះចេញពីក្នុងភក់ ភក់មិនល្អ ប៉ុន្តែបើយើងបានផ្កាឈូកមកហើយក៏ពិតជា សប្បាយរីករាយហើយ ទៅខ្វល់ពីកន្លែងកើតឡើងរបស់ផ្កាឈូកនោះធ្វើអ្វី ផ្កាឈូកដែលដុះចេញពីភក់ជ្រាំស្អុយ ក៏មិនបានធ្វើឲ្យផ្កាឈូកស្អុយទៅតាមភក់នោះដែរ។

ដូចគ្នានឹងដែរ ព្រះធម៌ ចំណេះវិជ្ជា និងពាក្យសម្តីលាតពិរោះទាំងនេះ ទោះបីជាបានមកពីមនុស្សមិនល្អក៏ដោយ អ្នកក្រចំណេះដឹង ឬមនុស្សពិការ បើសិនជាយើងត្រូវការ ហើយគេឲ្យមកយើងបាន ចាត់ទុកថា ចប់គ្នាទៅហើយ ហើយទៅគិតពីរូបរាង ឬការប្រព្រឹត្តិរបស់គេធ្វើអ្វី ដោយគិតដល់តែរបស់ដែលគេបាន ហើយផ្តល់ឲ្យយើងមិនប្រសើរជាងទេឬ ! ។

www.elibraryofcambodia.org

# ៧.ឈ្លូកនៅក្នុងភក់

កូនសម្លាញ់របស់ពុកម៉ែអើយ !

អ្នកណាក៏ដោយ បើសិនជាគេអាចឲចំណេះវិជ្ជាពិសេស ដែលបានដោយពិបាកដល់យើងនោះ យើងគួរតែព្រេកអរទៅរៀនជាមួយគេ មិនគួរទៅគិតពេនៈវង្សត្រកូល រូបរាង និងការប្រព្រឹត្តរបស់គេនោះទេ ហើយទោះបីជាគេមនុស្សក្រីក្រ ពិការយ៉ាងណា ឬមានការប្រព្រឹត្តិមិនល្អយ៉ាងម៉េចក៏ជារឿងរបស់គេទេ ឲតែគេបង្រៀនចំណេះវិជ្ជាពិសេសនោះដល់យើងទៅក៏បានហើយ។

គ្រូបាអាចារ្យដែលបង្រៀនយើងមក មិនមែនអ្នកមាន ឬមានការប្រព្រឹត្តិល្អគ្រប់ៗគ្នានោះទេ ប៉ុន្តែយើងគោរពដល់គាត់ជាគ្រូរបស់យើងបាន ពីព្រោះតែយើងមិនបានចាប់អារម្មណ៍ដល់ការពិត ឬការប្រព្រឹត្តិរបស់គាត់នោះទេ ហើយបើសិនជាយើងទៅស្អប់ខ្ពើមរឿងក្រៅខ្លួនដែលមិនល្អរបស់គាត់នោះ និងមិនព្រមទទួលយកចំណេះដឹងដែលគាត់ឲ យើងក៏មិនបានចំណេះដឹងអ្វីណាស់ណាដែរ។

ដូចគ្នាដែរ ព្រះធម៌ ឬពាក្យសម្តីដែលមានការដាស់តឿនចិត្ត ទោះបីជាចេញពីមាត់អ្នកបួសមានការប្រព្រឹត្តិមិនល្អ ឬអ្នកដែលក្រីក្រ បើសិនជា

www.elibraryofcambodia.org

# ៩.មនុស្សដែលគ្មានគោលដៅច្បាស់លាស់

កូនសម្លាញ់របស់ពុកម៉ែអើយ !

អ្នកដែលជាប្រធានរបស់គេ ឬធំជាងគេនោះ ក្រៅពីមិនគួរជាមនុស្សត្រចៀកស្រាលហើយ ហើយព្រមទាំងមិនគួរធ្វើជាមនុស្សដែលគ្មានគោលដៅច្បាស់លាស់ផងដែរ ដោយយើងគួរតែប្រកាន់ភ្ជាប់ជាមួយនឹងគោលជំហរ និងរក្សាគោលជំហរនេះបានស្ថិតស្ថេរ ហើយគោលជំហរដែលថានោះ គឺជាព្រះធម៌២ប្រការ **គុណធម៌** និង **យុត្តិធម៌**។

គុណធម៌ គឺជាគ្រឹះនៃភាពត្រឹមត្រូវ និងយុត្តិធម៌ គឺជាគ្រឹះនៃភាពទៀងត្រង់ ដោយអ្នកធំត្រូវតែប្រកាន់ភ្ជាប់នូវគោលការណ៍ពីរនេះទុក គឺមានគុណធម៌ យកភាពត្រឹមត្រូវជាគោល មិនមែនយកការពេញចិត្តដោយធ្វើអ្វីតាមចិត្តជាការសំខាន់នោះទេ ហើយនឹងមានយុត្តិធម៌ យកភាពត្រឹមត្រូវជាគោល មិនមានភាពលំអៀងទៅខាងអ្នកដែលមានអំណាចនោះទេ។

អ្នកធំដែលមិនគោរពចំពោះគោលការណ៍ទាំង២យ៉ាងនេះ អាចចាត់ទុកបានថា ជាមនុស្សដែលគ្មានគោលដៅច្បាស់លាស់ ហើយតែងតែកាន់អំណាចជាធម៌ មិនមែនកាន់ធម៌ជាអំណាចនោះទេ ដោយបើសិនជាថ្នាក់លើគ្មានគោលដៅច្បាស់លាស់អាចទទួលបានគោរព ថាតើនឹងទទួលបាន

www.elibraryofcambodia.org

# ៨.អំពើអបាយមុខ

កូនសម្លាញ់របស់ពុកម៉ែអើយ !

អំពើអបាយមុខផ្សេងៗ ដូចជា ស្រា ស្រី ល្បែង រួមទាំងបារី និងគ្រឿងញៀនផងដែរ ដោយគ្រប់គ្នាសុទ្ធតែដឹងថា ជារបស់មិនល្អ ជាអ្នកដែលបំផ្លាញលុយកាក់ សុខភាពរាងកាយ ហើយនឹងបង្កផលវិបាកដល់អ្នកជុំវិញខ្លួនជាច្រើន ព្រមទាំងដឹងហើយ ក៏នៅតែក្លាយជាទាសកររបស់វាទៀត ដោយមានហេតុផលផ្សេងៗដែលយកមកអាង សុទ្ធតែប្រាប់ថាជាការចាំបាច់ទាំងអស់។

ខ្លួនកូនសាកគិតពិចារណាមើលឲ្យច្បាស់បន្តិចទៅថា របស់ទាំងនោះមានដែលឲ្យអ្វីល្អៗដល់អ្នកដែលញៀនដែរឬទេ មានឲ្យផលល្អស្ថិតស្ថេរទៅដល់អ្នកណាម្នាក់ទេ មានដែលធ្វើឲ្យល្អ ឬធ្វើឲ្យយើងមានមុខមាត់ដែរឬទេ? ដោយឃើញថាមានតែបំផ្លាញដល់មនុស្ស ធ្វើឲ្យមនុស្សអាប់ឱន ធ្វើឲ្យខាតបង់ប្រយោជន៍ដោយគ្មានមូលហេតុ ធ្វើឲ្យខាតបង់ពេលវេលា និងព្រមទាំងខូចសុខភាពគ្រប់យ៉ាង។

បែបនេះ ចង់សួរទៅកូនថា បើសិនជាយើងទៅធ្វើជាទាសកររបស់វា តើវាសមរម្យ ឬក៏មិនសមរម្យ ពិចារណាមើលឲ្យបានច្បាស់ទៅ។

www.elibraryofcambodia.org

# ១០.ត្រូវចេះមានការសន្សំសំចៃ

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលដែលយើងតស៊ូធ្វើការទទួលបានប្រាក់ ឬក៏មានទ្រព្យសម្បត្តិមកហើយ មិនអាចធ្វើឲ្យយើងសាងអនាគតបានភ្លាមៗនោះទេ ពីព្រោះតែលុយកាក់ដែលបានមកនោះ មិនមែនបានមកម្ដងច្រើនដល់ថ្នាក់អាចសាងអនាគតបាននោះទេ ប៉ុន្តែការចូលមកបន្តិចម្ដងៗ ពេលដែលបានមកដូចយ៉ាងនេះហើយ ហើយអ្វីដែលសំខាន់នោះ បើមិនជាបានមកហើយមិនចេះទុកដាក់ចេះប្រើ មិនចេះរក្សាមិនចេះសន្សំទៀតនោះ វាក៏នឹងបានហើយក៏អស់ទៅវិញ។

ការសន្សំដែលបានដើមពីការរក្សាទុកនោះ គឺសំខាន់ណាស់ ដោយបានលុយកាក់មកហើយ ត្រូវចេះចែកជាចំណែកៗទុកចាយវាខ្លះ សន្សំទុកខ្លះ តិចក្តី ឬច្រើនក្តី ក៏រក្សាទុកទៅ មិនមែនបានមកហើយ គិតតែដើរចាយវាឲ្យអស់ពីដៃ ដោយអស់ហើយ ក៏ទៅរកមកថ្មីទៀត។

អ្នកដែលធ្វើបែបនេះគេហៅថា **អ្នករកស៊ី** ចំណែកអ្នកសន្សំហៅថា **អ្នករកទុក** ហើយការដែលសន្សំទុកបែបនេះ វាកាន់តែច្រើនកើនឡើងៗ ដល់ថ្នាក់ក្លាយជាទ្រព្យសម្បត្តិច្រើនអាចនឹងធ្វើឲ្យយើងសាងអនាគតបាន។

www.elibraryofcambodia.org

ការស្មោះត្រង់ពីអ្នកតូចតាចបានយ៉ាងម៉េចទៅ គួរឲ្យគោរព គួរឲ្យខ្លាចបានយ៉ាងម៉េច ចូរកូនគិតមើលឲ្យបានច្បាស់ ដូចជាពាក្យចាស់បានពោលថា ស្លាប់នៅហ្នឹងកន្លែង ប្រសើរជាងគ្មានកន្លែងស្លាប់។

## អភ័យទោសឲគេបាន អភ័យទោសទៅ !

កូនសម្លាញ់អើយ ! អ្នកផ្សេងៗខ្លះធ្វើមិនបានល្អ ខ្លះធ្វើខុសឆ្គង ខ្លះធ្វើមិនត្រូវចិត្តរបស់យើង ខ្លះប៉ះពាល់ដល់យើង បើសិនជាអាចអត់ទោសឲបាន ក៏អត់ទោសឲគេចុះ កុំទៅប្រកាន់ខឹងនឹងគេ ឬទៅថាឲគេនោះរឺនៅស្ងៀមទៅ ដោយធ្វើជាអ្នកដែលមិនដឹងមិនឮខ្លះក៏បានដែរ កុំទៅយកមកទុកនៅក្នុងចិត្តធ្វើអ្វី។

ពេលដែលអត់ទោសឲគេហើយនោះ អ្នកដែលសប្បាយចិត្ត គឺខ្លួនយើងនេះឯង ហើយការចងកំហឹងទុក ដូចជាទុកភ្លើងនៅក្នុងចិត្តដែលត្រូវគិតចងគំនុំរហូតទៅនោះ គ្មានអ្វីដែលល្អនោះទេ។

www.elibraryofcambodia.org

# ១១.ស្មោះត្រង់ស៊ីមិនអស់ បោកប្រាស់ស៊ីមិនបានយូរ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានពាក្យចាស់បុរាណបានពោលថា **ស្មោះត្រង់ស៊ីមិនអស់ បោកប្រាស់ស៊ីមិនបានយូរ** កូនប្រហែលជាធ្លាប់បានឮហើយ ដោយពាក្យនេះបានប្រាប់យើងបានដឹងថា ការស្មោះត្រង់នោះគ្មានថ្ងៃស៊ីអស់នោះទេ វាប្រសើរជាងមាសប្រាក់ មាសប្រាក់ស៊ីផង ចាយផង តែងតែអស់នោះទេ ប៉ុន្តែភាពស្មោះត្រង់ស៊ីគ្មានថ្ងៃអស់នោះទេ ទោះបីគ្មានប្រាក់ក៏អាចប្រើភាពស្មោះត្រង់ទៅខ្ចីគេបានផងដែរ ដោយអ្នកដែលឲ្យខ្ចីគេក៏ពេញចិត្តឲ្យ ពីព្រោះតែយើងស្មោះត្រង់ចំពោះគេ មិនគិតបោកប្រាស់គេ ប៉ុន្តែបើសិនជាយើងមិនមានភាពស្មោះត្រង់ចំពោះគេវិញនោះ បោកប្រាស់គេ គេនឹងឲ្យខ្ចីតែម្តងប៉ុណ្ណោះ ខ្លួនយើងក៏ពិបាករហូត ហើយមនុស្សនៅជាមួយអ្នកណា ធ្វើការជាមួយអ្នកណា គឺគួរតែមានភាពស្មោះត្រង់ចំពោះគេ ចំពោះការងារដែលធ្វើ និងចំពោះសម្តីរបស់ខ្លួនឯងផ្ទាល់។

ចិត្តស្មោះត្រង់ គឺជាការដែលមានចិត្តស្មោះ មាត់ និងចិត្តដូចគ្នា សម្តីនិងទង្វើដូចគ្នា មិនគិតបោកប្រាស់អ្នកណា ភាពស្មោះត្រង់នោះមានជាពពេះ ស៊ីមិនចេះអស់ទេស៊ីបានរហូតទៅ ព្រោះអ្នកផ្សេងគេទុកចិត្តយើង។

www.elibraryofcambodia.org

ការដែលរក្សាទុកបាននោះ វាក៏ស្ថិតនៅលើការចេះសន្សំចំចៃផងដែរ គឺត្រូវតែព្រមអត់ខ្លះ កុំតាមតែមាត់នឹកឃើញ កុំតាមតែចិត្តរបស់ខ្លួនឯងពេក ចង់ហូបអ្វី បើសិនជាទ្រាំបាន ក៏ទ្រាំទៅ ហូបរបស់ណាដែលចាំបាច់បានហើយ សូមកុំហូបព្រោះតែហៅ កុំហូបតាមតែចិត្តចង់ហូបនោះអី ចង់ប្រើអ្វីទ្រាំបាន ក៏ទ្រាំទៅ ប្រើរបស់ណាដែលចាំបាច់ត្រូវប្រើ ទិញរបស់ណាដែលចាំបាច់ត្រូវទិញ កុំទិញព្រោះតែចង់បាននោះអី។

ពេលដែលយើងអត់បាន លុយកាក់ក៏នៅនឹងយើង ព្រមទាំងយកចំណែកនោះទៅសន្សំទុកទៀត ធ្វើបែបនេះហើយដែលគេហៅថា សន្សំ ឬសន្សំទុក ហើយបើសិនជាកូនចង់សាងអនាគតឲបានឆាប់ៗនោះ កូនត្រូវតែធ្វើខ្លួនបែបនេះ ទើបសមតាមបំណងប្រាថ្នា។

www.elibraryofcambodia.org

# ១២.វិជ្ជា គឺជាទ្រព្យ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានសុភាសិតតាំងពីបុរាណមួយបានពោលថា **ពេលដែលនៅតូចគេខិតខំសិក្សា ដល់ចាស់កាលណាគេសុំស៊ីល** គឺពេលដែលអាយុនៅតិចគេខិតខំស្វែងរកចំណេះវិជ្ជា ដល់ពេលដែលខ្លួនធំដឹងក្តី គេប្រើចំណេះដឹងរកមាសប្រាក់ ទ្រព្យសម្បត្តិ ដើម្បីសាងអនាគត ហើយពាក្យទូន្មាននេះល្អខ្លាំងណាស់កូនអើយ ! ។

ការសិក្សារៀនសូត្រនោះ ជាចំណុចចាប់ផ្តើមដ៏សំខាន់របស់មនុស្សយើង ចំណេះវិជ្ជាជាដើមទុនក្នុងការរកស៊ី អ្នកដែលបានរៀនសូត្រតែងតែមានចំណេះវិជ្ជា អ្នកដែលមានចំណេះវិជ្ជាដឹងតែងតែមានប្រៀបនៅក្នុងការរកស៊ី ដែលពាក្យចាស់បានពោលថា **វិជ្ជាជាទ្រព្យ** គឺជាចំណេះដឹងជាទ្រព្យដើមទុនដែលមានខាងក្នុងខ្លួនរបស់មនុស្សយើង នៅជាប់នឹងខ្លួនយើងទៅគ្រប់ទីកន្លែង មិនពិបាកមើលថែនោះទេ អាចទាញចេញមកប្រើប្រាស់គ្រប់ពេលវេលា ហើយអាចយកមកប្រើប្រាស់ដើម្បីរកទ្រព្យសម្បត្តិទាំងក្រៅខ្លួនបានទៀតផង។

www.elibraryofcambodia.org

កូនគួរប្រកាន់ភ្ជាប់ជាមួយនឹងភាពស្មោះត្រង់ ដោយត្រង់ទៅត្រង់មក ធ្វើអ្វីក៏យកភាពស្មោះត្រង់ជាគោល ទោះបីជាបានផលប្រយោជន៍តបស្នងតិចក៏ដោយ កុំចោលអំពើល្អមួយនេះ ហើយអ្នកណាយល់ឃើញថា ការយកប្រៀបលើអ្នកដទៃជាពិសេសថា ជាអំពើវៃឆ្លាតនោះក៏ស្រេចតែគេទៅ អ្នកណាមកថាយើងល្ងង់ យើងឆោតនោះក៏ស្រេចតែគេ កុំទៅគិតច្រើនអី យើងកុំគិតដូចគេ ពីព្រោះបើសិនយើងមិនស្មោះត្រង់ទៅធ្វើអ្វីខុស ហើយត្រូវគេចាប់បាននោះ អ្នកដែលថាយើងល្ងង់ អ្នកដែលបានជំរុញឲយើងធ្វើខុស គេក៏មិនមកជួយដល់យើងដែរ យើងត្រូវទទួលទោស ទទួលខុសត្រូវដោយខ្លួនឯង និងតែម្នាក់ឯង។

បើសិនជាយើងធ្វើការដោយមានភាពស្មោះត្រង់ មុនដំបូងយើងរាក ពិបាក ប៉ុន្តែក៏សុខស្រួលនៅពេលក្រោយ ហើយយើងក៏មិនចាំបាច់ទទួលទុក្ខទោសអ្វីរហូតទៅដែរ។

www.elibraryofcambodia.org

# ១៣.ចេះស្រឡាញ់បងស្រឡាញ់ប្អូន

កូនសម្លាញ់របស់ពុកម៉ែអើយ !

បើសិនជាបងប្អូននឹងគ្នានោះ ចូរចេះស្រឡាញ់គ្នាទៅ សាច់ភាពអ ចិងគ្នា ទោះបីយ៉ាងណាក៏កាត់គ្នាមិនដាច់ដែរ លក់ក៏មិនបានផងដែរ កូនកុំស្អប់ខ្ពើម ឬក៏ច្រណែនឈ្នានីសគ្នាធ្វើអ្វី ជួយគ្នាមើលថែគ្នាទៅប្រសើរជាង ដោយបងប្អូននឹងគ្នា បែរជាមកឈ្លោះគ្នានោះ ពិតជារឿងដែលគួរឲ្យខ្មាសគេណាស់ មនុស្សល្អគេមិនធ្វើនោះទេ។

សូមគិតដល់ចិត្តរបស់ឪពុកម្ដាយផង បើសិនជាឈ្លោះគ្នានោះ គិតដល់កាលដែលនៅពីក្មេងៗទៅកូន ដោយឈ្លោះគ្នាហើយក៏ត្រូវគ្នាវិញ មកលេងជាមួយគ្នាបានដូចមុន បំភ្លេចរឿងដែលកន្លងហួសទៅ មកស្រឡាញ់គ្នា មកសាមគ្គីគ្នាដូចដើម បើមានការលំបាកជួយគ្នាបាន។

ស្វាមីអាចរកថ្មីបាន ភរិយាអាចរកថ្មីបាន កូនក៏អាចរកថ្មីបាន ប៉ុន្តែបងប្អូនរកមិនបានទៀតទេ មានប៉ុន្មានក៏មានប៉ុណ្ណឹង បើសិនជាកាត់កាលបងប្អូនដូចជាកាត់សាច់របស់ឪពុកម្ដាយអញ្ចឹងកូន។

www.elibraryofcambodia.org

ទើបកូនគួរតែតាំងចិត្តខិតខំរៀនសូត្រឲបានពូកែ ឲមានចំណេះដឹងទូលំទូលាយតាមដែលអាចធ្វើបាន ដោយពេលដែលកូនមានចំណេះវិជ្ជាប្រៀបបានដូចជាមានមរតកសំខាន់មួយដែរ ទោះបីជាមិនបានមរតកដែលជាមាសប្រាក់ ប៉ុន្តែក៏អាចប្រើចំណេះវិជ្ជារកមរតកបានដែរ។

www.elibraryofcambodia.org

# ១៥.ការចេះរក្សាចិត្តមនុស្ស

កូនសម្លាញ់របស់ពុកប៉ែអើយ !

ចៅហ្វាយដែលមានចិត្តល្អ មានភាពយុត្តិធម៌ ចេះរក្សាចិត្តថ្លើម ពិត ចេះប្រកាន់ខ្លួនជាមួយនឹងកូនចៅ មិនយកព្រៀប ពុំគាបសង្កត់លើកូនចៅ កូនចៅតែងតែស្រឡាញ់ និងគោរព មិនថានៅចំពោះមុខ ឬពីក្រោយខ្នងគាត់ឡើយ ហើយពេលណាដែលកូនមានឱកាសធ្វើជាចៅហ្វាយនាយ ឬក៏មេបញ្ជាការរបស់អ្នកដទៃ ចូរកុំភ្លេចការពិតពីរឿងនេះ បើសិនជាចង់ឲ្យកូនគេស្រឡាញ់ ចង់ឲ្យគេគោរព ហើយមានភាពស្មោះត្រង់ ក៏ត្រូវតែធ្វើនូវអ្វីដែលគេគោរព និងស្មោះត្រង់ វាប្រសើរជាជាងធ្វើនូវរឿងឲ្យគេខ្លាច ប៉ុន្តែមិនមានការគោរព។

អ្នកគ្រប់គ្រងដែលតែងតែប្រើនូវអំណាចច្រើនជាងគុណធម៌ ដោយបានតែមនុស្សខ្លាច ប៉ុន្តែមិនមានអ្នកណាគោរព និងស្មោះត្រង់ទេ ហើយចំពោះអ្នកដែលប្រើគុណធម៌ច្រើនជាងអំណាច ដោយបានទាំងអ្នកខ្លាច អ្នកគោរព និងអ្នកដែលមានភាពស្មោះត្រង់។

ថ្នាក់លើដែលគិតចង់គ្រប់គ្រងចិត្តមនុស្ស ដោយការប្រើអំណាចផ្តាច់ការ ធ្វើឲគេឯងខ្លាចនោះ ចាត់ទុកថា គេមានការយល់ច្រឡំហើយ

www.elibraryofcambodia.org

# ១៤.គ្រួសារដែលមានភាពកក់ក្ដៅ

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពាក្យថា **គ្រួសារមួយមាត់** ជាពាក្យដែលមានន័យបំផុត គឺមានន័យដល់ក្ដីស្រឡាញ់ ភាពកក់ក្ដៅ និងភាពចុះសម្រុងនឹងគ្នា ដោយកាលដែលកូនចៅនៅតូចៗយើងនៅជាមួយគ្នាជាគ្រួសារ អានសំឡេងសើចសប្បាយក្អាកក្អាយ មានសំឡេងរត់លេងដេញគ្នាពេញផ្ទះ បានញុំាបាយជាមួយគ្នា បានធ្វើស្អីៗជាមួយនឹងគ្នា មើលទៅពិតជាល្អខ្លាំងណាស់ ហើយទោះបីជាឪពុកម្ដាយមកពីការធ្វើការហត់នឿយ៉ាងណា ពេលដែលឃើញមុខកូនៗមកចាំទទួលនៅមាត់ទ្វារ សួរថាហត់នឿយឬទេ និងជួយកាន់របស់របរឲ្យ តែប៉ុណ្ណឹងក៏បាត់ហត់នឿយទៅហើយ ព្រមទាំងឃើញកូនញុំាបាន ដេកលក់ស្រួល ពុកម៉ែក៏សប្បាយចិត្តទៅហើយ។

នេះហើយកូនសម្លាញ់អើយ! ដែលគេហៅថាជាគ្រួសារកក់ក្ដៅនោះ ពេលនេះកូនធំៗអស់ទៅហើយ បើសិនជាអាចទៅរួចនោះ ពុកម៉ែចង់ឲ្យគ្រួសាររបស់យើងជាគ្រួសារដែលមានភាពកក់ក្ដៅ នៅជួបជុំគ្នាដូចកាលពីនៅក្មេងៗអញ្ចឹង ទោះបីយូរៗម្ដងក៏ល្អដែរ ដែលបានជួបមុខគ្នានោះ ហូបបាយជាមួយគ្នា សួរសុខទុក្ខគ្នាទៅវិញទៅមក បានបីចៅតូចៗ តែប៉ុណ្ណឹងក៏គ្រប់គ្រាន់ ដែលថែមអាយុឲ្យពុកម៉ែនៅបានច្រើនឆ្នាំទៀតកូនសម្លាញ់។

www.elibraryofcambodia.org

# ១៦.មានបានហើយ ចូរកុំភ្លេចខ្លួន

កូនសម្លាញ់របស់ពុកម៉ែអើយ !

ដូចដែលពុកបានប្រាប់ដល់កូនចៅមកហើយថា ការចេះសន្សំតែងតែជារឿងមួយល្អ ដោយចាប់ផ្ដើមពីមនុស្សក៏អាចកសាងកេរ្ដិ៍ ត្រូវធ្វើតាមដោយមានភាពម៉ត់ចត់ សន្សំបានច្រើនក៏សល់ច្រើន សល់ច្រើនប៉ុណ្ណាក៏អាចកសាងឋានៈបានប៉ុណ្ណឹងដែរ ហើយបើសិនជាចាប់ផ្ដើមកសាងអនាគត គឺត្រូវចាប់ផ្ដើមចេះសន្សំទុកជាមុនសិន កុំអោយរាយប៉ាយផ្ដេសផ្ដាស ចេះចាយ ចេះប្រើ ចាយវាយព្រុសៗ ដោយបើសិនធ្វើបាន អាចសាងខ្លួនបានហើយ។

សូមប្រាប់កូនទុកជាមុនថា ពេលដែលកូនសន្សំអាចកសាងអនាគតបានហើយនោះ កូនត្រូវប្រយ័ត្នប្រយែងខ្លួនឲ្យល្អ ព្រោះប្រាកដតែពេលណាបានសន្សំធ្វើជីវភាពរបស់កូនបានគ្រាន់បើនោះ វាអាចធ្វើឲ្យកូនភ្លេចខ្លួន ឈ្លក់វង្វេងទៅនឹងលាភប្រាក់ទ្រព្យសម្បត្តិទាំងនោះ រហូតក្លាយទៅជាមនុស្សមានភាពអាត្មានិយមបាន ធ្វើជាមនុស្សលេងខ្លួន ក្អេងក្អាង ពេកពេន់ មានចិត្តបរិភ្ជុតា ឬក៏ដើរតាមសង្កត់ដល់អ្នកដទៃ ដោយគិតថា ខ្លួនមានមាសប្រាក់ ចង់ធ្វើអ្វីក៏បានដែរតាមតែអំពើចិត្ត។

www.elibraryofcambodia.org

ដោយពិតប្រាកដនោះ កើតចេញពីការចេះយោគយល់ជាសំខាន់ ការរំភើបចិត្ត និងក្តីសន្តោសប្រណីមេត្តា ដូចជា ៤មាសប្រាក់ របស់ប្រើប្រាស់ ៤ជាកម្លាំងចិត្ត ៤ការយោគយល់គ្នា ៤ជាពាក្យណែនាំល្អៗ ៤ពាក្យលួងលោម ៤ភាពកក់ក្តៅ ព្រមទាំងជាការផ្តល់កិត្តិយស ឬការកោតសរសើរផងដែរ។

បើសិនជាចង់គ្រប់គ្រងចិត្តមនុស្សបានរហូតទៅ ត្រូវតែរៀន៤របស់ទាំងអស់នោះដល់គេ ដោយការគ្រប់គ្រងមនុស្សដែលល្អ គឺជាគ្រប់គ្រងចិត្តមនុស្ស ហើយការគ្រប់គ្រងចិត្តមនុស្សដែលល្អបំផុតនោះ គឺជាការគ្រប់គ្រង៤អ្នកដទៃមានការពេញចិត្ត ពេលណាដែលអ្នកដទៃមានការពេញចិត្ត ហើយនោះ បញ្ហានៅក្នុងការគ្រប់គ្រងក៏ស្ទើរតែគ្មានផងដែរ។

www.elibraryofcambodia.org

# ១៧.មិត្តដែលមានភាពស្មោះត្រង់អស់មួយជីវិត

កូនសម្លាញ់របស់ពុកម៉ែអើយ !

តើកូនធ្លាប់បានពិតដែរឬទេថា មិត្តដែលល្អបំផុតរបស់យើងនោះគឺ **សៀវភៅ** ដោយសារសៀវភៅជាមិត្តរបស់យើងបានគ្រប់ពេលវេលា មិនថាជាពេលដែលមានសេចក្តីសុខ ពេលកើតទុក្ខ សោកសៅ ឬក៏ពេលអផ្សុកក៏ដោយឡែកនោះ វាអាចតាមយើងទៅបានគ្រប់ទីកន្លែងមិនថា នៅក្នុងព្រៃ នៅលើភ្នំ នៅសមុទ្រនោះទេ ដល់ទីបំផុតនៅក្នុងបន្ទប់របស់យើងក៏ដោយ។

មិនថា កូនជាអ្វី កូននៅទីកន្លែងណាទេ ចូរកូនកុំចោលសៀវភៅអី ដោយហេតុថាការចោលសៀវភៅដូចជាចោលមិត្តដែលល្អបំផុត ព្យាយាមមើលសៀវភៅឲ្យបានច្រើន សៀវភៅអ្វីក៏ដោយ។

សៀវភៅប្រៀបបានដូចជាផែនទី ដែលវានាំផ្លូវយើងទៅរកគោលដៅឃើញ មើលសៀវភៅច្រើនក៏ដូចជាមានផែនទីសម្រាប់ដំណើរការនៅក្នុងជីវិតច្រើន ពីព្រោះសៀវភៅ គឺជាខួរក្បាលរបស់អ្នកនិពន្ធ ដែលគេបានចងក្រងមកឲ្យយើងអាន ដោយការមើលសៀវភៅច្រើនប៉ុណ្ណា ក៏ដូចជាមានមិត្តភក្តិច្រើនប៉ុណ្ណឹងដែរ វាស្មើនឹងបន្ថែមខួរក្បាលរបស់អ្នកនិពន្ធ មកនៅក្នុងខួរក្បាលរបស់យើងផងដែរ។

www.elibraryofcambodia.org

មាសប្រាក់កែវកងដូចជាអាវុធមុខពីរ ដែលគុណាបាន ឲទោសក៏បានផងដែរ សូមកូនគិតជានិច្ចថា សន្សំមាសប្រាក់ទុកដើម្បីដោះស្រាយជីវភាព និងដើម្បីចិញ្ចឹមគ្រួសារឲមានសេចក្ដីសុខ បើសិនជាមានហើយចង់បែងចែកជួយអ្នកផ្សេងៗនោះ ក៏ធ្វើតាមចិត្តរបស់កូនដែលយល់ឃើញថា សមរម្យនោះទៅ។

កូនគិតបែបនេះ ក៏បានប្រយោជន៍ពីមាសប្រាក់ ដែលបានសន្សំទុកមកនោះ ហើយពេលដែលមានហើយកុំភ្លេចខ្លួនអីកូន។

www.elibraryofcambodia.org

# ១៩.ការគ្រោះថ្នាក់មកពីការជក់បារី

កូនសម្លាញ់របស់ពុកម៉ែអើយ !

បើសិនជានិយាយអំពីបារីនោះ តែងតែដឹងច្បាស់ហើយថាជារបស់ដែលមានពិសក្នុងពេលបច្ចុប្បន្ននេះ ដោយសារតែមនុស្សភាគច្រើនខ្លាំងឡើងមិនព្រមឲ្យអ្នកណាមកជក់បារីតាមតែអំពើចិត្តដូចមុនទេ រហូតកំណត់ច្បាប់ចេញច្បាប់ទម្លាប់ហាមមិនឲ្យជក់បារីនៅតាមកន្លែងទីសាធារណៈផងដែរ។

អ្នកដែលមិនជក់បារី មានការយល់ឃើញថា អ្នកជក់បារីមានគ្រោះថ្នាក់ចំពោះគេ ប៉ុន្តែអ្នកដែលជក់បារីគេយល់ឃើញថា វាជាសិទ្ធិរបស់គេ ការជាផ្ទះហើយ ទើបគេនៅជក់បារីដែលដឹងពីទោស និងដឹងពីផលអាក្រក់របស់វាហើយ ទាំងដឹងដែលថា បារីជាអ្នកបំផ្លាញលុយកាក់ បំផ្លាញសុខភាព និងវេទនាមុនពេលនឹងស្លាប់ ប៉ុន្តែក៏នៅតែចោលវាមិនបាន ពីព្រោះតែបានញៀនបាត់ទៅហើយ។

កូនខ្លួនឯង ក៏កុំឲ្យបារីមកបំផ្លាញកូនបានឲ្យសោះ បើសិនមិនទាន់ចេះជក់កុំទៅរៀនជក់អី បើសិនជាញៀនហើយព្យាយាមឈប់ឲ្យបាន ការដែលមិនញៀនបារីនោះ នឹងធ្វើយើងមានសេរីភាព ជាម្ចាស់ការលើខ្លួនឯង និងមិនខ្ជះខ្ជាយទ្រព្យសម្បត្តិរបស់យើងផងដែរ។

www.elibraryofcambodia.org

# ១៨.ពូកែប្រឌិតរឿង

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានការប្រព្រឹត្តិម្យ៉ាងដែលមនុស្សខ្លះគេចូលចិត្តធ្វើនោះគឺ ការប្រឌិតរឿង ដូចជាប្រឌិតរឿងឡើងមកដើម្បីផលប្រយោជន៍អ្វីម្យ៉ាង ដូចជាបើប្រើ លើកដល់ខ្លួនឯង ដើម្បីធ្វើបាបអ្នកដទៃ ឬក៏ដើម្បីឲ្យអ្នកដទៃបែកបាក់គ្នា ដែលរឿងនោះមិនមែនជាការពិតផងនោះ ដែលមិនមែនជារឿងពិត ប៉ុន្តែម្នាក់នោះមានវិធីធ្វើឲ្យអ្នកដទៃអាចជឿជាក់បាន។

ពេលខ្លះកាលដែលអ្នកប្រឌិតនោះ មានយសស័ក្តិ ទើបធ្វើឲ្យគេមានការជឿជាក់ ទាំងរឿងដែលប្រឌិតឡើងមកនោះ មិនអាចពិសោធបាន ឬក៏មិនអាចជឿជាក់បានថាជាការពិតផងដែរ ប៉ុន្តែ បែរក្លាយជាអ្នកស្តាប់នោះជឿទៅលើអ្នកនិយាយជារឿងសំខាន់។

រឿងបែបនេះដែរបានបំផ្លាញមនុស្សជាច្រើនមកហើយ មិត្តត្រូវបែកបាក់គ្នា ប្ដីប្រពន្ធត្រូវឈ្លោះគ្នា ឬក៏បែកបាក់គ្នា ចៅហ្វាយ និងកូនចៅត្រូវបានទាស់ចិត្តគ្នា អ្នកនៅជាមួយគ្នាមើលមុខគ្នាមិនចំ ដោយទាំងអស់នេះសុទ្ធតែមានមូលហេតុមកពីការប្រឌិតរឿងឡើងទាំងអស់។

www.elibraryofcambodia.org

# ២១.សេចក្ដីប្រាថ្នារបស់ឪពុកម្ដាយ

កូនសម្លាញ់របស់ពុកម៉ែអើយ !

កូនអាចមិនទាន់ដឹងទេអំពីបំណងប្រាថ្នារបស់ឪពុកម្ដាយ ដោយសារនៅពេលដែលកូនមិនទាន់បានធ្វើជាឪពុកម្ដាយរបស់គេនៅឡើយនោះ ដោយឪពុកម្ដាយគ្រប់រូបតែងតែមានការឈឺស្ដាត់ ឬក៏មានការអផ្សុក ហើយបើមិនបានឃើញកូនរបស់ខ្លួនមកបម្រើមើលថែនៅជិតខ្លួននោះ មកពេលបានឃើញជាញឹកញាប់នោះ កូនអើយ! គឺវាប្រៀបបាននឹងជាថ្នាំទិព្វពិតប្រាកដ ដែលធ្វើឲ្យឪពុកម្ដាយបាត់ពពីស្ដាត់ឬយរំពេចនោះ។

កាលដែលកូនមកលេងឲ្យឃើញមុខ បានសួរសុខទុក្ខ ឪពុកម្ដាយគ្រប់រូបក៏សប្បាយចិត្តទៅហើយ ដោយសារតែវាប្រៀបដូចជាកំពូលនៃក្ដីប្រាថ្នាគ្រប់រូបរបស់ឪពុកម្ដាយទៀតផង ហើយជាពិសេសនៅពេលដែលខ្លួនចាស់ជរាទៅហើយ ជួយដល់ខ្លួនឯងមិនសូវបាននោះ កាន់តែមានក្ដីប្រាថ្នាចង់ឲ្យកូនមកនៅជិតខ្លួន ទោះបីជាដឹងថា កូនមានការរវល់ មានការងារត្រូវធ្វើជាច្រើន មិនសូវមានពេលទំនេរមកលេងក៏ដោយ ប៉ុន្តែក៏នៅតែរត់រកគ្មានិយមមិនបានទេ ចង់ឲ្យកូននៅជិតបម្រើមើលថែ។

www.elibraryofcambodia.org

# ២០.ចរិយាសង្គម

កូនសម្លាញ់របស់ពុកម៉ែអើយ !

ការរស់នៅជាមួយនឹងគ្នានៅក្នុងសង្គមនោះ ដោយរបស់មួយដែលមិនអាចខ្វះបាននោះគឺ **ចរិយាសង្គម** ដែលមានដូចជា ភាពទន់ភ្លន់ ការចេះដាក់ខ្លួន ការចេះស្គាល់ចាស់ទុំ ចេះមានការគួរសម ហើយការដែលមានចរិយាសង្គមបែបនេះ ជាគ្រឿងតុបតែងខ្លួនយ៉ាងល្អជាងខោអាវ និងគ្រឿងអលង្ការមាសប្រាក់ទៅទៀត។

កូនគួរតែហាត់រៀនចរិយាសង្គមបែបនេះ ឲជាទម្លាប់ឲល្អទៅ ដោយរដល់ពេលដែលអនុវត្តផ្ទាល់ទើបមិនខ្មាសគេ ហើយពេលដែលទៅទំនាក់ទំនងការងារជាមួយនឹងអ្នកដទៃ ឬចូលទៅរកអ្នកធំក៏ដោយ បើសិនជាកូនដឹងហើយ និងបដិបត្តិចរិយាសង្គមបានយ៉ាងល្អ កូននឹងមានប្រជាប្រិយភាពជាពិសេសចំពោះអ្នកដែលកូនបានទៅរកនោះ។

ចរិយាសង្គមនេះ ជាមន្តស្នេហ៍របស់មនុស្សម្យ៉ាង ដូចជាការខ្លាចក្រែងចិត្តគេដែរ ដោយមិនថាជាអ្នកណាក៏ដោយ តែងតែចូលចិត្តអ្នកដែលចេះគោរពដាក់ខ្លួន ចេះធ្វើខ្លួនសមរម្យ ជាមនុស្សមានចំណេះដឹងល្អ ប៉ុន្តែបើសិនជាខ្វះប្រជាប្រិយភាពខាងចរិយាសង្គមហើយ តើគេនឹងគួរឲគោរពកោតសរសើរបានយ៉ាងម៉េចទៅ ? ។

www.elibraryofcambodia.org

អធ្យាស្រ័យ ឬមានការអធ្យាស្រ័យមិនល្អ នោះក៏បានតែសត្រូវ មនុស្សដែលស្អប់ខ្ពើម មិនចង់ផ្តល់ជួយអ្វីនោះឡើយ។

ការមានការអធ្យាស្រ័យល្អ ក៏ដូចមានថ្នាំមានមន្តស្នេហ៍បហានិយម នៅក្នុងខ្លួនអញ្ចឹង ដោយមិនចាំបាច់ខាតពេលវេលា ទៅរកថ្នាំពិសេសនៅឯណានោះឡើយ។

www.elibraryofcambodia.org

# ២២.មន្តស្នេហ៍មហានិយម

កូនសម្លាញ់របស់ពុកម៉ែអើយ !

គេនមនុស្សមិនតិចទេ ដែលចង់ទទួលបានមន្តស្នេហ៍មហានិយម ក៏ព្រោះតែជឿថា អាចធ្វើឲខ្លួនឯងមានមន្តស្នេហ៍ មានមនុស្សស្រឡាញ់រាប់អានច្រើន ព្រមទាំងអាចជួយឲរកស៊ីបាន ទើបនាំគ្នាស្វែងរកថ្នាំមន្តស្នេហ៍នោះ ដោយតាមការពិតទៅថ្នាំបែបនេះ មាននៅក្នុងខ្លួនរបស់យើងគ្រប់តែគ្នាហ្នឹង ប៉ុន្តែមិនចេះយកចេញមកប្រើប្រាស់ ហើយថ្នាំប្រភេទនេះជាថ្នាំមន្តស្នេហ៍ពិតប្រាកដ អាចចងមិត្ត ចងចិត្តមនុស្សទុកបាន ឬធ្វើឲគេស្រឡាញ់រាប់អានគ្មានថ្ងៃសាបរលាភបាននោះទេ ថ្នាំដែលថានោះដែរ គឺជាការគេនអធ្យាស្រ័យនោះហើយ អ្នកដែលមានការអធ្យាស្រ័យល្អ តែងតែមានមន្តស្នេហ៍នៅក្នុងខ្លួនជានិច្ច។

ថ្នាំមន្តស្នេហ៍នោះរួមផ្សំជាមួយគឺ ការសួរនាំដល់គេមុន ញញឹមឲគេពេលដែលនិយាយជាមួយគេ បង្ហាញពីការយកចិត្តទុកដាក់ដែលចង់ជួយដល់គេ ចាប់អារម្មណ៍ពីរឿងដែលគេនិយាយ និងរឿងដែលគេធ្វើ ដោយឬកពាដែលគេហៅថា **ការមានអធ្យាស្រ័យ** អ្នកណាដែលអាចធ្វើបាននោះតែងតែមានមនុស្សស្រឡាញ់រាប់អានខ្លាំងណាស់ ហើយអ្នកដែលគ្មានការ

www.elibraryofcambodia.org

របស់អ្នកដទៃនោះ ហៅថា **មនុស្សគ្មានចិត្ត** ដោយមនុស្សគ្មានចិត្តមើលមិនឃើញអំពើល្អរបស់អ្នកដទៃទេ ប្រកាន់ខ្ជាប់នូវចិត្តទុទិដ្ឋិនិយមជានិច្ច។

យើងរកភាពយុត្តិធម៌ពីមនុស្សគ្មានចិត្តពិតជាពិបាកណាស់ សូម្បីតែខ្លួនគេផ្ទាល់ ជួនកាលគេទាំងមិនដឹងខ្លួនថា ខ្លួនឯងជាមនុស្សគ្មានចិត្តផងដែរ ដោយមនុស្សឆ្កួតគួរគេរាប់អានជាងមនុស្សគ្មានចិត្តទៅទៀត បើយើងនៅធ្វើល្អជាមួយមនុស្សគ្មានចិត្ត ត្រូវត្រៀមចិត្តទុកជាមុនថា គេនឹងមិនឃើញអំពើល្អរបស់យើងនោះទេ។

ការដែលប្រាប់កូនបែបនេះ គឺដើម្បីឲ្យកូនបានដឹងថា មនុស្សយើងដែលស្គាល់មុខ ប៉ុន្តែមិនស្គាល់ចិត្ត ត្រូវតែល្បងមើលឲ្យដឹងពីជម្រៅចិត្តគេ ទើបយើងនឹងបានប្រយ័ត្នខ្លួន និងសម្រេចចិត្តបានយ៉ាងត្រូវនៅក្នុងពេលត្រូវការនោះ។

«កូនកុំធ្វើខ្លួនជាមនុស្សគ្មានចិត្តដោយខ្លួនឯងឲ្យសោះ»

www.elibraryofcambodia.org

# ២៣.មនុស្សដែលគ្មានចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

កូនប្រហែលធ្លាប់បានឮពាក្យសម្ដីមួយថា **មើលគ្នាតែក្នុងផ្លូវល្អ** នេះជាពាក្យសម្ដីប្រាប់ឲយើងមើលចំណុចល្អរបស់មនុស្សដែលយើងស្គាល់ ឬអ្នកដែលយើងរាប់អាន និងអ្នកដែលនៅជាមួយនឹងយើងផងដែរ ពីព្រោះមនុស្សយើងម្នាក់ៗសុទ្ធតែធ្វេសប្រហែសដូចគ្នាទាំងអស់ គ្មានអ្នកណាល្អគ្រប់យ៉ាងទាំងអស់នោះទេ ដោយពេលដែលស្រឡាញ់រាប់អានគ្នា និងស្រឡាញ់ចង់នៅជាមួយនឹងគ្នា គឺត្រូវតែមើលចំណុចល្អៗរបស់គ្នាទៅ និងចំណុចអាក្រក់ បើសិនគ្មានច្រើនដល់ថ្នាក់ទទួលយកមិនបានទេ ក៏មើលរំលងទៅ ដោយយកតែចំណុចល្អរបស់គេទុកជាការសំខាន់ ក៏អាចធ្វើឲលុបបំបាត់ចំណុចអាក្រក់របស់គេ ឬអាចធ្វើឲរំសាយបានខ្លះដែរ។

តាមការពិតមនុស្សយើងមានចំណុចល្អៗដូចតែគ្នាទាំងអស់ បើសិនមើលដោយចិត្តយុត្តិធម៌ ហើយមនុស្សដែលមានចិត្តយុត្តិធម៌តែងតែមើលឃើញអំពើល្អអ្នកដទៃបានដោយងាយ ដោយចំណែកអ្នកគ្មានចិត្តយុត្តិធម៌ទោះបីជាអ្នកផ្សេងៗគេមានចិត្តល្អយ៉ាងណាក៏ដោយ តែងតែមើលរំលង ឬក៏ធ្វើជាមើលមិនឃើញ ហើយមនុស្សភ្នែកល្អដែលមើលមិនឃើញអំពើល្អ

www.elibraryofcambodia.org

# ២៥.ការជ្រើសរើសសេពគប់មនុស្ស

កូនសម្លាញ់របស់ពុកម៉ែអើយ !

ការជ្រើសរើសសេពគប់គ្នាជារឿងធម្មតា ដោយមនុស្សដែលយើងត្រូវសេពគប់គ្នាជាមិត្តភក្តិ ទោះបីជាមិនបានប្តូរជីវិតគ្នា ប៉ុន្តែមនុស្សដែលយើងត្រូវសេពគប់ជាប្តូរគ្នានោះ ត្រូវតែមើលឲ្យបានល្អ មើលឲ្យច្បាស់ ពីអត្តចរិតរបស់គេ គំនិតឬគោលការរបស់គេ បើសិនបានឃើញថា គេល្អមែនចាំរាប់អានជាមិត្តស្និទ្ធស្នាល ហើយបើសិនគេមានចំណុចខ្លះមិនល្អ រាប់អានត្រឹមតែជាអ្នកស្គាល់គ្នាធម្មតាក៏មិនអីដែរ។

ការសេពគប់ជាមួយនឹងមនុស្សនោះ ត្រូវតែដឹងហើយ និងស្វែងយល់ឲ្យបានច្បាស់លាស់ មនុស្សខ្លះអាចរាប់អានបាន ប៉ុន្តែនៅតែកន្លែងធ្វើការប៉ុណ្ណោះ អ្នកខ្លះអាចរាប់អានបានត្រឹមតែនៅលើផ្លូវជាប្តូរគ្នាប៉ុណ្ណោះ អ្នកខ្លះបានត្រឹមតែស្គាល់គ្នា ឬអ្នកខ្លះអាចទុកចិត្តនៅជាប្តូរនឹងគ្នាបានក៏មានដែរ។

កូនចង់សេពគប់ពេញចិត្តអ្នកណា ចង់រាប់អានគ្នាបែបណាក៏ជាសិទ្ធិរបស់កូន ប៉ុន្តែពុកម៉ែគ្រាន់តែប្រាប់ថា សេពគប់មនុស្សបែបណា យើងក៏ជាមនុស្សបែបនោះដែរ ដោយសេពគប់បណ្ឌិតនាំប្រាជ្ញាឲ្យបានសុខ សេពគប់ពាលបានទុក្ខសៅហ្មងចិត្ត កូនពិចារណាមើលខ្លួនឯងទៅ ! ។

www.elibraryofcambodia.org

# ២៤.ទាសកររបស់អារម្មណ៍

កូនសម្លាញ់របស់ពុកម៉ែអើយ !

ចិត្តរបស់មនុស្សយើងនោះ តែងតែមានការប្រែប្រួល មិនទៀងទាត់ ឆេវឆាវ មិនសូវគិតមុខក្រោយ យកតែចិត្តរបស់ខ្លួនឯងជាសំខាន់ ទើបតែងតែធ្វើអ្វីតាមអំពើចិត្ត និងធ្វើតាមអារម្មណ៍ ហើយបើសិនបែបនេះញឹកញាប់នោះ ក៏ក្លាយជាទាសកររបស់អារម្មណ៍ ដោយនៅទីបំផុតពេលក្លាយជាទាសកររបស់អារម្មណ៍ហើយនោះ ក៏ត្រូវអារម្មណ៍បញ្ជាគ្រប់ពេលវេលា រកភាពស្ងប់ស្ងៀមនៅក្នុងជីវិតមិនសូវបាននោះទេ។

អ្នកដែលក្លាយជាទាសករអារម្មណ៍ តែងតែគិតថា មានតែខ្លួនឯងនោះទេដែលធ្វើត្រូវ គិតត្រូវ អ្នកផ្សេងៗខុស អ្នកផ្សេងប្រៀបជាមួយនឹងខ្លួនមិនបាននោះទេ ដោយមិនព្រមស្តាប់អ្នកណា ឬតែងតែគិតថា គ្មានអ្នកណាធ្វើត្រូវចិត្តនោះឡើយ ទើបត្រូវធ្វើការដោយម្នាក់ឯង អ្នកផ្សេងធ្វើជាមួយមិនបាននោះទេ ទើសចិត្តទាំងអស់។

ចរិតបែបនេះហើយកូន ដែលគេហៅថា ជាទាសកររបស់អារម្មណ៍ ជាចរិតដែលកូនត្រូវតែបោះបង់ចោល បើសិនមិនដូចនេះទេ រកភាពស្ងប់ស្ងាត់ខាងផ្លូវចិត្តមិនបានទេ មានការធុញទ្រាំ ធុញថប់ រហូតទៅ។

www.elibraryofcambodia.org

ការចិញ្ចឹមកូនឲ្យបានល្អតាមវិធីមួយទៀត គឺជាការតម្រូវកូនឲ្យធ្វើជាមនុស្សមានទឹកចិត្ត ជួយដល់អ្នកដទៃ ជួយអ្នកក្រលំបាក បែបនេះក៏ជាការបង្ហាត់ឲ្យគេជាមនុស្សល្អដែរ។

មនុស្សយើងសុទ្ធតែចង់ល្អគ្រប់គ្នា ប៉ុន្តែល្អមិនបាន ខ្លះអាចមកពីអ្នកជិតខ្លួន ខ្លះមកពីបរិស្ថាន ខ្លះមកពីហេតុការណ៍ផ្សេងៗ ខ្លះក៏គ្មានឱកាសធ្វើអំពើល្អ បើសិនយើងចង់ឲ្យកូនយើងល្អតាមដែលយើងត្រូវការនោះ ដោយយើងធ្វើឲ្យចិត្តកូនបរិញ្ញាណរបស់គេល្អជាមុន យើងត្រូវការវិធីនៅក្នុងការចិញ្ចឹម ធ្វើដោយសន្សឹមៗ ប្រាប់ដោយសន្សឹមៗ ដឹកនាំដោយសន្សឹមៗ ណែនាំឲ្យគេដើរផ្លូវល្អៗ គេប្រាកដជាកូនដូចដែលយើងត្រូវការ។

ការចិញ្ចឹមកូនឲ្យបានល្អនោះ ដូចជាពិបាកផងដែរ ដូច្នេះយើងត្រូវធ្វើជារឿយៗ កុំអាចនឿយណាយ ព្រោះការដែលធ្វើកូនបានល្អនោះ គឺពិបាកជាងអ្វីទាំងអស់ សូមឲ្យកូនចងចាំពាក្យនេះទុកថា បើសិនជាចង់ឲ្យកូនល្អ ត្រូវតែធ្វើល្អឲ្យកូនមើលជាមុនសិន សូមកុំមានចិត្តកំណាញ់ចំពោះកូននោះទេ។

www.elibraryofcambodia.org

# ២៦.ចិញ្ចឹមកូនឲបានល្អ

កូនសម្លាញ់របស់ពុកម៉ែអើយ !

ការដែលចិញ្ចឹមកូនតាមបែបត្រឹមត្រូវមួយទៀត ដោយចិញ្ចឹមកូនឲបានល្អនោះ មានន័យថា ត្រូវឲគេធ្វើជាមនុស្សល្អទាំងកាយ វាចា ចិត្ត និងតាមការពិតឪពុកម្តាយគ្រប់រូបចង់ឲកូនជាមនុស្សល្អទាំងអស់ ប៉ុន្តែកូនមិនបានធ្វើជាមនុស្សល្អតាមតម្រូវចិត្តរបស់ឪពុកម្តាយនោះទេ ហើយរឿងនេះវាស្ថិតនៅលើយើងជាឪពុកម្តាយផងដែរ គឺយើងត្រូវតែធ្វើជាគំរូដ៏ល្អដល់កូនជាមុនសិន យើងចង់ឲកូនយើងល្អយ៉ាងណា ពូកែយ៉ាងណា យើងត្រូវតែឲគេបានឃើញ ឬនាំទៅមើលបែបល្អតាមដែលយើងចង់បាននោះ។

ដូចជា ចង់ឲកូនមានទឹកចិត្ត មានមេត្តាករុណា យើងត្រូវតែធ្វើខ្លួនឲជាមនុស្សមានទឹកចិត្ត មានមេត្តាករុណាឲគេឃើញជាញឹកញាប់ទៅ យើងចង់ឲកូនមានការព្យាយាម ស្មោះត្រង់ សុចរិត មានភាពកតញ្ញូ យើងត្រូវតែធ្វើបែបនេះជាគំរូជាមុនសិន ហើយការដែលគិតតែប្រដៅ គិតតែប្រាប់ឲកូនធ្វើជាមនុស្សព្យាយាម ស្មោះត្រង់ កតញ្ញូ មិនសូវទទួលបានផលប៉ុន្មាននោះទេ ឲគេយកធ្វើជាគំរូមិនបាននោះទេ។

www.elibraryofcambodia.org

ពេះកាយវាយ មិនប៉ះពាល់អំពើអបាយមុខ និងគ្រឿងញៀនផ្សេងៗ មិន ក្រោយមិនឆាប់ក៏ធូរធារ មានអនាគតល្អ ជីវិតសុខស្រួល ហើយអ្នកខ្លះពីដើម ជីវិតស្រណុកសុខស្រួលណាស់ មានឪពុកម្តាយជាអ្នកមានទ្រព្យសម្បត្តិ ច្រើន ប៉ុន្តែ គិតខ្លីតាមតែចិត្តរបស់ខ្លួនឯង មិនគិតពីតម្លៃទ្រព្យសម្បត្តិ របស់ឪពុកម្តាយរកទុក ចាយវាយយ៉ាងខ្ជះខ្ជាយ ដោយមិនយូរប៉ុន្មានក៏ អស់ពីខ្លួន ជីវិតក៏ចាប់ផ្តើមពិបាក អស់អនាគតទៅ ដែលជារឿងគួរគេ ស្តាយជំនួសឪពុកម្តាយរបស់គេណាស់ ដែលឪពុកម្តាយរកអស់មួយជីវិត ប៉ុន្តែបែរជាត្រូវកូនរបស់ខ្លួនឯងបំផ្លាញអស់ក្នុងពេលមិនប៉ុន្មានឆ្នាំ។

អំពើអបាយមុខមិនចេះស្រឡាញ់អ្នកណាទេគួរ វាបំផ្លាញអនាគត មនុស្សគ្រប់គ្នា ហើយបើសិនជាញៀនជាមួយនឹងវានោះ ត្រូវធ្វើតាម ពាក្យបុរាណដែលថា **ស្រឡាញ់ច្រើនឲបន្ថយ ស្រឡាញ់តិចឲបន្ថែម** ពិត ជាល្អណាស់។

## ២៧.ស្រឡាញ់ច្រើនចបន្ថយ ស្រឡាញ់តិចចបន្ថែម

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពាក្យចាស់បុរាណបាននិយាយតៗគ្នាថា **ស្រឡាញ់ច្រើនចបន្ថយ ស្រឡាញ់តិចចបន្ថែម** ដោយយល់ថាមានន័យល្អទើបបានកែណែនាំកូន គឺបើសិនយើងចង់បានអនាគតល្អ បានជីវិតរស់នៅយ៉ាងសុខតភាពរុងរឿងទៅ ត្រូវកាត់បន្ថយកាត់ផ្តាច់របស់ដែលបំផ្លាញអនាគត បំផ្លាញជីវិតរបស់យើង កុំចូលទៅជិតរបស់ទាំងអស់នោះ ដូចជា អំពើអបាយមុខ គ្រឿងញៀន ខ្ជិលច្រអូស ខ្ជះខ្ជាយ ទាំងនេះសុទ្ធតែជារបស់កាត់បន្ថយអនាគតរបស់យើងទាំងអស់ បើសិនអាចកាត់ចេញពីជីវិតរបស់យើងបាន អនាគតរបស់យើងក៏មានភាពរុងរឿងបានមិនពិបាកនោះទេ។

ប៉ុន្តែ បើសិនជាយើងគិតខ្លី គិតតែរបស់ចំពោះមុខ គិតតែសប្បាយចំពោះមុខ មានជីវិតពីមួយថ្ងៃទៅមួយថ្ងៃ អនាគតទៅជាយ៉ាងណាមិនខ្វល់ មានការខ្ជិលច្រអូស ខ្ជះខ្ជាយ អនាគតនឹងថយចុះ ហើយក៏នឹងរលត់ទៅទីបំផុត។

គំរូបែបនេះ កូនប្រហែលជាធ្លាប់បានឃើញខ្លះៗហើយ ដោយអ្នកខ្លះពីដើមជីវិតក្រលំបាកណាស់ ប៉ុន្តែដោយការព្យាយាម ធ្វើការងារ ចេះសន្សំ

www.elibraryofcambodia.org

ការប្រៀនប្រដៅគេចេះជួយដល់ខ្លួនឯងបានគ្រប់រឿង ហើយដោយយើងចាំឈរមើលគេពីចំងាយ ចាំណែនាំដល់គេ មិនមែនចាំគ្រប់គ្រងគេទេ នេះហើយជាការចិញ្ចឹមកូនឲ្យត្រឹមត្រូវនោះ។

កូនធ្វើអ្វីធ្វេសប្រហែសខុសឆ្គង ត្រូវឈឺខ្លួនប្រាណ ឬគេធ្វើអ្វីមិនត្រូវចិត្តយើងនោះ ក៏ត្រូវទ្រាំបន្តិចទៅ មិនយូរប៉ុន្មានគេអាចធ្វើជាម្ចាស់ការលើខ្លួនឯងបានហើយ ហើយការដែលជួយខ្លួនឯងបានទៅណាមកណា គឺយើងនឹងសប្បាយចិត្តលែងបារម្ភ។

បើសិនជាចិញ្ចឹមកូនតាំងពីទារក ឬទើបនឹងកើតវិញនោះ ដោយធ្វើអ្វីគ្រប់យ៉ាង គិតជំនួសគេគ្រប់រឿងគ្រប់យ៉ាង នាំផ្លូវគេគ្រប់រឿង មិនព្រមឲ្យធ្វើជាម្ចាស់លើខ្លួនឯង គិតតែខ្លាចគេពិបាក ខ្លាចធ្វើខុស បើសិនជាបែបនេះ តើពេលណាគេធំទៅ? ។

បើសិនកូនមិនចេះធំនោះ ទៅថ្ងៃអនាគតយើងនឹងអាចទុកចិត្តគេបានយ៉ាងម៉េចទៅ សូម្បីតែខ្លួនគេជួយខ្លួនឯងមិនបានផង តើអាចមកចិញ្ចឹមយើងបានយ៉ាងម៉េចទៅ? ។

www.elibraryofcambodia.org

# ២៨.ចិញ្ចឹមកូនឲធំ

កូនសម្លាញ់របស់ពុកម៉ែអើយ !

កូនបានចេញឃ្លាតពីដើមទ្រូងពុកម៉ែទៅហើយ កូនត្រូវមានគ្រួសារ និងមានកូនមានចៅដែលខ្លួនកូនជាអ្នកទទួលខុសត្រូវ កូនជាកែវភ្នែកទាំងគូរបស់ឪពុកម្តាយ ជាគ្រប់បែបយ៉ាងរបស់ឪពុកម្តាយ រឿងមួយនេះកូនក៏ប្រហែលជាយល់ច្បាស់ហើយ ទើបគួរតែចិញ្ចឹមកូនឲបានល្អ ឲគេមានអនាគត ដើម្បីយើងសប្បាយចិត្តទៅថ្ងៃអនាគត មិនចាំបាច់មកកើតទុក្ខពីព្រោះតែគេធ្វើមិនត្រូវ ឬមិនល្អនោះ។

ការចិញ្ចឹមកូនឲមានភាពត្រឹមត្រូវមាន២យ៉ាងគឺ ចិញ្ចឹមកូនឲធំ និងចិញ្ចឹមកូនឲល្អ ហើយការចិញ្ចឹមកូនឲធំ គឺជាការចិញ្ចឹមកូនឲរឹងមាំទាំងកាយ និងផ្លូវចិត្ត ប៉ុន្តែ ការចិញ្ចឹមកូនឲគេធំខាងរាងកាយរឹងមាំបានសុខសប្បាយនោះ មិនទាន់គ្រប់គ្រាន់នៅឡើយនោះទេ ត្រូវចិញ្ចឹមចិត្តរបស់គេឲមានភាពរឹងមាំផងដែរ បើសិនជាចិត្តរបស់គេមិនរឹងមាំ គេនៅតែជាកូនតាមឪពុកម្តាយមិនចេះធំ ទីពឹងខ្លួនឯងមិនបាន ធ្វើអ្វីមិនចេះរហូតទៅ។

ការបង្រៀនឲកូនធ្វើជាម្ចាស់ការលើខ្លួនឯង ត្រូវបង្រៀនឲគេជ្រើសរើស និងមានការសម្រេចចិត្តដោយខ្លួនឯង ឲគេចេះធ្វើអ្វីៗ ដោយការ

www.elibraryofcambodia.org

ឈប់គៀម ទៅមុនមិនបាននៅកន្លែងខ្លះ ធ្វើកិច្ចការ ឬការងាររូបប្លុះ រស់ក៏មានដែរ។

ដូច្នេះ បើសិនជាកូនប្រើអ្នកណា ប្រគល់ការងារឲ្យអ្នកណាធ្វើនោះ គួរតែពិចារណាឲ្យបានល្អ ដោយអ្នកណាក៏ដោយ ទោះបីជាមិនមែនជាគ្នារបស់យើងក៏ដោយ ឬចំណេះដឹងខ្ពស់ ប៉ុន្តែឲ្យតែមានបទពិសោធ និងការការទទួលខុសត្រូវ រកធ្វើការងារដែលកូនប្រគល់ឲ្យបានសម្រេចនោះ ក៏គួរតែប្រើគេ ប្រសើរជាងប្រើភ្នាក់ងារដែលមិនចេះធ្វើការ ដោយគ្រាន់តែគួរយកការងារមកប្រគល់ទៅជាមួយនឹងមនុស្សល្ងង់នោះទេ ពីព្រោះតែរកធ្វើធម្មតារបស់គួរតែបានរកពិចារណាប្រើនោះ ប្រាកដណាស់ក៏មានគេ កុំប្រថុយយកប្រសើរជាង។

www.elibraryofcambodia.org

# ២៩.ការចេះប្រើមនុស្ស

កូនសម្លាញ់របស់ពុកអើយ !

ការប្រគល់ឲមនុស្សទៅធ្វើការ ជាទូទៅគេហៅថា **ការប្រើមនុស្ស** ពីត្រូវតែមើលឲបានច្បាស់ជាមុនសិន ដោយមើលទាំងការងារ មើលទាំងមនុស្ស ហើយក៏ត្រូវប្រើមនុស្សឲសមនឹងការងារផងដែរ ហើយអ្នកណាមានជំនាញខាងណា មានបទពិសោធក្នុងការងារនោះយ៉ាងម៉េច រួមទាំងចំណេះដឹង ភាពទទួលខុសត្រូវ ការមានទំនុកចិត្តរបស់គេជាយ៉ាងណាត្រូវមើលឲបានច្បាស់។

បើសិនជាប្រើមនុស្សឲសមនឹងការងារ ការងារក៏ដំណើរការទៅបានយ៉ាងរលូនគ្មានរាំងស្ទះដែរ ហើយបើសិនជាប្រើមនុស្សមិនសមនឹងការទេ ប្រើមនុស្សដែលខ្វះគុណសម្បត្តិ ប្រើព្រោះតែយល់ដល់មុខគ្នា អ្នកប្រើដោយមិនបានពិចារណាឲបានច្បាស់លាស់ ក្រៅពីការងារដំណើរការមិនរលូនហើយ អាចធ្វើឲខាតបង់ទៀតផង។

មានតួរឲឃើញមិនតិចនោះទេ ដែលអ្នកធំជ្រើសរើសមនុស្ស និងប្រើមនុស្សមិនសមនឹងការងារ ប្រគល់ការងារដែលមានការប្រថុយប្រថានខ្ពស់ ទៅឲមនុស្សដែលគ្មានបទពិសោធធ្វើ ទើបធ្វើឲការងារទាំងនោះត្រូវ

www.elibraryofcambodia.org

អាចរិះគន់ជួប និងមិនធ្វើឲ្យអ្នកណាមានការទាស់ចិត្តជាទៀយ ដូចជា ក្នុងបន្ទប់ប្រជុំ អ្នកផ្សេងគេតាំងចិត្តស្តាប់ ប៉ុន្តែយើងគិតតែពីនិយាយរឿងធ្វើ ឲ្យអ្នករំខានដល់អ្នកដទៃ ហើយបើយើងប្រកបរបរ ឬជួសជុលអ្វីដែលរំខាន ដល់អ្នកជិតខាង ឬបន្ទប់ជិតខាង គឺគេនឹងធុញទ្រាន់ បែបនេះយើងគួរតែ គោរពការខ្លាចចិត្តគេ គួរប្រាប់គេផង បើសិនជាយើងត្រូវធ្វើនោះ។

ត្រូវគោរពការខ្លាចចិត្តរបស់គេឲ្យបានច្រើន បែបនេះ ទើបមិនមានរឿង ច្រើន ហើយកុំយកគំនិតពាក្យអ្នកដទៃ ជាពិសេសការនិយាយរឿងគេ គំនិតបែប នេះជាគំនិតរបស់មនុស្សអាត្មានិយម មិនគិតពីចិត្តអ្នកដទៃ ចូរតួរកុំគិត បែបនេះអី វាជារឿងគួរឲ្យខ្មាសគេខ្លាំងណាស់។

www.elibraryofcambodia.org

# ៣០.ការចេះក្រែងចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលដែលកូនចង់ធ្វើអ្វី មិនថា ធ្វើនៅក្នុងផ្ទះខ្លួនឯង ឬធ្វើនៅកន្លែងណាក៏ដោយ បើសិនជារឿងដែលធ្វើនោះ អាចធ្វើឲ្យអ្នកជិតខាងមានការទាស់ចិត្ត រំខានអ្នកដទៃនោះ កូនត្រូវតែប្រយ័ត្នប្រយែងផង កុំធ្វើអ្វីតាមតែអំពើចិត្ត ឬអាងសិទ្ធិថា អាចធ្វើបាន គួរណាតែខ្លាចចិត្តអ្នកដទៃខ្លះផង ដែលនៅផ្ទះជាប់គ្នា នៅបន្ទប់ជាប់គ្នា ឬនៅបន្ទប់តែមួយ ដោយការចេះខ្លាចគេខ្លាចឯងនេះហើយ ទើបមិនមានការឈ្លោះទាស់ទែងគ្នា និងពោងមិត្តប្រសើរជាងសត្រូវ។

បើសិនជាចាំបាច់ត្រូវធ្វើនោះ ក៏គួរតែប្រាប់ឲគេដឹងមុន ឬបើសិនជាសូមអនុញ្ញាតក៏កាន់តែល្អ ហើយគ្មានខាតបង់អ្វីទេ ពេលដែលយើងខ្លាចចិត្ត គេក៏ខ្លាចចិត្តយើង យល់ព្រមអនុញ្ញាត និងអត់ទ្រាំការរំខាន ឬទ្រាំពិបាកមួយរយៈបានផងដែរ។

រឿងនេះសូមឲកូនយកចិត្តគេមកដាក់ចិត្តយើងផង យល់ពីអារម្មណ៍របស់គេ យល់ពីអារម្មណ៍របស់ផង ដើម្បីកុំឲធ្វើអ្វីតាមតែអំពើចិត្ត ហើយសូមកូនចងចាំទុកទៅថា ការក្រែងចិត្តគេជាចរិតមួយថ្លៃថ្នូរ ជាមន្តស្នេហ៍

www.elibraryofcambodia.org

# ៣២.ការចេះចាត់ចែងពេលវេលា

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលវេលាដែលកន្លងហួសទៅនោះ មិនអាចហៅឲវិលត្រឡប់មកក្រោយបានវិញនោះទេ បើគិតជាកន្លងផុតទៅ គឺកន្លងផុតរហូតហើយ ប៉ុន្តែពេលវេលាដែលកន្លងផុតទៅនោះ មិនមែនកន្លងផុតទៅទទេៗទេ វាបាននាំជីវិតរបស់យើងឆ្លងកាត់ពេលវេលា ព្រមទាំងឆ្លងវ័យកាត់ទៅជាមួយគ្នា គឺជីវិតរបស់យើងចេះកន្លងផុតទៅ ដើរទៅមុខពុំអាចថយក្រោយនោះទេ។

មនុស្សឆ្លាត គេស្គាល់ពីតម្លៃពេលវេលាណាស់ ចេះប្រើពេលវេលាឲមានប្រយោជន៍ ទទួលបានផលសមនឹងតម្លៃ ដូចដែលបាននិយាយថា **ពេលវេលាជាមាសប្រាក់** ហើយពេលខ្លះ យើងមិនស្គាល់ពីតម្លៃរបស់ពេលវេលា ឬមិនចេះចាត់ចែងពេលវេលា ដោយពេលវេលាដែលកន្លងផុតទៅនោះ អាចជាការបាត់បង់ឱកាសដែលសំខាន់នៅក្នុងជីវិត ដែលយើងអាចទទួលបានការពិសោធន៍យ៉ាងមានតម្លៃចំពោះ ប៉ុន្តែយើងបណ្តោយឲកន្លងផុតទៅទទេៗ យើងគួរតែមានការសោកស្តាយ។

www.elibraryofcambodia.org

# ៣១.ពួកពូកែអុចអាល

កូនសម្លាញ់របស់ពុកម៉ែអើយ !

នៅក្នុងសង្គមរបស់យើងសព្វថ្ងៃនេះ មានមនុស្សមួយប្រភេទដែលចូលចិត្តនិយាយឲគេឈ្លោះគ្នា ឬក៏បំបែកបាក់គ្នា ហើយវាជាសេចក្តីសុខរបស់ពេលដែលឃើញអ្នកដទៃ ជឿតាមសម្តីរបស់គេនោះ។

ចាស់បុរាណហៅមនុស្សប្រភេទនេះថា មនុស្សពូកែញុះញង់ ឬពួកពូកែអុចអាល ដែលពួកទាំងនេះ ជាមនុស្សនាំសម្តីពីអ្នកនេះទៅប្រាប់អ្នកនោះ យកសម្តីពីអ្នកនោះមកប្រាប់អ្នកនេះ ដោយការនិយាយបំផ្លើសលើសពីការពិត ពិតខ្លះ មិនពិតខ្លះ ក៏ចេះតែថាទៅ។

មនុស្សដែលជឿសម្តីមនុស្សបែបនេះ តែងតែឈ្លោះគ្នា រេរាំងទ្រាំលើគ្នា ឬសម្លាប់គ្នារហូតក៏មានដែរ ដែលទាំងការពិតទាំងអស់នោះ មិនពិតដូចជាគេនិយាយនោះទេ ដូនេះ ទើបត្រូវប្រយ័ត្នប្រយែងមនុស្សប្រភេទនេះ កុំទៅជឿសម្តីរបស់គេងាយៗ ធ្វើចិត្តឲធ្ងន់ស្តាប់ម្ខាងទុកម្ខាង ទើបល្អ។

អ្នកណាមកនិយាយរឿងអ្នកនោះ អ្នកនេះឲស្តាប់ ក៏ស្តាប់ទៅ មិនគួរទៅនាំចាក់ឫស ចាក់គល់ ឬក៏មកយកទុកក្នុងចិត្តទេ យើងអាចឆ្លុតជាមួយគេដែរ ហើយការដែលសំខាន់ជាងគេ គឺយើងត្រូវប្រយ័ត្នខ្លួន កុំក្លាយជាមនុស្សអុចអាល ឬជាពួកញុះញង់ដោយខ្លួនឯង។

www.elibraryofcambodia.org

# ៣៣.មន្តគាថាបន្ទន់ចិត្ត

កូនសម្លាញ់របស់ពុកប៉ែររីរេ !

**«រស់នៅគេស្រឡាញ់ ចាកចេញគេអាឡោះអាល័យ រស់នៅគេទុកចិត្ត ចេញទៅគេនឹកអាល័យ»** សម្តីទាំងនេះជាមន្តគាថាបន្ទន់ចិត្តសម្រាប់ធ្វើមនុស្សម្នាទៅបានការគាប់អារម្មណ៍។

យើងនៅទីណា នៅជាមួយអ្នកណា ធ្វើការនៅទីណា ធ្វើការជាមួយអ្នកណា ? ល្អ ឬអាក្រក់យ៉ាងណាក៏ដោយ រឿងទីមួយដែលយើងត្រូវធ្វើនោះ គឺធ្វើឲ្យគេពេញចិត្ត កុំទៅបង្ករឿងស្មុគស្មាញ កុំបង្កផលពិបាកដល់អ្នកដែលយើងនៅជាមួយ ឬធ្វើការជាមួយគ្នានោះ។

បើសិនជាយើងធ្វើឲ្យគេពេញចិត្តចំពោះយើងបានហើយនោះ យើងក៏អាចនៅកន្លែងសុខស្រួល មានតែមនុស្សស្រឡាញ់ ពេញចិត្ត គ្មានការព្រួយនោះឡើយ ប៉ុន្តែផ្ទុយទៅវិញ បើសិនជាយើងបង្កផលពិបាកដល់គេវិញនោះ ក៏មានតែមនុស្សស្អប់ខ្ពើម នៅមិនបានសុខឡើយ ហើយវិធីធ្វើឲ្យគេមានចំណាប់អារម្មណ៍មកលើយើង គឺជាការលះបង់ មិនមើលតែបាននិយាយស្តីល្អទៅ តែជួយដល់គេ មិនចេះប្រកាន់ខ្លួនចំពោះគ្រប់គ្នា ចេះប្រមាណខ្លួន មានចរិតសុភាពរាបសា មានភាពថ្លៃថ្នូរ។

www.elibraryofcambodia.org

មនុស្សគ្រប់គ្នាមានពេលវេលា និងបានពេលវេលាស្មើៗគ្នាទាំងអស់ មិនថាជាម៉ោង ជាថ្ងៃ ឬជាខែ សុទ្ធតែទទួលបានដូចគ្នា គ្មានអ្នកណាបានពេលវេលាពិសេសជាងអ្នកណានោះទេ ដូច្នេះ ទើបស្ថិតនៅលើអ្នកណាចេះប្រើពេលវេលា និងចាត់ចែងពេលវេលាបានជាងប៉ុណ្ណោះ ហើយក៏មានឱកាសទទួលបានជោគជ័យសមតាមបំណងប្រាថ្នាច្រើនជាងអ្នកដទៃ។

ពេលវេលាដែលមានតម្លៃ ទើបគួរប្រើឲសមនឹងតម្លៃ ហើយប្រើឲមានប្រយោជន៍ដល់ខ្លួនឯងច្រើនបំផុតតាមដែលអាចធ្វើទៅបាន ហើយនៅក្នុងផ្លូវព្រះពុទ្ធសាសនាលោកបានប្រៀនប្រដៅថា **កុំឲពេលវេលាកន្លងហួសទៅដោយឥតប្រយោជន៍ ឆាប់ធ្វើរឿងដែលគួរធ្វើនៅថ្ងៃនេះទៅ** ទាំងនេះជាការណែនាំឲចេះចាត់ចែងពេលវេលានោះហើយ។

www.elibraryofcambodia.org

# ៣៤.ការដែលប្រកាន់ខ្លួន

កូនសម្លាញ់របស់ពុកម៉ែអើយ !

ភាពប្រកាន់ខ្លួន មានន័យថា យកខ្លួនឯងទៅប្រៀបធៀបជាមួយអ្នកដទៃ ឬយកអ្នកដទៃមកប្រៀបធៀបជាមួយយើង ដោយភាពប្រកាន់ខ្លួនមាន៣ យ៉ាងគឺ ការគិតថាខ្លួនឯងល្អជាអ្នកដទៃ គិតថាខ្លួនឯងអន់ជាងអ្នកដទៃ និងគិតថាខ្លួនឯងស្មើជាមួយអ្នកដទៃ។

គំនិតទាំង៣នេះ សុទ្ធតែមិនល្អទាំងអស់ ពីព្រោះបើសិនគិតថា ខ្លួនឯងពូកែជាងអ្នកដទៃ អាចធ្វើឲបានអំនួតថា អ្នកដទៃមិនអាចប្រៀបជាមួយខ្លួនបាន និងធ្វើឲបានការក្រអឺតក្រទម ធ្វើអ្វីតាមតែអំពើចិត្ត និងបង្ហាញអាកប្បកិរិយា ឬការមើលស្រាលចំពោះអ្នកដែលអន់ជាង ក្លាយទៅជាមនុស្សក្អេងក្អាងបានយ៉ាងងាយណាស់។

បើសិនជាគិតថាខ្លួនឯងអន់ជាអ្នកដទៃ អាចធ្វើឲយើងមានអារម្មណ៍ថា អ្នកដទៃល្អជាងខ្លួនរបស់យើង ធ្វើឲមានការរាក់រន់ចិត្ត មានការអស់សង្ឃឹម មិនគិតខំស្វះស្វែង បណ្តោយបណ្តែតជីវិតទៅតាមយថាកម្ម អ្នកណាមើលស្រាលក៏មើលទៅ ហើយបើសិនគិតថាខ្លួនឯង ស្មើភាពជាមួយអ្នកដទៃ អាចធ្វើឲយើងមានការភ្លើតភ្លើន មិនខ្វល់ពីអ្នកណា ហើយក៏

បើសិនជាធ្វើបែបនេះបាន ចង់ទៅនៅកន្លែងណាក៏ដោយ ក៏អាចនៅបានដែរ ធ្វើការនៅកន្លែង ក៏អាចធ្វើបានផងដែរ ហើយដល់ពេលដែលបែកគ្នា គេក៏នឹកស្រណោះ ដូចជាពាក្យថា នៅឲគេស្រឡាញ់ ចាកចេញឲគេនឹករឭឡោះអាល័យ និងដោយអ្វីដែលសំខាន់នោះ គឺយើងបានមិត្តភ័ក្តិដែលមានភាពស្មោះត្រង់ បើសិនយើងជាមនុស្សមានចិត្តចង្អៀតចង្អល់មិនចេះលះបង់ យើងក៏ពិបាករស់នៅជាមួយ និងគ្មានមិត្តភ័ក្តិស្មោះត្រង់ដែរ។

www.elibraryofcambodia.org

# ៣៥.អ្នកដែលស្រឡាញ់យើងស្មោះ

កូនសម្លាញ់របស់ពុកម៉ែអើយ !

អ្នកដែលស្រឡាញ់យើងស្មោះ ឬក៏មិនស្មោះនោះ កុំមើលតែលើសម្ដីរបស់គេចេញពោះ ដោយសារពាក្យសម្ដីគ្រាន់ជាខ្យល់បញ្ចេញដែលអាចប្រែប្រួលនៅពេលណាក៏បានដែរ អ្នកដែលនិយាយថាស្រឡាញ់យើង ពេញចិត្តយល់ស្ដីយើង ឬគោរពចំពោះយើងនោះ អាចគ្រាន់តែជាពាក្យសម្ដីធ្វើឲ្យយើងជឿជាក់ទុកចិត្តប៉ុណ្ណោះ ចិត្តរបស់គេអាចស្អប់យើងក៏ថាបាន ព្រោះតែផលប្រយោជន៍អ្វីមួយ ទើបធ្វើឲ្យគេនិយាយបែបនោះ។

អ្នកដែលមិនធ្លាប់និយាយថា ស្រឡាញ់យើងស្មោះនោះ ក៏មិនមែនគេមិនស្មោះចំពោះយើងក្នុងពេលនោះ គេអាចជាមនុស្សដែលស្រឡាញ់យើងពិតប្រាកដ មានភាពស្មោះត្រង់ចំពោះយើងក៏ថាបាន ប៉ុន្តែក៏មិនមែនមានន័យថា អ្នកដែលប្រាប់ថាស្រឡាញ់យើងនោះ មិនស្រឡាញ់យើងស្មោះនោះទេ អ្នកមិនដែលប្រាប់ថាស្រឡាញ់ចំពោះយើងនោះ គេស្រឡាញ់យើងស្មោះនោះដែរ គឺគ្រាន់តែចង់ប្រាប់ថា អ្នកណាស្រឡាញ់យើង ឬមិនស្រឡាញ់យើង មិនមែនស្ថិតលើពាក្យសម្ដី មិនមែនស្ដាប់តែគេនិយាយទេ ដោយស្ថិតនៅលើទង្វើ ស្ថិតលើការសម្ដែងចេញរបស់គេដែរ ត្រូវមើល

www.elibraryofcambodia.org

មិនព្រមស្តាប់សម្តីរបស់អ្នកណាដែរ ពីព្រោះអាចថាខ្លួនឯងស្មើភាពជាមួយអ្នកដទៃ អ្នកដទៃក៏ដូចជាគេដែរ អ្នកដទៃគ្មានអ្វីអស្ចារ្យជាងគេនោះទេ ដោយគំនិតបែបនេះមិនល្អទាំងអស់។

យល់ល្អ មនុស្សយើងគួរតែមានការគោរព ស្តាប់តាម ឱនលំទោន យល់ព្រម និងប្រតិបត្តិចំពោះគ្នាតាមទម្លាប់ដែលសក្តិសម ដល់ពេលដែលគោរពក៏គោរព ដល់ពេលឱនលំទោនក៏ឱលំទោន ដល់ពេលគួរព្រមក៏គួរព្រមទៅ ហើយដល់ពេលណាដែលរឹងក៏រឹង មានការសម្របខ្លួនឲ្យត្រូវជាមួយនឹងស្ថានការណ៍ និងបុគ្គលដទៃ បើសិនជាបានពិតល្អណាស់។

អ្នកដែលវៃឆ្លាតនៅក្នុងការសម្របខ្លួន គេហៅថា ជាមនុស្សដែលធ្វើខ្លួនបានសមរម្យ អាចចងចិត្តអ្នកនៅក្បែរខ្លួនបាន។

www.elibraryofcambodia.org

# ៣៧. យឺតជាការ យូរជាគុណ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានពាក្យស្លោកមួយទៀតសម្រាប់ដាស់តឿនដល់ចិត្តអ្នកធ្វើការថា **យឺតជាការ យូរជាគុណ** នេះមានន័យថា ការងារប្រភេទខ្លះ ត្រូវធ្វើដោយមានភាពល្អិតល្អន់ ត្រូវធ្វើតាមសម្រួល ប្រញាប់ធ្វើមិនបានទេ ពីព្រោះបើសិនណាជាប្រញាប់នោះអាចធ្វើខុសឆ្គង ឬខាតបង់ការ ដោយត្រូវតែធ្វើទៅតាមសន្សឹមៗ និងត្រូវរង់ចាំពេលវេលា ដែលការងារខ្លះត្រូវតែរង់ចាំពេលវេលាស្ថិតនៅលើពេលវេលា និងមានការកំណត់ពេលវេលាទុក។

**ឧទាហរណ៍** ដូចជានៅពេលដែលឈឺក្ដៅ គ្រូពេទ្យប្រាប់ថា ត្រូវតែសម្រាក ហាមធ្វើការធ្ងន់ ហាមធ្វើដំណើរប៉ុន្មានថ្ងៃ យើងត្រូវតែសម្រាកត្រូវលះបង់ទៅតាមនោះ ទោះបីជាពេលនេះយើងមានអារម្មណ៍ថា ស្រួលខ្លួនវិញហើយក៏ដោយ អាចធ្វើបាន ធ្វើដំណើរបាន ក៏ត្រូវតែរង់ចាំដល់គ្រប់ពេលកំណត់ដែរ ហើយបើសិនយើងមានះចង់ទៅធ្វើការធ្ងន់ ឬធ្វើដំណើរនោះ អាចមានផលប៉ះពាល់ដល់សុខភាពបាន ជំងឺឈឺក្ដៅអាចនឹងត្រឡប់មកវិញ ឬអាចធ្ងន់ជាងមុនទៀតក៏ថាបាន ដោយចាំបន្តិច យឺតបន្តិច ក៏គ្រាន់តែហាក់ជាមិនធ្វើរួចការប៉ុន្មាននោះទេ ប៉ុន្តែផ្ទុយទៅវិញ គឺធ្វើឱ្យមានផល

www.elibraryofcambodia.org

អ្នកដែលធ្វើការគោរពពេលវេលាបាន គេតែងតែមានប្រៀបជាងអ្នកដទៃណាស់ ដោយការងារដូចគ្នា ធ្វើព្រមគ្នា អ្នកខ្លះធ្វើហើយលឿន អ្នកខ្លះធ្វើហើយយឺត នោះមកពីការចាត់ចែងពេលវេលាមិនបានល្អនេះហើយ។

សូមបញ្ជាក់ឲកូនឃើញពីភាពសំខាន់របស់ពេលវេលាម្តងទៀតថា មាសប្រាក់នោះបាត់បង់ហើយ អាចរកមកវិញបាន ប៉ុន្តែបើសិនពេលវេលាកន្លងហួសហើយ មិនអាចហៅមកវិញមិនបានទេ ទោះបីជាមានពេលក្រោយទៀត ក៏ជាពេលវេលានៃថ្ងៃថ្មីដែរ ហើយវាដែលគួរជាពេលវេលាធ្វើការអ្វីផ្សេងៗ ប៉ុន្តែ បែរជាប្រើពេលវេលាថ្មីនោះ ធ្វើការចាស់ទៅវិញ នោះក៏មានឈ្មោះថា ខាតដើមទុនពេលវេលាទៅហើយ។

www.elibraryofcambodia.org

# ៣៨.ចិត្តដែលស្រស់ស្អាត

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សយើង ទោះបីជាមានរូបសម្បត្តិមិនស្អាតកុំរន្ធត់ចិត្ត ពីព្រោះតែរូបរាងជារឿងក្រៅពីសមត្ថភាពរបស់យើង កើតមកជាបែបណា គឺបែបនោះហើយ ពិបាកនឹងប្រែប្រួលណាស់ ទោះបីជាពុកតែងតែអធិស្ឋានយ៉ាងណាក៏ឲ្យដូចដែលត្រូវការនោះមិនបានដែរ ដោយបើសិនជារូបសម្បត្តិរបស់យើងមិនស្អាត យើងអាចសាងភាពស្រស់ស្អាតម្យ៉ាងទៀតបាន គឺសាងចិត្តឲ្យស្រស់ស្អាត ពីព្រោះតែភាពស្រស់ស្អាតមាន២យ៉ាងគឺ ស្អាតខាងក្រៅ និងស្អាតខាងក្នុង។

ស្អាតខាងក្រៅ គឺជារូបសម្បត្តិស្អាត ហើយស្អាតខាងក្នុង គឺជាចិត្តស្អាត ដោយរូបរាងជារឿងរបស់បុណ្យកាលពីអតីតជាតិ និងចំណែកចិត្តដែលស្អាតជារឿងបុណ្យថ្មី អាចធ្វើឲ្យកើតមានឡើងដោយខ្លួនឯងបាន។

កើតមកជាមនុស្ស ទោះបីជារូបសម្បត្តិមិនស្អាត ក៏កុំធ្វើជាមនុស្សមានចិត្តមិនស្អាតទៅតាមដែរនោះ នឹងគ្មានអ្វីល្អនោះទេ ធ្វើខ្លួនជាមនុស្សដែលមានចិត្តល្អទៅ ដោយមនុស្សចិត្តល្អ ជាមនុស្សដែលមានចិត្ត មានចិត្តទន់ភ្លន់, ចេះយល់ចិត្តយល់ថ្លើមអ្នកដទៃ មិនប្រកាន់ពេលដែលអ្នក

www.elibraryofcambodia.org

ល្អដល់ខ្លួនឯង និងធ្វើឲ្យជាសះស្បើយពីជំងឺបានទៀតផង ដោយសារតែហេតុនេះហើយ ទើបលោកដាស់តឿនសតិថា ទោះបីជាយឺតក៏ត្រូវយឺត ដល់ពេលចាំក៏ត្រូវតែចាំ ដល់ពេលប្រញាប់ក៏ត្រូវតែប្រញាប់។

ពេលខ្លះ យើងអាចកើតមានការរំខាន ដោយពេលឃើញអ្នកដទៃធ្វើការយឺតយ៉ាវមិនទាន់ចិត្ត ប៉ុន្តែយើងមិនអាចដឹងថា ការងារដែលគេកំពុងធ្វើនោះ ជាការងារដែលប្រើពេលវេលាដើម្បីពិចារណា គិតឲ្យច្បាស់លាស់ កុំឲ្យមានការភ្លេះភ្លាយ ទើបគេធ្វើតាមសន្សឹមៗ ដោយគិតថា យឺតជាការយូរជាគុណ ដែលគួរឲ្យយកធ្វើជាគំរូណាស់។

www.elibraryofcambodia.org

# ៣៩.ភាពស្មោះត្រង់

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលដែលកូនធ្វើជាមន្ត្រីរាជការ រឿងដំបូងដែលកូនគួរស្គាល់ឲ្យច្បាស់គឺ ភាពស្មោះត្រង់ចំពោះថៅហ្វាយនាយ ដោយរឿងនេះសំខាន់ខ្លាំងណាស់ ភាពស្មោះស្ម័គ្រ ភាពស្មោះត្រង់ ជាគុណធម៌ដ៏ល្អ ហើយជារឿងដែលមន្ត្រីរាជការគួរតែមាន ហើយមន្ត្រីរាជការដែលមានភាពស្មោះត្រង់ គឺចាត់ទុកថា ជាមន្ត្រីរាជការដែលល្អ ប៉ុន្តែបើស្មោះត្រង់ជាមួយថៅហ្វាយទៀតនោះ ក៏កាន់តែល្អប្រសើរ។

ភាពស្មោះត្រង់ចំពោះកិច្ចការនោះ ជារឿងរបស់តួនាទី ជារឿងដែលត្រូវតែមាន ត្រូវតែធ្វើ ដោយភាពស្មោះត្រង់ជារឿងខាងផ្លូវចិត្ត រឿងហួសពីតួនាទី ហើយបង្ខំគ្នាធ្វើមិនបានទេ។

ពេលដែលកូនធ្វើការជាមួយអ្នកណា បើគេជាថៅហ្វាយដ៏ល្អ មានមេត្តាធម៌ករុណា ជាមនុស្សចាស់ដែលគួរឲ្យគោរពបានហើយល្អនោះ ក៏សូមឲ្យកូនមានភាពស្មោះត្រង់ ទៀងត្រង់សុចរិត ព្រមប្រគល់បំពេញតួនាទីបម្រើគេឲ្យបានល្អទៅ ហើយច្បាស់ជាមិនខកបំណងនោះទេ។

www.elibraryofcambodia.org

ដទៃធ្វើខុស មិនចេះខឹងពេលដែលអ្នកដទៃមកប៉ះពាល់ មិនយករឿងឥតប្រយោជន៍មកគិត កាត់ចិត្តបាន មិនគិតព្យាបាទ ហើយក៏មិនយករឿងអាក្រក់របស់អ្នកដទៃមកនិយាយដើមលេងដែរ។

សូមបងប្អូនដឹងថា រូបសម្បត្តិស្អាតទាក់ទាញភ្នែក ហើយចិត្តស្រស់ស្អាតទាក់ទាញចិត្ត ដោយរូបសម្បត្តិស្រស់ស្អាតនៅបានមួយគ្រាប៉ុណ្ណោះ ប៉ុន្តែចិត្តដែលស្រស់ស្អាតនៅបានរហូតទៅ។

www.elibraryofcambodia.org

# ៤០.សុខភាពរាងកាយ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សយើងគ្រប់រូបសុទ្ធតែចង់បានអាយុវែង និងគ្មានរោគាពាធជួបគ្នាទាំងអស់ ប៉ុន្តែការដែលអាយុវែង គ្មានរោគាពាធបាននោះ ភាគច្រើនកើតពីការថែរក្សាសុខភាពបានល្អ មិនមែនត្រូវការហើយ ទើបរកពេទ្យសុខភាពទៅតាមក្រោយនោះទេ ដោយអ្នកដែលបានថែរក្សាសុខភាពរាងកាយបានល្អ តែងតែមានឱកាសមានអាយុវែង ហើយគ្មានរោគាពាធច្រើនជាងមនុស្សមិនចេះថែរក្សាសុខភាពរបស់ខ្លួន។

កូនក៏ត្រូវតែប្រកាន់ភ្ជាប់ពីសុខភាពល្អផង ថែរក្សាសុខភាពបានល្អ គឺប្រឹងធ្វើការឲ្យទៀងពេល ដល់ថ្នាក់រាងកាយមិនបានសម្រាក កុំបណ្ដោយឲ្យរាងកាយស្រុតស្រោម ឬតម្រូវស្រួលហួសប្រមាណពេក ក៏ព្រោះវាអាចធ្វើឲ្យកើតរោគាពាធដោយងាយ បើសិនកើតហើយពិបាកនឹងព្យាបាលណាស់។

នៅក្នុងរឿងការថែរក្សាសុខភាពនេះ ធ្វើតាមគ្រូពេទ្យណែនាំទៅចុះណាកូន ដូចជាញ៉ាំអាហារណាដែលមានប្រយោជន៍ ហាត់ប្រាណ តែងនៅទីកន្លែងមានខ្យល់អាកាសល្អ រក្សាចិត្ត និងអារម្មណ៍ឲ្យស្រស់ថ្លា មិនត្រូវស្មុគស្មាញខ្លាំង មិនធ្វើការធ្ងន់ពេក មិនផឹកស្រា មិនសេពគ្រឿងញៀន ។ល

អ្នកដែលបដិបត្តិតួនាទីដោយភាពសុចរិត ទៀងត្រង់ និងស្មោះត្រង់នោះ ទោះបីទៅដល់ទីណាក៏មិនស្លាប់ និងមានអ្នកដែលគោរពស្រឡាញ់រាប់អាន យល់ព្រមគាំទ្រធ្វើការងារធំជាមិនខាន។

www.elibraryofcambodia.org

# ៤១.សុខភាពផ្លូវចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលដែលនិយាយអំពីរឿងសុខភាព យើងតែងតែគិតដល់សុខភាពរាងកាយ គិតតែពីភាពរឹងមាំ ភាពគ្មានរោគាពាធរបស់រាងកាយ ប៉ុន្តែតាមការពិតទៅ សុខភាពភាពផ្លូវចិត្តក៏សំខាន់ដូចជាសុខភាពរាងកាយផងដែរ ចិត្តដែលមានសុខភាពល្អ ក៏ស្រស់ថ្លា សប្បាយរីករាយមិនធុញថប់ មិនតប់ប្រមល់ ហើយមិនតឹងតែងសង្កត់ ដែលនៅក្នុងសម័យនេះគេហៅថា មិនស្មុគស្មាញ រក្សាសុខភាពចិត្តឲ្យល្អ ទើបជាការចាំបាច់ណាស់។

សុខភាពផ្លូវចិត្តអាចល្អប្រសើរឡើងបាន លុះត្រាតែយើងរក្សាសតិអារម្មណ៍ឲ្យបានល្អ កុំធ្វើឲ្យខូចអារម្មណ៍ ហើយរឿងដែលធ្វើឲ្យខូចអារម្មណ៍ច្រើនណាស់ អាចឆ្លងកាត់តាមភ្នែក តាមត្រចៀក តាមគំនិតគិតអានដែរ។ មួយថ្ងៃៗ មនុស្សយើងតែងតែទទួលបានអារម្មណ៍អាក្រក់ៗ យកមកដាក់ក្នុងចិត្តច្រើនរាប់មិនអស់ ហើយការសន្សំម្តងបន្តិចៗរហូតក្លាយជាគំនរសំរាមខាងផ្លូវអារម្មណ៍ដែលដក់ជាប់ក្នុងចិត្ត។

អ្នកដែលមានគំនរសំរាមអារម្មណ៍នៅច្រើន គឺសុខភាពផ្លូវចិត្តក៏ខូចទៅតាមដែរ អ្នកដែលមានសុខភាពផ្លូវចិត្តខូចច្រើន ឧស្សាហ៍ឆាប់ខឹង តប់

www.elibraryofcambodia.org

មិនឧស្សាហ៍អត់ងងុយ ជាដើម ហើយបើសិនធ្វើបាន សុខភាពរាងកាយក៏រឹងមាំ ទប់ទល់ជាមួយរោគាពាធបាន និងមានអាយុវែងថែមទៀតផងដែរ។

មនុស្សយើងបើសិនមានសុខភាពល្អ ក៏ស្មើនឹងមានដើមទុនក្នុងការពប្រង់ជីវិតដែលអាចធ្វើអ្វីបានដោយខ្លួនឯងផ្ទាល់ រហ័សរហួន រាងរៃ ពេនភាពងាយស្រួលក្នុងការប្រកបរបររកស៊ីណាស់ ហើយបើសិនជាសុខភាពរាងកាយទ្រុឌទ្រោម ទន់ខ្សោយ មួយថ្ងៃកាត់មួយថ្ងៃកោរនោះ ក៏ស្មើនឹងមានឧបសគ្គដ៏ធំ មិនអាចតស៊ូជាមួយការងារបានទេ ដោយពេលខ្លះ ធ្វើឲមានការរាថយ អស់សង្ឃឹម គ្មានកម្លាំងតស៊ូនៅក្នុងជីវិតបាន ដូច្នេះ ចូរក្សាសុខភាពឲបានល្អទៅកូន ពីព្រោះអាចធ្វើអ្វីៗល្អបានច្រើនណាស់។

www.elibraryofcambodia.org

# ៤២.បរិស្ថាន

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សយើងក្រៅពីការថែរក្សាសុខភាពផ្លូវចិត្តបានល្អហើយ បរិស្ថាន ក៏ជារឿងសំខាន់ផងដែរ ដែលយើងត្រូវយកចិត្ត និងចាត់ការល្អ ពីព្រោះតែបរិស្ថាននឹងធ្វើឲ្យយើងមានសុខភាពកាយ និងចិត្តរបស់យើងល្អ ទៅតាមនោះដែរ។

បរិស្ថានដែលកើតឡើងតាមធម្មជាតិ ដូចជា ដើមឈើ ភ្នំ ទន្លេ អាកាសធាតុ និងដែលយើងបានសាងសង់ឡើង ដូចជាទីកន្លែងស្នាក់នៅតុបតែងបរិវេណផ្ទះ ព្រមទាំងរបស់ដែលរៀបចំផ្សេងៗ ដោយបរិស្ថានទាំងអស់នេះ សុទ្ធតែផ្ដល់ប្រយោជន៍ ឬផលវិបាកដល់យើងទាំងអស់គ្នា បើសិនជាយើងមើលថែទាំវាបានល្អ ក៏ផ្តល់ផលប្រយោជន៍ដល់យើង ប៉ុន្តែបើសិនជាយើងមើលថែទាំវាមិនបានល្អ ក៏ផ្តល់ផលវិបាកវិញដែរ។

ដូច្នេះហើយ កូនត្រូវតែមើលថែ រក្សាបរិស្ថានឲ្យបានល្អ ដើម្បីជាប្រយោជន៍ដល់កូន និងគ្រួសារជុំវិញខ្លួនកូន ដោយចាប់ផ្តើមពីកន្លែងស្នាក់នៅអាស្រ័យ បន្ទប់គេង ផ្ទះបាយ បន្ទប់ទឹក មើលដុសលាងសម្អាត កុំឲ្យមានក្លិន ពីព្រោះវាជាទីកន្លែងសម្បូរទៅដោយមេរោគ ហើយបរិវេណផ្ទះមើល

www.elibraryofcambodia.org

ប្រមល់ នឹងក្លាយជាមនុស្សមានអារម្មណ៍ឆេវឆាវដោយមិនដឹងខ្លួន ហើយ វិធីការពារកុំឲសុខភាពផ្លូវចិត្តខូចគឺ កុំទៅធ្វើដឹង ធ្វើឮ ជាមួយរឿងរ៉ាវខាងក្រៅច្រើនពេក បើសិនជាដឹងហើយ កុំយកមកទុកក្នុងចិត្ត ក្នុងអារម្មណ៍ច្រើនពេក ដឹងក៏ធ្វើជាមិនដឹងខ្លះទៅ ឃើញក៏ធ្វើជាមិនឃើញខ្លះទៅ។

ភ្នែកធ្វើមិនឃើញ ត្រចៀកធ្វើមិនឮខ្លះទៅ ដែលធ្វើដូចជាពាក្យចាស់ពោលថា **បិទភ្នែកទាំងគូរ បិទត្រចៀកទាំងពីរ បិទមាត់ខ្លះទៅ អាចនៅបានស្ងប់** ក៏ថាបានដែរ ហើយបើសិនធ្វើដូច្នេះបាន ចិត្តប្រាកដជាសប្បាយ ពីព្រោះតែគ្មានជាតិពុល អារម្មណ៍ខាងក្រៅមិនអាចធ្វើអ្វីមកលើយើងបាននោះទេ ដោយសារយើងមិនខ្វល់យកវាមកគិត សុខភាពក៏ល្អ ពីព្រោះមិនស្មុគស្មាញ មិនខ្វល់ពីអ្វីទាំងនោះ។

www.elibraryofcambodia.org

# ៤៣.ភាពកតញ្ញូជាថ្នាំប៉ូវកម្លាំង

កូនសម្លាញ់របស់ពុកម៉ែអើយ !

ឪពុកម្ដាយទាំងឡាយ តែងតែមានក្ដីប្រាថ្នាចង់ឃើញកូនរបស់ខ្លួន ជាមនុស្សល្អ មានសេចក្ដីសុខ មានភាពរីកចម្រើន ពិសេសក្នុងមុខរបរ និង ពេលដែលឃើញរបស់កូនទទួលបានជោគជ័យ រស់នៅប្រកបដោយសេចក្ដីសុខហើយនោះ ឪពុកម្ដាយក៏សប្បាយចិត្តតែងព្រួយបារម្ភផងដែរ។

ប៉ុន្តែនោះគ្រាន់តែជាការសប្បាយចិត្ត មិនមែនជារបស់ដែលធ្វើឲ្យពួកគាត់មានចិត្តសោមនស្សរីករាយនោះទេ ដោយរបស់ដែលប៉ូវកម្លាំង ឬថ្នាំប៉ូវនោះ ដែលធ្វើឲ្យឪពុកម្ដាយគ្រប់រូប ចង់មានជីវិតរស់នៅដើម្បីនៅមើលកូនចៅរបស់ខ្លួនបានយូរនោះ គឺជាភាពកតញ្ញូដែលកូនមានចំពោះឪពុកម្ដាយតែមួយប៉ុណ្ណោះ។

កូនដែលទទួលបានភាពជោគជ័យរីកចម្រើន មានកិត្តិយស មានមុខមាត់នៅក្នុងសង្គម សង្គមមានការកោតសរសើរ បើសិនជាកូននោះ គ្មានភាពកតញ្ញូចំពោះឪពុកម្ដាយរបស់ខ្លួនទេ ឪពុកម្ដាយរបស់គេក៏មិនសូវសប្បាយចិត្តប៉ុន្មានដែរ ហើយចំពោះកូនដែលក្រីក្រ ប៉ុន្តែមានភាពកតញ្ញូ

www.elibraryofcambodia.org

ថែឲ្យបានស្អាត ដោយដាំដើមឈើ ដាំផ្កា ដើម្បីឲ្យត្រជាក់ កម្ចាត់ទីជម្រករបស់មូស បោះសំរាមចោលឲ្យស្រួលបួល ឬមិនត្រូវបោះរបស់កខ្វក់ចូលទៅក្នុងទឹកទន្លេ បឹងបួរជាដើម ព្រមទាំងមិនធ្វើអ្វីដែលបង្កឲ្យមានជាតិពុល ពីព្រោះវាអាច ឲ្យមានផលប៉ះពាល់ដល់អ្នកដទៃ។

ការមើលថែរក្សា កែលំអបរិស្ថានឲ្យបានល្អ ហើយមិនធ្វើឲ្យបរិស្ថានខូចខាត សុទ្ធតែជាប្រយោជន៍ចំពោះខ្លួនរបស់យើងទាំងអស់ ហើយពេលណាតែបរិស្ថានបានល្អ ផ្ទះក៏គួរចង់រស់នៅ បរិវេណជុំវិញផ្ទះក៏ស្រស់ស្អាត តាមដងផ្លូវក៏ត្រជាក់ ទន្លេ ស្ទឹង បឹងបួក៏ស្រស់ស្អាត ទីក្រុងក៏គ្មានជាតិពុលអ្វីដែរ វាជារឿងល្អទាំងអស់។

ផ្ទុយទៅវិញ បើសិនយើងមិនការពារមើលថែបរិស្ថានឲ្យបានល្អនោះ អានតែបំផ្លាញបរិស្ថានល្អៗចោលរាល់ថ្ងៃ យើងប្រាកដជាទទួលរងផលប៉ះពាល់យ៉ាងពិតប្រាកដ ពីព្រោះតែបរិស្ថានដាក់ទោសដល់ខ្លួនយើង។

www.elibraryofcambodia.org

# ៤៤. សម្បត្តិរបស់អ្នកថ្លៃថ្នូរ

កូនសម្លាញ់របស់ពុកម៉ែអើយ !

បើសិនជាយើងនៅក្នុងសង្គម ការគិតចំពោះអ្នកដទៃ ការធ្វើខ្លួន ការនិយាយស្តី រួមទាំងដល់ការតុបតែងខ្លួនល្អទៀតផង ជារបស់ដែលចាំបាច់ណាស់ ពីព្រោះវាជាការបញ្ជាក់ថា យើងជាមនុស្សថ្លៃថ្នូរ មានការអប់រំមកយ៉ាងល្អ ទើបបង្ហាញអាកប្បកិរិយាចេញមកល្អដូចគេបានឃើញ ដោយអ្នកប្រភេទនេះគេហៅថា **មនុស្សមានសម្បត្តិអ្នកថ្លៃថ្នូរ** ហើយអ្នកដែលមានសម្បត្តិថ្លៃថ្នូរបែបនេះ តែងតែមានរបៀបជាងមនុស្សគ្រប់គុណភាពសម្បត្តិទាំងអស់នេះ ដោយគេទាំងនៅក្នុងគ្រប់រឿង ទាំងការគោរពរាប់អាន និងការស្និទ្ធស្នាល ព្រមទាំងទៅដល់ការទុកចិត្តប្រគល់តួនាទីការងារសំខាន់ឲ្យធ្វើទៀតផង !

**សម្បត្តិថ្លៃថ្នូរ** គឺជាការបង្ហាញអាកប្បកិរិយាដែលមានសុភាពរាបសាចេញមក គួរឲ្យគេមានការទាក់ទាញភ្នែក មិនមើលស្របុះភាព ហើយព្រមទាំងពោរពេញទៅដោយភាពទន់ភ្លន់ និងឱនលំទោនា

ដូច្នេះ កូនគួរតែរៀនហាត់ឲ្យមានសម្បត្តិថ្លៃថ្នូរជាប់ខ្លួនជានិច្ច ដូចជាគួរតែងខ្លួនដោយស្លៀកបំពាក់ដែលសមជាមួយវ័យ មិនដោះខោអាវនៅ

www.elibraryofcambodia.org

ស្រឡាញ់ឪពុកម្តាយ ស្តាប់តាម ហើយយកចិត្តទុកដាក់ចំពោះឪពុកម្តាយ តែងតែធ្វើឲឪពុកម្តាយសប្បាយចិត្ត ហើយមានកម្លាំងចិត្តច្រើនជាង។

កូនសម្លាញ់អើយ ! ទោះបីជាឪពុកម្តាយអត់យ៉ាងណា ពិបាកយ៉ាងណាក៏ដោយ បើសិនមានកូនដឹងគុណកតញ្ញូមកបម្រើមើលថែនៅជិតនោះ ចាំសួរសុខទុក្ខ ធ្វើតែរឿងល្អ មិនធំទាស់ចិត្ត តែប៉ុណ្ណឹងក៏ធ្វើឲឪពុកម្តាយសប្បាយចិត្ត បានអាយុវែងទៅហើយ។

ឪពុកម្តាយដែលមានកូនអកតញ្ញូ មិនដឹងគុណ មិនមកមើលថែពួកគាត់ ទុកពួកគាត់ចោលមិនរវល់ មានកូនបែបនេះក៏ដូចជាគ្មានដែរ ដោយទុកជា ជាសំណាងអាក្រក់របស់ឪពុកម្តាយហើយ ឪពុកម្តាយដែលបានកូនបែបនេះ កើតទុក្ខក្រៀមក្រំ និងមិនចង់មានជីវិតរស់នៅទេ។

ភាពអកតញ្ញូរបស់កូននោះ គឺជាថ្នាំពិសសម្រាប់ឪពុកម្តាយ ហើយ ចំណែកភាពកតញ្ញូរបស់កូនជាថ្នាំប៉ូវបេះដូង និងប៉ូវកម្លាំង ព្រមទាំងជាថ្នាំប៉ូវលេខមួយសម្រាប់ឪពុកម្តាយទាំងឡាយ។

www.elibraryofcambodia.org

# ៤៥.យកឈ្នះដោយមានហេតុផល

កូនសម្លាញ់របស់ពុកម៉ែអើយ !

ការយកឈ្នះទាស់ទែងគ្នាដោយពាក្យសម្ដី ឬក៏ដោយការឈ្លោះប្រកែកគ្នា ទោះបីជាធ្វើទៅដោយហេតុផល ពេលខ្លះក៏មិនអាចធ្វើឲ្យឯកភាពផ្សេងៗបានគ្រាន់បើផងដែរ រកតែធ្វើឲ្យខាតបង់ពេលវេលា ឬក៏អាចមានការបែកបាក់គ្នាពេលក្រោយទៀតក៏ថាបាន ដោយសារតែពាក្យសម្ដីដែលគ្មានហេតុផលមិនអាចប្រើបានគ្រប់ពេលវេលា គ្រប់ករណីនោះទេ។

ជាពិសេសក្នុងការនៅជាមួយគ្នាជាគ្រួសារ ការយល់ចិត្តគ្នា ការចេះអត់ឱនចំពោះគ្នា ការស្ដាប់គ្នាដោយភាពអត់ធ្មត់ វាក៏អាចដោះស្រាយបញ្ហាគ្រួសារបានដូចគ្នាផងដែរ ទោះបីជាមិនសូវមានហេតុផលក៏ដោយ ប៉ុន្តែម្នាក់ៗយល់ចិត្តគ្នា និយាយដោយសន្តិវិធី មិនបែកបាក់គ្នា មិនមានការប្រកាន់គ្នាបែបនេះ មិនចាំបាច់ប្រើហេតុផលក៏បានដែរ។

មានគូស្វាមីភរិយាជាច្រើនបានចែកផ្លូវគ្នាដើរ ក៏ព្រោះតែម្នាក់ៗមានហេតុផលផ្ទាល់ខ្លួន មានតែចង់យកឈ្នះគ្នាដោយហេតុផល ដោយទុកថាហេតុផលរបស់ខ្លួនឯងត្រឹមត្រូវ ម្ខាងទៀតគ្មានហេតុផល មិនព្រមធ្វើតាមនោះទេ នៅទីបំផុតក៏បែកគ្នា។

www.elibraryofcambodia.org

កន្លែងសាធារណៈ គួរតែមានការឱនលំទោនចេះដាក់ខ្លួន ចេះក្រាបសំពះគោរពដល់ចាស់ទុំ ចង់និយាយស្តីត្រូវប្រយ័ត្នមាត់ មិនត្រូវនិយាយឡូឡានៅកន្លែងសាធារណៈឡើយ ឬនៅក្នុងបន្ទប់ប្រជុំទេ មិននិយាយលូកមាត់ពេលដែលចាស់ទុំកំពុងនិយាយគ្នា ហើយចេះខ្លាចចិត្តអ្នកដទៃពេលហូបបាយហូបទឹក កុំធ្វើប្រញាប់ប្រញាល់ពេក មិនគួរនិយាយពេលដែលមានបាយក្នុងមាត់ ចង់ក្រោក ឬអង្គុយកុំប្រញាប់ពេក មើលបានសមរម្យជាមុនសិន។

ទាំងរស់នេះ សុទ្ធតែជាសម្បត្តិអ្នកថ្លៃថ្នូរដែលកូនគួរចាំទុក ដោយសម្បត្តិអ្នកថ្លៃថ្នូរជាមូលហេតុធ្វើមនុស្សយើងមានមន្តស្នេហ៍ ព្រមទាំងគួរឲស្រឡាញ់ និងជាមូលហេតុធ្វើឲចាស់ទុំស្រឡាញ់រាប់អាន ចង់ជួយឧបត្ថម្ភជាគ្រឿងតុបតែងជាប់ខ្លួន ដែលអាចយកទៅអួតគេឯងបានគ្រប់ទីកន្លែង។

www.elibraryofcambodia.org

# ៤៦.មនុស្សត្រចៀកស្រាល

កូនជាទីស្រឡាញ់របស់ពុកអើយ !

ជាប្តីភរិយានឹងគ្នាក៏ដោយ ជាមិត្តភក្តិការងារនឹងគ្នាក៏ដោយ ជាមិត្តសម្លាញ់នឹងគ្នាក៏ដោយ ជាបងប្អូននឹងគ្នាក៏ដោយ បានជំងឺប្រភេទដែលធ្វើឲ្យទាស់ទែងគ្នា ឬការមិនពេញចិត្តគ្នា ជំងឺនោះគឺ ជំងឺត្រចៀកស្រាល។

អាការៈរបស់ជំងឺត្រចៀកស្រាល គឺជាការងាយជឿគេ ដោយខ្វះការពិចារណាមិនគិតមុខក្រោយ មានអ្នកណាមកនិយាយអ្វីពីរឿងមិនល្អរបស់ស្វាមី ភរិយា មិត្តភក្តិ បងប្អូន ឬមនុស្សដែលទាក់ទងជាមួយខ្លួនឯង ក៏ស្តាប់ពិចារណាតែង ហើយជឿតែគេភ្លាម ទាំងមិនទាន់បានរកពិចារណាឲ្យបានច្បាស់លាស់ជាមុនសិន ឬមិនទាន់បានសាកសួរឲ្យច្បាស់លាស់ផង ដោយហេតុតែខ្វះគតិមិនទាំងស្គាល់អ្នកដែលនិយាយប្រាប់នោះផង នេះហើយជាជំងឺត្រចៀកស្រាលនោះឯង។

តាមការពិត បើសិនជាមានអ្នកណាមកនិយាយពីរឿងអ្នកនោះ រឿងអ្នកនេះ ដែលទាក់ទងជាមួយយើង យើងត្រូវនៅតែកណ្តាល គិតពិចារណាឲ្យបានច្បាស់លាស់ជាមុនសិន ហើយស្វាមីភរិយាឆ្លងជំងឺត្រចៀកស្រាលមកពីអ្នកដទៃ ត្រូវបែកឈ្លោះគ្នា ត្រូវបែកបាក់គ្នា និងមិត្តភក្តិបែកបាក់គ្នា

www.elibraryofcambodia.org

ហេតុផលនោះជារបស់ល្អ ប៉ុន្តែត្រូវតែប្រើឲ្យសមជាមួយករណី និងពេលវេលាផងដែរ ហើយបើសិនជានៅជាមួយគ្នា ឬធ្វើការជាមួយគ្នា ការអភ័យទោសឲ្យគ្នា ឬការព្រមទទួលស្តាប់យោបល់របស់ភាគីម្ខាងទៀតនោះ ដោយភាពអត់ធ្មត់ ការមិនប្រកាន់នូវរឿងតូចតាច ទោះបីជាមើលទៅមិនត្រឹមត្រូវ ឬមិនសមហេតុផលក៏ដោយ ប៉ុន្តែ បើសិនជាយើងអាចការពារសាមគ្គីភាពកុំឲ្យបែកបាក់គ្នាបាននោះ ក៏ប្រសើរជាងការប្រើហេតុផលដែលធ្វើឲ្យបែកបាក់ជាងមុនដែរ។

នៅក្នុងរឿងស្នេហា និងការគ្រប់គ្រងផ្ទះសម្បែងនោះ ពេលខ្លះយើងមិនអាចយកហេតុផលមកប្រើបាននោះទេ ដោយពេលខ្លះនោះវាអាចលើពីហេតុផលទៅទៀត ពីព្រោះតែការយល់ចិត្តគ្នា និងព្រមទទួលស្គាល់គ្នា គឺជាជម្រើសដែលល្អបំផុត បើសិនជាមានកំហុសឆ្គងណាមួយនោះ ក៏មិនចាំបាច់បន្ទោសគ្នា ឬក៏ប្រកែកគ្នាថា អ្នកណាខុស អ្នកណាត្រូវនោះទេ ពីព្រោះតែម្នាក់ៗសុទ្ធតែឃើញពីទង្វើល្អរបស់គ្នាទៅវិញទៅមក។

www.elibraryofcambodia.org

# ៤៧.ធ្វើល្អខ្លះក៏ល្អដែរ

កូនសម្លាញ់របស់ពុកម៉ែអើយ !

ការធ្វើខ្លួនជាមនុស្សមានទឹកចិត្ត មានភាពស្មោះត្រង់ រក្សាយុត្តិធម៌ ណាស់ណោះ ទោះបីអ្នកដទៃមើលមកថា ល្ងង់ខ្លៅ មិនចេះឆក់ឱកាសទុក មិនចេះរកស៊ី ដូចជាពាក្យចាស់ថា ធ្វើមិនជាមានឱកាសត្រូវចេះត្រជាក់ទុក កើបកើយព្រលេពពេក ធពេកល្ងង់រទាំចុះ ចុះចិត្តធពេកល្ងង់ ប្រសើរជាង ធ្វើជាមនុស្សដែលគ្មានចិត្ត មិនស្មោះត្រង់ និងមិនយុត្តិធម៌ ។

បើឯធ្វើការដោយភាពស្មោះត្រង់ មានទឹកចិត្ត ត្រង់ទៅត្រង់មក ទោះបីការនោះ មិនសូវបានកម្រៃច្រើនដូចជាគេប្រើល្បិចក៏ដោយ ប៉ុន្តែយើងគឺ សប្បាយចិត្ត ព្រោះការងើបរកព្រះខាតខ្លះតែង ប៉ុន្តែបានភាពកក់ក្ដៅ នៅ ដូចប៉ុណ្ណោះ មិនការស្ទើរនូវក្ដៅអ្វីនោះទេ តើអ្នកណាមានភាពរកឃើញ ប៉ុន្តែមិនកក់ក្ដៅ ជាមួយនឹងភាពកកក្ដៅ ប៉ុន្តែគ្មានប្រាក់ កូនជ្រើសរើស យកមួយណា ?

មានមនុស្សមួយចំនួនធ្វើជាមានមុខមាត់ក្នុងសង្គម មានពេលវេលា ចាំបោកចិត្តយកផ្លើមអ្នកដទៃជាផ្លូវការរបស់ខ្លួនឯង ប្ដូរគំនិតទីស្មោះស្មោះដើម្បី រក្សាផលប្រយោជន៍របស់ខ្លួនឯងគ្រប់ពេលវេលា ដោយមើលរំលងមនឹង

www.elibraryofcambodia.org

បងប្អូនត្រូវបែកបាក់គ្នា ដោយសារជំងឺត្រចៀកស្រាលនេះ ក៏មានឲ្យយើងឃើញមិនតិចនោះដែរ។

ពេលដែលដឹងការពិតបែបនេះហើយ បើសិនមានអ្នកណាមួយមកនិយាយរឿងអ្វីប្រាប់នោះ និយាយគួរឲ្យជឿជាក់ក៏ដោយ ត្រូវតែពិចារណាឲ្យបានច្បាស់ជាមុនសិន ប៉ុន្តែ បើសិនជាអ្នកនិយាយជាមនុស្សដែលមិនគួរឲ្យជឿជាក់នោះ យើងក៏បោះបង់ចោលទៅ មិនចាំបាច់យកមកគិតនាំតែឈឺក្បាលនោះទេ ពីព្រោះនៅលើលោកនេះមានមនុស្សពូកែប្រឌិតរឿង និងចូលចិត្តឃើញអ្នកដទៃកើតមានទុក្ខលំបាកចិត្តច្រើនណាស់។

អ្នកដែលចូលចិត្តសាបព្រោះអង្ករ អ្នកដែលចូលចិត្តបំផ្លាញអ្នកដទៃដោយពាក្យសម្ដីនោះ ក៏មានមិនតិចដែរ កូនត្រូវប្រយ័ត្នមនុស្សប្រភេទនេះឲ្យបានល្អទៅ ធ្វើចិត្តឲ្យធូន់ កុំជឿគេងាយៗឲ្យសោះ។

www.elibraryofcambodia.org

# ៤៨.ស្នេហ៍ស្មោះមួយទល់នឹងមួយ

កូនសម្លាញ់របស់ពុកប៉ែអើយ !

រឿងដែលធ្វើឲ្យគ្រួសាររស់នៅជាមួយគ្នាបានយូរអង្វែងរហូតនោះ គឺស្នេហ៍ស្មោះមួយនឹងមួយ ដោយមានន័យថា ជាការស្មោះត្រង់ ជាការស្មោះស្ម័គ្រ មិនក្បត់ចិត្តគ្នា ប្រកាន់ខ្ជាប់នៅពាក្យសន្យាដែលបានសន្យាគ្នាតាំងពីមុនមករៀងៗ

ស្វាមី ឬភរិយាដែលស្រឡាញ់គ្នាស្មោះមួយនឹងមួយ បែបនេះហៅថា ជាពាក្យសច្ចៈទៀងត្រង់ សច្ចៈនេះហើយដែលជាគ្រឿងភ្ជាប់ សម្រាប់ទាក់ទាញចិត្តស្វាមីភរិយាមួយគូនេះ លើកលែងពេលដែលបានសច្ចៈជាស្រឡាញ់ស្មោះមួយនឹងមួយចំពោះគ្នាហើយ អ្វីផ្សេងៗទៀតដូចជា ការដែលបែកចិត្តយល់ផ្ទើម ការអត់ទោសឲ្យគ្នា ការអាណិតអាសូរគ្នាក៏នឹងមានដែរ។

ការស្រឡាញ់ស្មោះមួយនឹងមួយនេះហើយ ដែលធ្វើឲ្យគ្រួសាររស់នៅដោយមានសុខសប្បាយ គ្មានការឈ្លោះប្រកែកគ្នាតវ៉ាលើគ្នា ជារឿងដ៏ល្អបំផុតគួរតែរក្សាទុក ហើយពេលដែលកូនមានគ្រួសារក៏ស្នើឲ្យកូនធ្វើការប្រកាន់ខ្ជាប់ខ្លួនបែបនេះទៅ នោះគ្រួសាររបស់កូននឹងក្លាយទៅជាគ្រួសារដែលមានសេចក្ដីសុខ ប៉ុន្តែបើសិនភាគីខាងណាមិនស្រឡាញ់ស្មោះមួយនឹងមួយនោះទេ ប្រាកដជានៅមិនបានសុខនោះទេ ការដែល

www.elibraryofcambodia.org

អ្នកដទៃ ហើយតែងតែគិតថា ខ្លួនឯងឆ្លាតដែលធ្វើបែបនោះបាន ដោយភ្លេចថា ភាពឆ្លាតវៃនោះហើយដែលធ្វើឲខ្លួនឯងហូបមិនទៀងពេល ដេកមិនទៀងពេល គ្មានពេលឲគ្រួសារ ធ្វើឲគ្រួសារគ្មានភាពកក់ក្ដៅ ពីព្រោះរវល់ទៅយកចិត្តអ្នកដទៃ ហួសពីការចាំបាច់។

កូនអើយ ! អ្នកដែលគេងមិនលក់ ពីព្រោះគិតច្រើនអំពីរឿងការងាររឿងរពេញរ៉ីនោះ តែងតែគិតថា ខ្លួនឯងជាមនុស្សឆ្លាតណាស់ អ្នកដែលព្រមធ្វើជាមនុស្សល្ងង់ ឬក៏ជាមនុស្សល្ងង់ពិតនោះ ឲតែក្បាលដល់ខ្នើយពេលណាក៏លក់ពេញមួយយប់ ព្រមធ្វើជាមនុស្សល្ងង់ខ្លះទៅក៏ល្អម្យ៉ាងដែរកូន។

www.elibraryofcambodia.org

# ៤៩.កុំយកតម្រាប់តាមអ្នកដទៃ

កូនសម្លាញ់របស់ពុកម៉ែអើយ !

កូនប្រហែលជាធ្លាប់បានឃើញពួកមនុស្សខ្លះហើយ ចូលចិត្តអង្គុយជុំគ្នានិយាយដើមគេណាស់ បានអង្គុយនិយាយពេលណាលើករឿងអ្នកនេះអ្នកនោះមកនិយាយលេងដើម និយាយពីគេពីរឿងផ្សេងៗ ដែលសុទ្ធតែជារឿងធ្វើឲគេអាក្រក់ ចូលចិត្តធ្វើខ្លួនជាអ្នកដឹងរឿងរបស់គេណាស់ ទាំងដែលខ្លួនឯងដឹងច្បាស់ខ្លះ មិនច្បាស់ខ្លះ ប៉ុន្តែពេលដែលនិយាយទៅហើយ ក៏សប្បាយមាត់ឈប់មិនបាន។

កូនអើយ ! ធម្មតាដែលមនុស្សយើងនិយាយច្រើននោះ វាមិនអាចទេដែលពាក្យសម្ដីទាំងនោះជាការពិតទាំងអស់ មនុស្សប្រភេទនេះកូនមិនគួរធ្វើតាមនោះទេ កុំយកតម្រាប់តាមគេ បើសិនជាមានអ្នកណាលើករឿងយើងទៅនិយាយក្នុងផ្លូវមិនល្អនោះ យើងក៏មិនចូលចិត្តដូចគ្នាផងដែរ។

ដូច្នេះហើយ កូនមិនគួរធ្វើបែបនេះចំពោះអ្នកដទៃ ហើយការដែលនិយាយពីអ្នកដទៃនោះត្រូវប្រយ័ត្នផង ទោះបីជាការពិត ឬរឿងល្អក៏ដោយ ត្រូវតែមានការប្រយ័ត្នជៀសវាងប៉ះពាល់ទៅដល់គេ ដោយគេប្រហែលជាមិនចូលចិត្តទេដែលយើងយករឿងគេមកនិយាយនោះ បើសិនជារឿងមិនពិត

www.elibraryofcambodia.org

ឃើញមុខគ្នាហើយ នៅជាមួយគ្នាជាមួយមនុស្សដែលមិនស្មោះត្រង់ នោះវាពិតជាគួរឲ្យធុញទ្រាន់ និងពិបាកចិត្តយ៉ាងណាទេ ក៏ប្រហែលជាកូនបានដឹងខ្លះហើយ ទើបមិនគួរប្រព្រឹត្តិខ្លួនជាមនុស្សក្បត់ចិត្តនឹងគូស្រករបស់ខ្លួនឯងនោះឡើយ។

មនុស្សយើងសូម្បីតែសច្ចៈចំពោះគូស្រករដែលខ្លួនស្រឡាញ់ ក៏រក្សាមិនបានផង តើអាចទៅរក្សាអំពើល្អអ្វីផ្សេងបានទៅ ភាពគួរឲ្យជឿជាក់ និងកិត្តិយសរបស់យើងនោះ ចាប់ផ្ដើមឡើងពីការមានសច្ចៈនេះហើយ ដោយបេអ្នកដែលមានសច្ចៈ ហើយរក្សាសច្ចៈបាន ទើបគួរឲ្យជឿជាក់បាន ហើយបេមានកិត្តិយសគ្រប់គ្រាន់ដែលអាចឲ្យទុកចិត្តបាន។

www.elibraryofcambodia.org

# ៥០.បាបកម្មមានពិត

កូនសម្លាញ់របស់ពុកម៉ែអើយ !

រឿងបាបកម្មនោះ សូមកុំមានការប្រមាថមើលងាយ ហើយកុំគិតថា កម្មពៀរវាគ្មានមែននោះ រឿងពិតនេះមិនមែនរកពេលវេលាតែចាំមើលវាបាន នោះទេ អ្នកណាជឿ ឬមិនជឿក៏ដោយ បើដល់ពេលវេលា កម្មពៀរនឹងកើតពេលមកដល់ ដូចជាឆ្នាំពុលអ្នកស្គាល់ ឬមិនស្គាល់ក៏ដោយ ពេលផឹកហើយក៏ត្រូវតែស្លាប់ដូចគ្នាដែរ។

បាបកម្មជារឿងដែលយើងសាងទុក អាចតិចខ្លះ ច្រើនខ្លះ សាងជាញឹកញាប់ទៅ ក៏សន្សំទុក យូរទៅក៏កើតផលដល់អ្នកដែលសាង ទទួលកម្មផលនោះ ដោយពេលខ្លះធ្វើឲ្យខាតបង់ ពេលខ្លះធ្វើឲ្យបាត់ជីវិតក៏មានដែរ ហើយដូចមនុស្សដែលបរិភោគអាហារដែលមានជាតិពុលតិចតួចទៅ ដំបូងគ្មានអារម្មណ៍អ្វីទេ ប៉ុន្តែយូរទៅ ពិសដែលគេលាយទុកក្នុងអាហារនោះ វាកើតឫទ្ធិ ធ្វើឲ្យអ្នកបរិភោគនោះមានគ្រោះថ្នាក់ធ្ងន់ធ្ងរដូចដែលបានដឹងរួចមកហើយ។

បាបកម្មបានបង្កផលធ្វើឲ្យអ្នកសាងបាបកម្មនោះ ទទួលកម្ម ឬក៏មានវិបត្តិផ្សេងៗ ហើយគេមិនដឹងទេថា ដែលជាបែបនេះគឺព្រោះតែផល

www.elibraryofcambodia.org

ឬជារឿងដែលយើងប៉ាន់ស្មានដោយខ្លួនឯងនោះ ជាបាបកម្មខ្លាំងណាស់ គ្មានប្រយោជន៍អ្វីនោះទេ មានតែខាតពេលទទេៗ សុខចិត្តយកពេលវេលាមកគិតពីរឿងរបស់យើងវិញប្រសើរជាង។

បើសិនជាគ្មានអ្វីគិតទេ ទៅដេកសម្រាក ឬទៅដើរលេង អង្គុយដេកមើលសៀវភៅ មើលទូរទស្សន៍វិញប្រសើរជាង ពីព្រោះតែគ្មានទោសខាងផ្លូវមាត់ ហើយក៏មិនជាទុច្ចរិតខាងវាចារដែរ ដោយអ្នកដែលចង់និយាយដើមអ្នកណានោះ វាជារឿងរបស់គេ កុំទៅចូលរួមជាមួយគេអី វាល្អបំផុតណាស់ទៅហើយ។

www.elibraryofcambodia.org

# ៥១.ទឹកចិត្តមានតម្លៃជាងទឹកប្រាក់

កូនសម្លាញ់របស់ពុកអើយ !

ពេលដែលកូនចូលបម្រើការងារ ឬទៅស៊ីឈ្នួលគេក៏ដោយ ចូរខំធ្វើការនោះឲ្យបានល្អ ខំប្រឹងឲ្យអស់ពីសមត្ថភាពឲ្យលើសនឹងប្រាក់ខែ ឬថ្លៃឈ្នួលរបស់គេ ហើយបើសិនជាធ្វើឲ្យលើសប្រាក់ខែ ឬថ្លៃឈ្នួលនោះក៏កាន់តែល្អ កុំធ្វើការបើគ្រាន់តែចង់បានតែប្រាក់ខែនោះ កុំគិតធ្វើការឲ្យតែហើយពីដៃនោះ គួរណាតែធ្វើការនោះឲ្យអស់ពីសមត្ថភាពផង។

មនុស្សយើងគួរតែធ្វើជាមនុស្សមានទឹកចិត្ត កុំធ្វើជាមនុស្សគ្មានទឹកចិត្តអី អ្នកដែលធ្វើការលើសពីប្រាក់ខែដែលទទួលបាននោះដោយស្ម័គ្រចិត្ត បង្ហាញពីទឹកចិត្តដែលមិនចេះយកប្រៀបលើអ្នកដទៃនោះ ទោះបីខាតពេលបន្តិចក៏ដោយ ប៉ុន្តែការងារចេញមកល្អ នោះជាមោទនភាពរបស់ខ្លួនយើងហើយដែរ។

មោទនភាពបែបនេះហើយ អាចស្រោចស្រង់ចិត្តបេះដូងយើងមានការរីករាយជាប់ជានិច្ច ដែលមិនអាចរកទិញបានទេ ហើយក្រៅពីបានពីការមានទឹកចិត្តរបស់យើងហើយ បើសិនមានទឹកចិត្ត ចិត្តក៏មានទឹកចាំស្រោចស្រង់ត្រជាក់ជុំ ដោយខុសពីមនុស្សគ្មានទឹកចិត្ត ក្រៅពីគ្មានរបស់គួរឲ្យមាន

www.elibraryofcambodia.org

កម្មដែលគេបានសាងមក ដោយពេលខ្លះអាចមិនព្រមទទួលយកការពិតពីរឿងនេះទេ ប៉ុន្តែបែរជាទៅបន្ទោសនេះ បន្ទោសនោះ ទៅវិញ ពីព្រោះតែមូលហេតុនេះហើយ ទើបធ្វើឲមនុស្សខ្លះទៅមិនខ្លាចបាប និងមិនខ្មាសបាប ទើបបានជានាំឲពួកគេសាងបាបកម្មផ្សេងៗដោយមិនខ្លាចបាបអ្វីសោះ។

www.elibraryofcambodia.org

# ៥២.ថ្នាំប៉ូវបេះដូង

កូនសម្លាញ់របស់ពុកម៉ែអើយ !

កូនមានដឹងទេថា ទំនិញក៏ដោយ អាហារក៏ដោយ កេសប្រាក់កាក់របរក៏ដោយ ដែលកូនយកមកឲពុកម៉ែ ពេលកូនមកលេងពុកម៉ែនោះ ជាថ្ងៃដ៏រីករាយរីករាយដែលធ្វើឲពុកម៉ែសប្បាយចិត្តខ្លាំងណាស់ ពីព្រោះវាជារបស់កូន ជារបស់ដែលកូនបានយកមក ហើយទោះបីជារបស់ទាំងអស់នោះពុកម៉ែមានរួចទៅហើយ ទោះបីរកធ្វើ រកទិញខ្លួនឯងបានក៏ដោយ ប៉ុន្តែប្រៀបជាមួយរបស់កូនយកមកឲមិនបាននោះទេ គួរឲចង់ហូប គួរឲចង់ប្រើប្រើនជាង ពីព្រោះវាជារបស់ដែលលាយជាមួយទឹកចិត្តកូននោះវិញ។

កូនមកលេងពុកម៉ែឃើញមុខ ពុកម៉ែក៏សប្បាយចិត្តណាស់ទៅហើយ ប៉ុន្តែកាន់តែសប្បាយចិត្តទៅទៀត ដោយនៅពេលដែលកូនយករបស់មកឲដោយផ្ទាល់ដៃរបស់កូននោះ ដោយជារបស់ដែលផ្ដល់កម្លាំងចិត្ត ហើយគ្មានអ្វីរាពប៉ូវបេះដូងបានល្អជាងថ្នាំបែបនេះទេកូន ! ។

www.elibraryofcambodia.org

មោទនភាពហើយ ចិត្តរបស់គេក៏ក្រៀមស្វិត ដូចជាផ្កាខែប្រាំងដែរ។

សូមកូនរៀនធ្វើជាមនុស្សមានទឹកចិត្តទៅ ដោយរឿងបែបនេះដែរ កុំប្រកាន់ថា ជាការចាញ់ប្រៀប ឬបានប្រៀបអី ប៉ុន្តែសូមកូនទុកថា ជារឿងទឹកចិត្តដែលគួរមានចំពោះគ្នា ដើម្បីនៅធ្វើការងារជាមួយគ្នាបានយូរអង្វែង ហើយនៅទីបំផុតនោះទឹកចិត្តក៏មានតម្លៃជាទឹកប្រាក់ដែរកូន។

www.elibraryofcambodia.org

# ៥៤.ការចេះសន្តោសប្រណី

កូនសម្លាញ់របស់ពុកម៉ែអើយ !

នៅលើលោកយើងនេះ គ្មានអ្នកណាធ្វើល្អ ឬធ្វើត្រូវគ្រប់យ៉ាងឡើយ ហើយក៏គ្មានអ្នកណាធ្វើត្រូវចិត្តយើងបានគ្រប់យ៉ាងនោះដែរ ដោយចំពោះយើងក៏ដូចគ្នា មិនមែនធ្វើល្អត្រូវបានទាំងអស់នោះទេ ឬធ្វើឲ្យអ្នកដទៃបានពេញចិត្តគ្រប់គ្នានោះដែរ រឿងអ្វីទាំងនេះជាការធម្មតា។

អ្នកដទៃគេធ្វើខុសផ្លូង ខ្លះឆ្កួតប្រហែស ខ្លះធ្វើមិនត្រូវចិត្តយើង និងខ្លះប៉ះពាល់ដល់យើងនោះ បើសិនជាយើងសន្តោសប្រណីឲ្យគេបាន ក៏ឲ្យគេទៅកូន កុំទៅប្រកាន់ទឹង ឬទៅស្តីឲ្យគេអី ដោយអោនទៅស្ងៀមទៅ ធ្វើជាមិនដឹងមិនឮខ្លះទៅក៏ល្អដែរ កុំយកមកទុកក្នុងចិត្តពេកអី។ ពេលណាអត់ទោសឲ្យគេហើយ អ្នកដែលសប្បាយចិត្តជាងគេគឺជាយើងនេះហើយ ព្រោះការចងកំហឹងជាប្ញូរគេ ដូចជាបានប្រកាន់នៅចងដឹងខ្លួន ត្រូវគិតព្យាបាទចងគំនុំមិនឈប់មិនឈរ គ្មានអ្វីល្អនោះទេ។

ការចេះសន្តោសប្រណីមួយវិញទៀតគឺ មិនឲ្យទុកទោសរបស់អ្នកផ្សេងមានន័យថា យើងកុំធ្វើខ្លួនជាមនុស្សឲ្យមានទុក្ខទោសដល់អ្នកដទៃ មិនបង្កការភ័យខ្លាច ការពិបាក ឬការសង្ស័យដល់អ្នកដទៃ ប៉ុន្តែធ្វើជាមនុស្សបើក

www.elibraryofcambodia.org

# ៩៣.សង្ឃឹមថានឹងបានឃើញ

កូនសម្លាញ់របស់ពុកម៉ែអើយ !

ឪពុកម្ដាយទាំងឡាយ ក្រៅពីចង់ឲ្យកូនមកមើលថែយកចិត្តទុកដាក់ហើយនោះ គឺនៅមានសេចក្ដីប្រាថ្នាមួយទៀតគឺ សង្ឃឹមថាបានឃើញកូនមានភាពរីកចម្រើន មានភាពជោគជ័យនៅក្នុងជីវិត មានជីវិតល្អ និងមានសេចក្ដីសុខសប្បាយ ហើយបើសិនជាកូនបានដូចក្ដីប្រាថ្នានេះ ឪពុកម្ដាយគ្រប់រូបមិនច្រណែននឹងកូនទេ ព្រមទាំងបារម្ភតែម្យ៉ាងខ្លាចមិនបានឃើញកូនជាបែបនោះ។

អ្វីដែលពុកម៉ែទ្រាំចិញ្ចឹមកូនមកនេះ គឺដើម្បីប្រាថ្នាឲ្យកូនបានសម្រេចនៅបំណងនោះ ហើយបើសិនជាកូនជាមនុស្សល្អ មានចំណេះដឹងមានសមត្ថភាពឆ្លាតវៃ មានការងារពិតប្រាកដ មានភាពជោគជ័យនៅក្នុងជីវិតបានតាមបំណងនោះ ឪពុកម្ដាយគ្រប់រូបក៏បាត់ហត់នឿយ ប៉ុន្តែកុំឲ្យពុកម៉ែអស់សង្ឃឹមទៅបានហើយ។

www.elibraryofcambodia.org

# ៥៥.រឿងលាក់នៅក្នុងចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

កូនក៏ធំល្មមអាចដឹងរឿងរ៉ាវរបស់ជីវិតខ្លះហើយ កូនប្រហែលជាដឹងហើយថាឪពុកម្ដាយណាក៏ដោយត្រូវស្រឡាញ់កូនរបស់ខ្លួនណាស់ ដោយហេតុកូនប្រៀបប្រដូចជាកែវភ្នែករបស់ឪពុកម្ដាយ ហើយដែលពុកម៉ែខិតខំធ្វើការរកលុយដល់ថ្នាក់មិនសូវមានពេលវេលាជួបកូនសព្វថ្ងៃនេះ ក៏កូនប្រហែលជាដឹងហើយថាដើម្បីតែកូននោះហើយ ដោយសម្រាប់តែខ្លួនពុកម៉ែពីរនាក់ធ្វើការតែកន្លះថ្ងៃក៏គ្រប់គ្រាន់ណាស់ទៅហើយ ដែលពុកម៉ែប្រឹងគ្នាបែបនេះ ក៏ព្រោះតែស្រឡាញ់កូននោះហើយ ហើយការដែលប្រាប់នេះ មិនមែនចង់រំឭកគុណឬចង់ទាមទារអ្វីពីកូននោះទេ ពីព្រោះទៅថ្ងៃក្រោយកូនក៏គង់តែបានដឹងខ្លួនឯងដូចគ្នា។

តាមការពិតទៅឪពុកម្ដាយគ្រប់គ្នានោះ ត្រូវការអ្វីៗជាច្រើនយ៉ាងពីកូន ប៉ុន្តែនិយាយមិនបាន ពិបាកនឹងហាមាត់ណាស់ ដូចជា ឪពុកម្ដាយមានមាសប្រាក់ មានរបស់ប្រើប្រាស់រាប់មិនអស់ក៏ដោយ ប៉ុន្តែក៏នៅតែចង់បានរបស់ធ្វើពីកូនផងដែរ ហើយទោះបីជារបស់នោះគ្មានតម្លៃដូចជារបស់ដែលមានហើយក៏ដោយ ប៉ុន្តែ បើសិនជារបស់កូនធ្វើមកនោះ ពុកម៉ែពិត

www.elibraryofcambodia.org

ជំហរមិនប្រកាន់ខ្លួន ធ្វើខ្លួនឲ្យអ្នកដទៃមានទំនុកចិត្ត។

ការតរន្ដោសប្រណីជាអំពើល្អសម្រាប់ខ្លួនឯង ដោយអ្នកដទៃគេនឹងមានទំនុកចិត្តចំពោះយើង ប្រគល់ការងារសំខាន់ឲ្យយើងធ្វើ ខុសពីមនុស្សមានពិសពុល ទុកចិត្តមិនបាន ទៅដល់ទីណាក៏គ្មានអ្នកណាចង់ឲ្យនៅជិត នៅទីណាក៏មានការសង្ស័យ ធ្វើការអ្វីក៏ដោយគ្មានអ្នកណាទុកចិត្ត មានតែផលវិបាកក្រក់គ្រប់យ៉ាង។

សូមកូនកុំធ្វើខ្លួនជាមនុស្សបែបនេះអី ដោយការឲ្យអភ័យទោសដល់អ្នកដទៃបាន កូនក៏សប្បាយចិត្ត និងធ្វើខ្លួនមិនឲ្យមានពិសពុល ទោះបីជានៅទីណាកូនក៏អាចនៅបានដែរ គ្មានអ្នកណាស្អប់ឡើយ។

កូនរៀនអភ័យទោសឲ្យគេទៅ កុំទៅគិតថា ជាការអាប់ឱនអីពេលដែលអភ័យទោសឲ្យគេនោះ ពីព្រោះមនុស្សយើងស្រឡាញ់កិត្តិយសហួសពីការចាំបាច់នេះហើយ ទើបបានជាមកគិតចងគំនុំ សាងកម្មពៀរមិនចេះឈប់ឈរនោះ។

www.elibraryofcambodia.org

# ៥៦.ល្អ អាក្រក់

កូនសម្លាញ់របស់ពុកម៉ែអើយ !

បើសិនជាយើងចង់ឲ្យជីវិតរបស់យើងដំណើរការទៅបានល្អ ការគេគោរពនោះ រស់នៅដោយមានសេចក្តីសុខនោះ និងទីបំផុតចង់ឲ្យគ្រួសាររបស់ខ្លួនមានភាពកក់ក្តៅ ត្រូវធ្វើខ្លួនយើងឲ្យល្អជាមុនសិន ដោយយើងអាចធ្វើល្អបាន ទាល់តែយើងដឹងថាអ្វីល្អ ទើបអាចធ្វើត្រូវ ដូចគ្នានឹងយើងត្រូវតែដឹងថាអ្វីអាក្រក់ ទើបយើងមិនធ្វើ។

រឿងល្អអាក្រក់នេះជារឿងសំខាន់នៅក្នុងជីវិត អ្វីល្អ អ្វីអាក្រក់ ត្រូវតែមានការបែងចែកឲ្យបានច្បាស់លាស់ បើសិនជាបែងចែកមិនបានច្បាស់ទេ អាចធ្វើឲ្យយល់ខុស គឺឃើញល្អថាអាក្រក់ ឃើញអាក្រក់ថាល្អវិញ ហើយដែលមានច្រើនណាស់ ដែលយល់បែបនេះ ទើបធ្វើឲ្យយល់ច្រលំបាន ធ្វើឲ្យជីវិតប្រែប្រួលទៅ ធ្វើឲ្យគ្រួសារខ្វះភាពកក់ក្តៅរហូតដល់ថ្នាក់បែកបាក់គ្នាបានផងដែរ ធ្វើឲ្យអ្នកដទៃស្អប់ខ្ពើម មិនចង់រាប់អានជាមួយ។

រវាងការពិតអំពើល្អ អំពើអាក្រក់ មនុស្សល្អ មនុស្សអាក្រក់ រឿងល្អ រឿងអាក្រក់ នៅជិតគ្នាណាស់ ដោយពេលខ្លះនៅក្នុងខ្លួនមនុស្សម្នាក់ទេ ប៉ុន្តែផ្ទុយគ្នា , ស្រឡះមិនដូចគ្នាទេ ដូចជាកាក់មុខពីរដែរ ទោះបីជាទាំង

www.elibraryofcambodia.org

ជាមានការសប្បាយគ្មានអាចប្រៀបផ្ទឹមបាននោះឡើយ។

ពេលដែលកូនមាននំ មានអាហារផ្ញើមក ទោះបីឆ្អែតហើយក៏ដោយ ក៏អាចហូបបានទៀតដែរយ៉ាងមានការពេញចិត្ត ជាមួយនឹងរបស់ដែលកូនយកមកនោះ ឬខោអាវដែលយកមកឲ ទោះបីមិនសូវស្អាតក៏ដោយ ប៉ុន្តែពាក់អួតកូន យកចិត្តកូន ឬពេលដែលកូនមកលេង ព្រមទាំងម្យ៉ាងទៀត ទោះបីជាគ្មានអ្វីយកមកផ្ញើ មានតែមុខឲមកឃើញ មានតែដៃទាំងពីរមកសំពះ និងឱបឪពុកម្តាយនោះ តែប៉ុណ្ណឹងក៏ឪពុកម្តាយមានការសប្បាយចិត្តណាស់ទៅហើយ វាពិតជាឲពុកម៉ែសប្បាយរីករាយខ្លាំងណាស់។

នៅក្នុងចិត្តឪពុកម្តាយគ្រប់គ្នាជាបែបនេះ ដោយកូនទៅថ្ងៃអនាគត បើសិនជាកូនមានកូនដែរនោះ កូននឹងយល់ពីអារម្មណ៍នេះបានច្បាស់។

www.elibraryofcambodia.org

# ៥៧.ទម្លាប់របស់មនុស្សចាស់

កូនសម្លាញ់របស់ពុកម៉ែអើយ !

រឿងរបស់មនុស្សចាស់តែងតែជារឿងគួរខានសម្រាប់ក្មេងៗ ព្រោះតែមានវិបត្តិសញ្ញា ដោយសារមនុស្សចាស់ភាគច្រើនពូកែរអ៊ូរទាំណាស់ ចិត្តក៏ច្រើន ចូលចិត្តឲ្យកូនចៅយកចិត្តបើកថ្លើម គំនិតយឺតយ៉ាវ ចំណែកក្មេងៗចូលចិត្តភាពរហ័សរហួន ឆាប់ខាតពិនិត្យពេកច្រើន លើកលែងតែមនុស្សដែលស្លូតត្រង់ស្រឡាញ់ប៉ុណ្ណោះ ដែលទម្លាប់មនុស្សចាស់បែបនេះហើយ ទើបធ្វើឲ្យចាស់ៗ និងក្មេងៗ មិនសូវត្រូវគ្នា ដោយសារទោះបីជាឪពុកម្ដាយ និងកូនក៏ដោយក្ដីដែរ។

ពេលនេះពុកម៉ែចាស់ៗរស់ទៅហើយ អាចរអ៊ូរទាំខ្លះដែរ កូនកុំប្រកាន់នឹងពុកម៉ែធ្វើអ្វី ពីព្រោះគ្មានចេតនាទេ ទ្រាំរំខានបន្តិចសិនទៅ ដោយមនុស្សចាស់ស្ទើរតែបែបនេះគ្រប់គ្នា ឃើញអ្វីក៏ទើសបុនទើសភ្នែកផងដែរ កូនមិនចាំបាច់ខ្វល់ខ្វាយក៏បានដែរ នៅស្ងៀមស្ដាប់ខ្លះទៅ បណ្ដោយឲ្យពុកម៉ែរអ៊ូតាមទម្លាប់របស់ចាស់ទៅ ពេលហត់ក៏ឈប់ខ្លួនឯងហើយ។

ធ្វើយ៉ាងម៉េចទៅកូនសម្លាញ់អើយ ការរអ៊ូទាំងនេះជាចរិតទម្លាប់របស់មនុស្សចាស់ទាំងអស់គ្នាទៅហើយ បើសិនបានរអ៊ូចេញមកខ្លះ បានធូរ

www.elibraryofcambodia.org

សងខាងនៅជិតគ្នា ក៏មិនអាចចូលគ្នាបានដែរ ចូលមិនបានទេ ពីព្រោះតែវាបានបែងចែកម្ខាងម្នាក់ ហើយល្អអាក្រក់ក៏ដូចគ្នាដែរ ជួនកាលបែងចែកស្ទើរតែមិនដឹង ប៉ុន្តែក៏ត្រូវព្យាយាមបែងចែកឲដឹង បើសិនមិនអញ្ចឹងនឹងឃើញល្អទៅអាក្រក់ អាក្រក់ទៅល្អជាមិនខាន។

ការដែលយល់ឃើញបែបនេះ ចាស់បុរាណគាត់ហៅថា **ឃើញកងចក្រថាផ្កាឈូក** ពីព្រោះតែបែងចែកមិនដឹងថា កងចក្រជាយ៉ាងណា និងកម្រងផ្កាជាយ៉ាងណា។

www.elibraryofcambodia.org

# ៥៨. ទុកសម្រាប់កូន

## ជាមនុស្សមានទឹកចិត្តប្រពៃ

កូនសម្លាញ់របស់ពុកម៉ែអើយ !

**មនុស្សចិត្តល្អ** គឺជាមនុស្សដែលមានទឹកចិត្តទន់ភ្លន់ ចេះករុណាអាណិតអាសូរដល់អ្នកដទៃ មិនប្រកាន់ពេលដែលមានអ្នកដទៃធ្វើខុសមកលើខ្លួន មិនចេះខឹងក្រោធពេលដែលមានអ្នកដទៃមកប៉ះពាល់ មិនលើករឿងអ្វីមិនបានការមកគិត កាត់ចិត្តបាន មិនគិតចងគំនុំ ហើយក៏មិនចេះលើករឿងមិនល្អរបស់អ្នកដទៃមកនិយាយបង្ខូចឈ្មោះផងដែរ។

## ភាពកតញ្ញូដឹងគុណ

ចំពោះឪពុកម្ដាយវិញនោះ ទោះបីជាអត់យ៉ាងណា ទោះបីជាពិបាកយ៉ាងណា បើសិនជាកូនមានភាពកតញ្ញូដឹងគុណ ចាំមើលថែបម្រើ ចាំសួរសុខទុក្ខ ធ្វើរឿងដែលល្អមិនឲ្យទាស់ចិត្តតែប៉ុណ្ណឹង ក៏ធ្វើឲ្យឪពុកម្ដាយបានអាយុវែងណាស់ទៅហើយកូនសម្លាញ់អើយ !។

www.elibraryofcambodia.org

កូនចៅទៅខ្លះនោះ វាអាចធ្វើឲមនុស្សចាស់មានអាយុវែង ពីព្រោះស្លូតបានហាត់ប្រាណ និងធ្វើឲឈាមដើរបានស្រួល ហើយកូនចាំតែមើលទៅថា វាពិតដូចដែលគេថាឬទេ ទោះបីជាយ៉ាងណាពេលនេះកូនទ្រាំសិនទៅ ពុកម៉ែរអ៊ូឲកូនចៅខានត្រចៀកមិនបានយូរប៉ុន្មាននោះទេ។

www.elibraryofcambodia.org

# ៥៩.ធ្ងន់ ឬក៏ស្រាល ក៏ត្រូវតែតស៊ូ

កូនសម្លាញ់របស់ពុកម៉ែអើយ !

អ្នកដែលរកឃើញខ្លួនរបស់គេ រហូតទទួលបានជីវភាពស្ថិតស្ថេរនោះ ដោយសារភាគតិចណាស់ដែលទទួលបានទ្រព្យសម្បត្តិកេរ្តិ៍មរតក ពីភាគច្រើនគេចាប់ផ្ដើមមកពីការលំបាក មានតែកម្លាំងកាយ កម្លាំងចិត្ត ដែលជាកេរ្តិ៍មរតក ហើយប្រើនូវកម្លាំងកាយកម្លាំងចិត្តនោះ មកធ្វើការតស៊ូនៅក្នុងជីវិត ដោយប្រើការតស៊ូបែបក្បាលទល់មេឃ ជើងទល់ដី ឬធ្ងន់ក៏ស៊ូ ស្រាលក៏ស៊ូ ទើបគេមានជីវភាពល្អ មានជីវភាពស្ថិតស្ថេរដូចដែលយើងបានឃើញ ហើយចំណែកប្រភេទមនុស្សដែលធ្ងន់មិនស៊ូ ស្រាលមិនយកនោះ ពិតតែសុខស្រួល ចូលចិត្តតែសប្បាយហ៊ឺហា គឺនឹងគ្មានឱកាសកសាងខ្លួនបាននោះឡើយ ទោះបីជាមានទ្រព្យសម្បត្តិច្រើនសម្រាប់ដេកស៊ីក៏ដោយ ក៏ត្រូវតែបំផ្លាញដោយស្នាដៃខ្លួនឯងរបស់ផងដែរ។

កូនសម្លាញ់អើយ ! ចាស់បុរាណបានប្រៀនប្រដៅមកយូរហើយថា **«ជីវិត គឺជាការតស៊ូ និងសត្រូវ គឺជាថ្នាំប៉ូវកម្លាំង»** ដោយពាក្យថាសត្រូវនៅទីនេះ ក្រៅពីចង់សំដៅលើមនុស្សហើយ នៅមានន័យដល់ការលំបាក និងឧបសគ្គផ្សេងៗទៀតផងដែរ ហើយបើសិនជាមនុស្សយើងត្រូវតស៊ូនៅ

www.elibraryofcambodia.org

# ជំពូកទី២

## គតិបណ្ឌិតប្រៀនប្រដៅ
## បង្រៀនកូនឲចេះតស៊ូនៅក្នុងជីវិតដោយខ្លួនឯង

«ដរាបណាដែលយើងអាចក្រោកឈរឡើងតស៊ូបាន ដរាបនោះ យើងនៅមិនទាន់បរាជ័យ ដោយព្រះពុទ្ធទ្រង់សម្តែងថា កើតជាមនុស្ស ត្រូវតែខំព្យាយាម ទាល់តែបានសម្រេចប្រយោជន៍ ទោះបីការព្យាយាមនោះ អាចមានឱកាសបានសម្រេចទទួលផលបន្តិចបន្តួចក៏ដោយ ប៉ុន្តែក៏មានឈ្មោះថា មានការព្យាយាមហើយ ហើយអ្នកដទៃក៏មិនអាចមើលស្រាលយើងថា ជាមនុស្សបរាជ័យ ឬក៏ជាអ្នកចុះចាញ់នៅក្នុងជីវិតបាននោះទេ ដូច្នេះ បើសិនជាយើងមិនត្រូវការបរាជ័យនោះទេ ក៏មិនត្រូវបោះបង់ ហើយបើមិនទាន់បោះបង់ ក៏មិនទាន់បរាជ័យផងដែរ»

www.elibraryofcambodia.org

# ៦០.បើសិនជាដួលត្រូវក្រោកឈរឡើង

កូនសម្លាញ់របស់ពុកអើយ !

នៅក្នុងការរស់នៅវិញ មិនមែនមានភាពងាយស្រួលគ្រប់ពេលវេលានោះឡើយ ដោយជីវិតមានឡើង មានចុះ មានសុខ មានទុក្ខ ដែលតែងជាមួយនឹងគ្នាគ្រប់ពេលវេលា ហើយជាពិសេសនៅក្នុងរឿងធ្វើការ ការងារកាន់តែធំ មានឧបសគ្គក៏កាន់តែច្រើន។

បើសិនជាកូនធ្វើការអ្វីមួយដែលកូនច្បាស់ថា ជាការងារល្អនោះ ជាការងារធ្វើឲ្យមានភាពរីកចម្រើនបាន ប៉ុន្តែបើសិនពេលដែលធ្វើទៅហើយ ការងារមិនមានភាពរីកចម្រើនដូចដែលយើងបានគិតទុកនោះ ហៅថាមានឧបសគ្គរាំងហើយ ដោយកូនត្រូវតែពុះពារឧបសគ្គនោះឲ្យបានជាមួយនឹងសតិបញ្ញា ភាពមោះមុត ម៉ត់ចត់ កុំឆេវឆាវ គិតដោះស្រាយតាមសម្រួល កុំមានការរួញរាអស់កម្លាំងចិត្តឲ្យសោះ។

របស់ដែលសំខាន់ជាងគេបំផុតនៅក្នុងពេលដែលយើងមានបញ្ហា ឬមានឧបសគ្គនៅក្នុងជីវិតនោះគឺ **កម្លាំងចិត្ត** ដោយកុំឲ្យកម្លាំងចិត្តមានការធ្លាក់ចុះឲ្យសោះ ទោះបីជាការងារ ឬសាច់ប្រាក់គ្មានយ៉ាងណាក៏ដោយ សូមកុំឲ្យកម្លាំងចិត្តរបស់យើងធ្លាក់ទៅតាម ត្រូវតែប្រឹងប្រែងកម្លាំងចិត្តឲ្យបាន

www.elibraryofcambodia.org

ក្នុងជីវិត ត្រូវតែជួបជាមួយនឹងការលំបាក ប៉ុន្តែសូមឲកូនគិតថា រាល់ការលំបាកនោះ ជាថ្នាំប៉ូវកម្លាំងដែលជំរុញឲយើងមានភាពរត់ធ្មត់ និងមានការព្យាយាមដើម្បីយកឈ្នះការលំបាកឲទៅដល់គោលដៅ។

ឪពុកម្ដាយគ្មានមរតកដែលជាទ្រព្យសម្បត្តិឲកូនទេ ឬមានឲក៏មិនច្រើនណាស់ណាដែរ ប៉ុន្តែកូនទទួលបានកម្លាំងកាយកម្លាំងចិត្តទៅហើយ ដោយប្រើកម្លាំងកាយនោះតស៊ូទៅ ស៊ូនឹងការងារ ស៊ូនឹងជីវិត ធុនក៏ស៊ូ ស្រាលក៏ស៊ូ ហើយកុំមានការរួញរា កុំខ្ជិលច្រអូស និងកុំទម្រើសខ្លួន ឬដេករង់ចាំវាសនា ដោយបើសិនជាធ្វើបាននោះ ថ្ងៃណាមួយកូនប្រាកដជាអាចងើបឡើងក្លាយជាអ្នកមានយ៉ាងមានក្ដីសុខ និងសប្បាយរីករាយ។

www.elibraryofcambodia.org

# ៦១.កុំទាន់អាលអស់សង្ឃឹម

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សគ្រប់គ្នាត្រូវតែរស់នៅដោយមានក្ដីសង្ឃឹម ទោះបីពិបាកយ៉ាងណាក៏ដោយ ក៏នៅតែសង្ឃឹមថា ថ្ងៃណាមួយនឹងសម្រេចតាមបំណងប្រាថ្នាបានដើម្បីស្រួលដូចគេឯង ហើយបើសិនជាមានក្ដីសង្ឃឹម ទោះបីជារស់ចាំឆ្នាំកន្លះក៏ចាំបានដែរ ប៉ុន្តែទម្រាំតែបានសម្រេចនោះ ពិតជានឿយហត់ស្ទើរតែត្រូវកំណាយទៅហើយ។

បើសិនជាកូនចង់ប្រាថ្នាអ្វីទុក ប៉ុន្តែមិនបានសម្រេចបំណងពិតនោះ កុំទាន់អាលឆ្អែតអស់សង្ឃឹមជាមុនអី ដោយអ្នកដែលគេសម្រេចតាមបំណងនោះ ពីព្រោះមកពីគេមិនចេះអស់សង្ឃឹម មិនចេះដើរថយក្រោយ ចេះតែដើរទៅមុខរកសេចក្ដីសង្ឃឹមរហូត ទើបបានជាសម្រេចបំណងរបស់គេ។

កូនប្រហែលជាធ្លាប់ឮខ្លះហើយ ដោយព្រះពុទ្ធបានត្រាស់សម្ដែងថា **មនុស្សយើងឆ្លងផុតទុក្ខបាន ពីព្រោះតែសេចក្ដីព្យាយាម** នោះគឺពិតប្រាកដណាស់កូនសម្លាញ់អើយ ! ការខុសឆ្គង ការបរាជ័យដែលយើងជួបប្រទះ កុំបែរធ្វើឲ្យយើងអស់សង្ឃឹមទាំងអស់នោះទេ ដោយហេតុណាដែលយើងនៅមិនទាន់អស់សង្ឃឹមនោះ ប្រាកដជាមានថ្ងៃណាមួយនឹងបានសម្រេចតាម

www.elibraryofcambodia.org

ដោយដូចជាពាក្យចាស់បុរាណតែងតែពោលថា បើសិនដួលចក្រោកឈរ មានន័យថា ពេលដែលយើងដួលផ្លោះផ្លោយនោះ ត្រូវតែក្រោកឈរតស៊ូជាថ្មី ដោយមានតែអ្នកក្រោកឈរឡើងតស៊ូនោះទេ ទើបនឹងអាចទៅដល់គោលដៅបាន ហើយពេលដែលយើងដួលនៅលើផ្លូវ ហេតុអ្វីយើងត្រូវដេកនៅបែបនោះ ហេតុអ្វីយើងមិនប្រញាប់ក្រោកឡើង ហើយបន្តដើរទៅមុខទៀត។

ដូចគ្នានឹងពេលដែលយើងមានឧបសគ្គ ឬក៏ជួបនឹងការរស់តស៊ៀរ ហេតុអ្វីយើងមិនធ្វើចិត្តឲ្យបានរឹងមាំ និងរួសរាញ់ខ្លួនឯងចេញពីភាពរស់សង្សៀរនោះ ហើយក្រោកឈរឡើងដកដង្ហើមឲ្យបានស្រួលបួល រួចឈានដើរទៅមុខដោយភាពជឿជាក់ ដោយមានសតិបញ្ញា និងមានការប្រយ័ត្នប្រយែងជាងមុន ប្រើកំហុសឆ្គងដែលមានកន្លងមក ជាគ្រូសម្រាប់ដាស់តឿន មកជាធ្វើជាមេរៀន ដើម្បីកុំឲ្យមានការខុសឆ្គងបែបនោះទៀត ហើយទាំងអាចឈានទៅមុខដោយភាពជឿជាក់ និងកម្លាំងចិត្តដែលរឹងមាំនោះ។

www.elibraryofcambodia.org

# ៦២.ការជួយដល់ខ្លួនឯង

កូនសម្លាញ់របស់ពុកម៉ែអើយ !

ការជួយដល់ខ្លួនឯងនោះជារឿងមួយល្អ កូនត្រូវតែព្យាយាមធ្វើនូវអ្វីៗដោយខ្លួនឯង របស់របរប្រើប្រាស់កន្លែងផ្ទាល់ខ្លួន បើសិនជាអាចបោសសម្អាតដោយខ្លួនឯងបាន ក៏គួរធ្វើទៅ រួមទាំងការចំអិនអាហារ ការទៅណាមកណា ឬស្ទើរតែការងារផ្សេងៗ បើសិនអាចធ្វើដោយខ្លួនឯងបាន គឺជាការល្អណាស់កូនណា

កូនរៀនហាត់ចេះធ្វើសិនទៅ ពេលណាដែលយើងចេះហើយនោះ ថ្ងៃក្រោយបើប្រើអ្នកផ្សេងធ្វើ ឲ្យគេធ្វើជំនួសក៏បានដែរ ដោយហេតុថាតែយើងចេះសិនទៅ បើសិនជាពេលណាគ្មានមនុស្សមកធ្វើឲ្យយើងទេ យើងក៏អាចធ្វើបានដោយខ្លួនឯង យើងអាចជួយដល់ខ្លួនឯងបាន មិនបាច់រកអ្នកជួយគាំ ដោយចាំគេមកជួយនោះទេ

ការជួយខ្លួនឯងបាន គឺជាការបង្ហាញពីសមត្ថភាពដំបូងរបស់មនុស្សយើង គ្រាន់តែជួយដល់ខ្លួនឯងមិនបានផង តើអាចទៅជួយដល់អ្នកណាបានទៅ ដោយសារមនុស្សយើងចាំបាច់ត្រូវតែលត់ដំធ្វើអ្វីមួយដោយខ្លួនឯងជាមុនសិន ជាពិសេសរឿងកិច្ចការផ្ទាល់ខ្លួន ហើយមិនរញ្ជៀងទេត្រូវខិតខំព្រោះ

www.elibraryofcambodia.org

បំណងប្រាថ្នារបស់យើងជាមិនខាន ហើយបើសិនអស់សង្ឃឹមហើយនោះ ពិតនឹងអស់សង្ឃឹមរហូតទៅ។

ដូចដែលបានធ្លាប់ប្រាប់ដល់កូនមកហើយថា បើសិនជាដួលត្រូវតែក្រោកឈរវិញ ខុសញឹកញាប់ ដួលញឹកញាប់ ទោះបីធ្វើឲយើងឈឺខ្លួន និងរួញរាក៏ដោយ ប៉ុន្តែក៏ធ្វើឲ្យយើងកាន់តែមានភាពរឹងមាំឡើង ហើយពេលដែលយើងរឹងមាំហើយនោះ ថ្ងៃក្រោយមិនងាយខុស មិនងាយនឹងដួលទេ ដោយការតាំងខ្លួនបានស្ថិតស្ថេរ តាំងចិត្ត តាំងសតិ ហើយទន្ទេញថា ស៊ូៗ ក៏ធ្វើឲចិត្តរបស់យើងកើនភាពរឹងមាំឡើង ពេលដែលចិត្តរឹងមាំហើយនោះ រាងកាយរបស់យើងក៏ព្រមតស៊ូដើរទៅមុខ រកសេចក្តីសង្ឃឹមបានជានិច្ច ហើយនៅថ្ងៃណាមួយគង់តែទៅដល់គោលនោះទេ។

នៅពេលដែលយើងដោះជំហានមិនឈប់ បើសិនជានៅសង្ឃឹម និងឆ្ពោះទៅមុខជារៀងរហូតនោះ ថ្ងៃណាមួយគង់តែបានសម្រេច ខំតស៊ូទៅណា កូនសម្លាញ់អើយ ! ។

www.elibraryofcambodia.org

# ៦៣.គុណបុណ្យនៃផលវិបាក

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពុកម៉ែក៏ដូចគ្នានឹងអ្នកទាំងអស់គ្នាដែរ ក្រៅអំពីមិនចង់ឲ្យខ្លួនពិបាកហើយនោះ ក៏នៅមិនចង់ឲ្យកូនរបស់ខ្លួនឯងពិបាកផងដែរ ដោយគ្មានឪពុកម្តាយណាដែលចង់ឲ្យកូនរបស់ខ្លួនពិបាកនោះទេ ឬក៏ក្រនោះទេ ប៉ុន្តែពេលខ្លះក៏ធ្វើឲ្យកូនពិបាកដូចគ្នាដែរ ពីព្រោះតែឪពុកម្តាយមិនអាចធ្វើឲ្យកូនសុខស្រួលបានគ្រប់យ៉ាងទេ ប៉ុន្តែកូនគួរតែដឹងថា ផលវិបាកនោះមិនមែនជាការពិសពុលតែម្យ៉ាងដែលធ្វើឲ្យមនុស្សយើងត្រូវតែពិបាកនោះទេ ដោយផ្ទុយទៅវិញគុណតម្លៃ ឬប្រយោជន៍នៃផលវិបាកនោះក៏មានដែរ គឺផលវិបាកបានធ្វើឲ្យមនុស្សយើងមានភាពរឹងមាំ ពូកែឡើង និងធ្វើឲ្យមនុស្សយើងចេះគិត ធ្វើឲ្យចាស់ទុំជាងមុន បង្រៀនឲ្យមនុស្សចេះជួយការពារខ្លួនឯង ពង្រឹងដើម្បីរស់នៅបន្តទៀត។

មានមនុស្សជាច្រើនដែលទទួលបានផលល្អពីផលវិបាក ដោយគេប្រកាន់ភ្ជាប់ជាមួយពាក្យមួយឃ្លាថា **នឿយមុន ស្រណុកក្រោយ** ប្រៀបបានដូចដែលយើងដួលហើយ ប្រឹងក្រោកឈរឡើងបាក់ស្ទើរស្លាប់ ប៉ុន្តែពេលដែលជួបរឿងលំបាកយូរៗទៅ បែរជាមើលឃើញផ្លូវដែលឆ្ពោះទៅរកភាព

www.elibraryofcambodia.org

របស់គេមកដកដង្ហើមរហូត ដោយការខ្ចីច្រមុះអ្នកផ្សេងមកដកដង្ហើមនោះ គឺបានស្រួលម្តងម្កាលនោះទេ បើសិនជាគ្មានច្រមុះអ្នកផ្សេងមកដកដង្ហើមនោះទេ ហើយច្រមុះខ្លួនឯងក៏ដកដង្ហើមមិនស្រួលទៀតនោះ លទ្ធផលដែលនឹងទទួលបាន គឺខ្លួនឯងនោះហើយដែលពិបាក និងធុញទ្រាន់មួម៉ៅដោយេការជួយដល់ខ្លួនឯងបែបនេះតាមទ្រឹស្តីព្រះពុទ្ធសាសនា លោកហៅថា **ខ្លួនទីពឹងខ្លួន** ដោយលោកបានប្រៀនប្រដៅថា គឺព្យាយាមពឹងខ្លួនឯងឲបានច្រើន កុំគិតតែពឹងពាក់អ្នកដទៃរហូតនោះ។

កូនក៏ត្រូវតែព្យាយាមធ្វើអ្វីៗឲបានដោយខ្លួនឯង ពឹងផ្អែកលើខ្លួនឯងហើយបើសិនពិតជាធ្វើពុំបានមែន ចាំពឹងអ្នកដទៃ ដោយកុំជំពាក់គេគ្រប់បែបយ៉ាងអី ពេលនោះកូននឹងធំធាត់រីកចម្រើន ហើយឈរដោយខ្លួនឯងយ៉ាងរឹងមាំដើម្បីតស៊ូជាមួយនឹងពិភពលោកដ៏លំបាកនេះបានគ្រប់យ៉ាង។

www.elibraryofcambodia.org

# ៦៤.គូតស៊ូដ៏ពិតប្រាកដ

កូនសម្លាញ់របស់ពុកម៉ែអើយ !

នៅក្នុងការងារគ្រប់បែបយ៉ាង តែងតែមានការប្រណាំងប្រជែងតស៊ូ ហើយការពិបាកខុសៗគ្នា ដែលកើតចេញពីឧបសគ្គនៅក្នុងរៀងធ្វើការ ហើយអ្នកដែលធ្វើការបានសម្រេចនោះ គឺជាអ្នកដែលឆ្លងកាត់ឧបសគ្គ ខ្លះធ្ងន់ ខ្លះស្រាល ប៉ុន្តែមិនមែនគ្រប់គ្នា សុទ្ធអាចពុះពារឧបសគ្គនោះសម្រេចបានគ្រប់គ្នានោះទេ។

ការដែលមនុស្សយើងអាចពុះពារឆ្លងកាត់ឧបសគ្គទៅបាន ក៏ដោយសារតែការតស៊ូជាមួយនឹងឧបសគ្គនោះផងដែរ មិនមែនអាចឆ្លងកាត់បានដោយការគេចវេះ ឬការលោតផ្លោះ ដូចជាផ្លោះរបងនោះទេ ប៉ុន្តែយើងត្រូវតែចូលទៅដល់ឧបសគ្គនោះ ដែលប្រៀបដូចជាការជិះទូកកាត់រលក ឬដើរកាត់ព្យុះ កាត់ភ្លៀងអញ្ចឹងដែរ ទើបយើងអាចឆ្លងកាត់រលក កាត់ព្យុះភ្លៀងទៅបានដូចគ្នា។

តាមការពិតការតស៊ូជាមួយឧបសគ្គមិនពិបាកទេ បើសិនយើងបានតស៊ូយកឈ្នះចិត្ត និងកម្លាំងចិត្តរបស់យើងជាមុនសិន នោះចិត្ត និងកម្លាំងចិត្តរបស់យើងហ្នឹងហើយដែលចាត់ទុកថា ជាគូតស៊ូពិតប្រាកដរបស់យើង

www.elibraryofcambodia.org

សប្បាយ ហើយគេបានសប្បាយយ៉ាងពិតប្រាកដនៅពេលអនាគត ហើយផ្ទុយទៅវិញអ្នកដែលធ្លាប់បានស្រណុកស្រួលមកពីកំណើត មិនស្គាល់នូវការលំបាក ដល់ពេលដែលមានរឿងពិបាកកើតមានឡើងស្ទើរតែជួយដល់ខ្លួនមិនបាន ធ្វើអ្វីក៏មិនចេះ ចាប់អ្វីក៏មិនបាន ទម្រាំតែអាចជួយខ្លួនឯងបានជីវិតជិតនឹងឈានចូលភាពយ៉ាប់យ៉ឺនទៅហើយ។

ដូច្នេះ កូនអើយ! កុំខ្លាចភាពពិបាកអី ត្រូវចាត់ទុកថា ភាពពិបាកជាព្រួជាកម្រៃនៃជីវិត និងជាមេរៀនដែលយើងគួរចងចាំ ហើយក៏កុំបែរទៅមើលវាទៀតអី។

www.elibraryofcambodia.org

# ៦៥.វិធីសាស្ត្រទប់ស្កាត់ទុក្ខ

កូនសម្លាញ់របស់ពុកម៉ែអើយ !

រាងកាយដែលមានភាពមាំមួន មិនអាចមានរោគមកបៀតបៀនបានដោយងាយទេ គេហៅថាមានប្រព័ន្ធការពារ ឬវិធីការពារ ហើយវិធីការពារបែបនេះ ជាវិធីការពារទុក្ខខាងផ្លូវកាយ ដែលធ្វើឲ្យរាងកាយបានសុខស្រួល ដូចគ្នានេះដែរ បើសិនមិនចង់ឲ្យកើតមានទុក្ខទេ ក៏ត្រូវសាងប្រព័ន្ធការពារផ្លូវចិត្តឲ្យបានល្អ។

តាមការពិតទុក្ខខាងផ្លូវចិត្តនោះ មានមូលហេតុមកពីការនឹកគិត ការស្រមើស្រមៃនៅក្នុងចិត្តរបស់ខ្លួនឯងជាសំខាន់ ដោយចិត្តបានទៅប្រមូលរឿងរ៉ាវផ្សេងៗមកពីការបានឃើញខ្លះ ពីការបានឮខ្លះហើយមកគិតឲ្យជារឿងនោះ រឿងនេះ តាមអារម្មណ៍របស់ខ្លួនឯង ហើយរឿងដែលនឹកគិតនោះ បើសិនជាខ្លួនឯងមានអារម្មណ៍ចូលចិត្ត គឺនឹងមានសេចក្ដីសុខ ឬបើសិនជាមានអារម្មណ៍មិនចូលចិត្តទេ គឺនឹងពិបាកចិត្ត ដោយរឿងតែមួយទេដែលអាចធ្វើមនុស្សម្នាក់សប្បាយចិត្ត ប៉ុន្តែធ្វើឲ្យមនុស្សម្នាក់ទៀតពិបាកចិត្តបាន វាស្ថិតនៅលើការគិតរបស់មនុស្សម្នាក់ៗនោះទេ។

www.elibraryofcambodia.org

ហើយការតស៊ូជាមួយទឹកចិត្ត និងកម្លាំងចិត្តខ្លួនឯងនេះ ពិបាកជាងតស៊ូជាមួយឧបសគ្គផ្សេងៗនៅខាងក្រៅទៅទៀតដូចជា ក្តៅរងារ ព្យុះភ្លៀង និងអ្វីផ្សេងៗជាដើម។

ការតស៊ូយកឈ្នះទឹកចិត្តរបស់ខ្លួនឯងនោះ គឺយើងត្រូវមានសតិជានិច្ចកុំរាថយ ត្រូវតែមានកម្លាំងចិត្ត មិនត្រូវអស់កម្លាំងចិត្តជាមុនឡើយ ដោយពេលណាដែលតស៊ូជាមួយនឹងចិត្តខ្លួនឯងរហូតបានឈ្នះ និងមានកម្លាំងចិត្តហើយនោះ ក៏អាចតស៊ូជាមួយឧបសគ្គខាងក្រៅបានដែរ ហើយការពុះពារឆ្លងកាត់នោះទទួលបានផលល្អទៀតផង ប៉ុន្តែបើសិនជាយកឈ្នះចិត្តរបស់ខ្លួនឯងដោយមិនបានពុះពារឧបសគ្គដ៏សំខាន់ ដោយការខ្ជិលច្រអូសដោយភាពរាថយ និងការអស់កម្លាំងចិត្ត មិនបានទេនោះ តើយើងនឹងអាចទៅពុះពារជាមួយឧបសគ្គអ្វីទៅ ? ដោយព្រះពុទ្ធទ្រង់បានទូន្មានថា តស៊ូយកឈ្នះចិត្តរបស់ខ្លួនឯងជាមុនសិន នោះយើងនឹងអាចយកឈ្នះអ្វីៗគ្រប់យ៉ាងនៅលើលោកនេះបាន។

www.elibraryofcambodia.org

# ៦៦.ភាពមានះរឹងរូស

កូនសម្លាញ់របស់ពុកម៉ែអើយ !

នៅក្នុងការរស់នៅជាមួយគ្នា មិនថានៅរវាងមិត្តភក្តិ ឬក៏រវាងស្វាមី ភរិយានោះឡើយ តែងតែកើតនូវរឿងអ្វីមួយមកជ្រៀតជ្រែកជានិច្ច ដោយ របស់នោះ គឺជាការយល់ច្រឡំលើគ្នាដែលវាជារឿងធម្មតា បើសិនជាប្ដី ប្រពន្ធវិញនោះ កាន់តែឆាប់បែកបាក់ពីគ្នាជាងមិត្តភក្តិទៅទៀត កុំភ្លេច ថាការយល់ច្រឡំ គឺជាការយល់ខុសពីការពិត វាជាអារម្មណ៍ឆេវឆាវមួយ ពេល ជាការយល់ឃើញតែម្នាក់ឯង ដែលការពិតមិនមែនបែបនោះឡើយ ដោយខ្លួនយល់ឃើញតែម្នាក់ឯងជាត្រឹមត្រូវ ទើបបានជាហៅថា **ការយល់ច្រឡំ**។ អ្នកដែលយល់អ្វីខុសៗតែងតែមានភាពមានះរឹងរូស មិនព្រមស្ដាប់ តាមអ្នកណាឡើយ គិតថា ខ្លួនឯងជាអ្នកត្រូវម្នាក់គត់ អ្នកផ្សេងមិនយល់ពី ចិត្តរបស់ខ្លួនឯង ទើបធ្វើទៅធ្វើមកកាន់តែមានរឿងធំ ត្រូវឈ្លោះប្រកែកគ្នា មិនព្រមអត់ឱនឲ្យគ្នា ហើយនៅទីបំផុតក៏បែកបាក់គ្នាមើលមុខគ្នាមិនចំ។

កូនគួរតែចងចាំទុកថា ភាពមានះរឹងរូស ដោយសារតែមានការយល់ ច្រឡំនោះ មិនដែលផ្ដល់ផលប្រយោជន៍ទៅដល់អ្នកណាម្នាក់ឡើយ មាន តែធ្វើឲ្យមានការបែកបាក់ មានភាពមិនសប្បាយចិត្តទាំងសងខាង។

www.elibraryofcambodia.org

ដូច្នេះ បើសិនជាកូនមិនចង់ឲ្យទុក្ខមកបៀតបៀនដល់កូនទេ កូនគួរតែព្យាយាមកសាងប្រព័ន្ធការពារ ដោយត្រូវតាំងសតិឲ្យបានល្អ ហើយបើសិនជាជួបប្រទះនឹងរឿងអ្វីក៏ដោយ បើសិនជាចោលបានក៏ចោលទៅ បើសិនជាទុកបាន ក៏ទុកទៅ កុំយកមកគិតស្រមើស្រមៃ កុំយកមកទុកនៅក្នុងអារម្មណ៍ ដោយបើសិនចង់ស្រមើស្រមៃត្រូវគិតយ៉ាងមានសតិ ហ្មត់ចត់ឲ្យបានច្បាស់លាស់ជាមុនសិន កុំទាន់អាលសម្រេចចិត្តយ៉ាងងាយៗថាជាបែបនេះ បែបនោះ ហើយមកអង្គុយសប្បាយចិត្តតាមការគិតនោះ ត្រូវតែមានចិត្តអំណត់ឲ្យបានល្អ។

ចិត្តដែលមានភាពអំណត់ មានសតិ មានបញ្ញា នោះហើយ ជាប្រព័ន្ធការពារទុក្ខយ៉ាងល្អ ប៉ុន្តែក៏មិនងាយស្រួលធ្វើបានផងដែរ ត្រូវតែហ្វឹកហាត់ជាញឹកញាប់ ហើយប្រើពេលវេលាយូរទើបឃើញលទ្ធផល ដោយវាក៏ដូចគ្នានឹងរាងកាយដែរ ទម្រាំតែរឹងមាំ រហូតមានប្រព័ន្ធការពារមេរោគបាននោះ ត្រូវចំណាពេលយ៉ាងយូរ។

www.elibraryofcambodia.org

# ៦៧.ប្រភពនៃការបង្កើតកម្លាំងចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

ធ្លាប់បានប្រាប់ដល់កូនរួចមកហើយ **កម្លាំងចិត្ត** គឺជាកម្លាំងខាងក្នុង ដែលធ្វើឲមនុស្សយើងមានភាពរឹងមាំ អត់ធ្មត់ មិនចុះចាញ់ងាយ និង ព្រមទាំងព្យាយាមតស៊ូបន្តទៀតដោយភាពជឿជាក់ ហើយបើសិនមនុស្សយើងអស់កម្លាំងចិត្ត ឬកម្លាំងចិត្តធ្លាក់ចុះនោះ ពេលខ្លះរហូតទាល់តែមិនចង់បានជីវិតរស់នៅទៀតផង ចង់ស្លាប់ឲផុតៗទៅ ដោយសូម្បីតែអ្នករឹងមាំហើយក្តី បើសិនជាអស់កម្លាំងចិត្តនោះ ដៃជើង និងខួរក្បាលក៏អស់កម្លាំងទៅជាមួយផងដែរ អាចដល់ថ្នាក់គិតផ្តេសផ្តាសថា ត្រូវធ្វើដើម្បីអ្វី បើសិនជាធ្វើហើយមិនបានការ មិនបានផលបែបផងនោះ។

អ្នកជំងឺ បើសិនជាមានកម្លាំងចិត្តល្អ ក៏អាចឆាប់ជាបានដែរ ប៉ុន្តែ បើសិនជាអស់សង្ឃឹមចិត្តនោះ ក៏បណ្តាលឲស្លាប់បានភ្លាម បើសិនជាដឹងបែបនេះហើយ គួរតែរកកម្លាំងចិត្តល្អៗមកដាក់ក្នុងខ្លួនទៅ ដោយកម្លាំងចិត្តនេះអាចកើតបានឡើងពីប្រការ២យ៉ាងគឺ ខ្លួនឯងធ្វើឲកើតមាន និងអ្នកដទៃធ្វើឲកើតមាន ហើយប្រការទាំង២យ៉ាងនេះ គឺខ្លួនឯងក៏អាចពង្រឹងកម្លាំងចិត្តដោយខ្លួនឯងបាន ដោយបន្ថែមចំណេះដឹង និងសមត្ថភាពដល់

www.elibraryofcambodia.org

ជាស្វាមីភរិយានឹងគ្នា ជាមិត្តភ័ក្តិនឹងគ្នា បែរជាមានគំនិតមានះរឹងរូស មានគំនិតយល់ឃើញប្រកាន់នឹងគ្នា មិនងាកមុខរកគ្នា មិននិយាយតាមសម្រួល ហើយបង្កើតភាពសប្បាយចិត្តជាមួយនឹងគ្នាវិញ តើវាមិនប្រសើរជាងទេឬ? ។

www.elibraryofcambodia.org

# ៦៨.ការគុំគួនសងសឹក

កូនសម្លាញ់របស់ពុកម៉ែអើយ !

កូនប្រហែលធ្លាប់បានមើលភាពយន្តរឿងបែបកង្វ៉ាងធាតុហើយ វាជាប្រភេទអ្នកពិភពគុនសងសឹកគ្នាទៅវិញទៅមក ពីព្រោះគេប្រកាន់ភ្ជាប់នូវពាក្យថា គំនុំត្រូវតែសងសឹក ដោយនៅទីបំផុតក៏មានរបួស និងស្លាប់ទាំងសងខាង នោះគ្រាន់តែជាភាពយន្តនោះទេ ដោយអ្នកនិពន្ធចង់ឲ្យយើងបានយល់ថា គំនុំ និងការសងសឹកនោះមិនល្អនោះទេ វាជាការពិតណាស់កូន គំនុំជារឿងដែលមិនល្អពិតប្រាកដណាស់។

បើសិនកូនទៅកេនគំនុំជាមួយនឹងអ្នកណា ឬអ្នកណាធ្វើឲ្យកូនទើសចិត្តនោះ ទោះបីជាធ្ងន់ធ្ងរយ៉ាងណា បើសិនអាចទ្រាំបានកំទ្រាំទៅ កុំទៅយកចិត្តទុកដាក់នឹងរឿងគំនុំនោះអី វាមានតែធ្វើឲ្យយើងស្មុគស្មាញរសាប់រសល់នៅមិនបានសុខ នៅមិនស្ងប់ ហើយខាតពេលវេលាទៅដោយគ្មានប្រយោជន៍នោះទេ។

គំនុំដូចជាភ្លើង វាអាចដុតបំផ្លាញចិត្តគំនិតរបស់យើងឲ្យក្តៅក្រហាយគ្រប់ពេលវេលា ធ្វើឲ្យយើងឈ្លក់វង្វេងជាមួយការគុំគួនជានិច្ច ព្រមទាំងជាមេភ្លើងបំផ្លាញពេលវេលា និងសេចក្តីសុខនៅក្នុងជីវិត គ្រួសាររបស់យើង

www.elibraryofcambodia.org

ខ្លួនឯង ម្ចាស់ការលើខ្លួនឯង រួមទាំងធ្វើឲមានជំនឿចិត្ត និងភាពជឿជាក់លើខ្លួនឯង ទាំងនេះដែលធ្វើឲមានកម្លាំងចិត្តតស៊ូដោយខ្លួនឯង។

ក្រៅពីនោះគួរតែខិតខំធ្វើអំពើល្អ ធ្វើរឿងដែលមានប្រយោជន៍ទុកឲបានច្រើន ដោយរភាពជាមនុស្សល្អ និងជាភាពជាមនុស្សមានប្រយោជន៍នឹងធ្វើឲយើងគិតថា យើងក៏អន់ជាងអ្នកដទៃដែរ ហេតុអ្វីបានជាយើងត្រូវរួញរាអស់សង្ឃឹមគ្មានកម្លាំងចិត្ត គ្រាន់តែភាពខុសឆ្គងធ្វើការមិនបានផលសម្រេចនោះ។

បើសិនជាជឿជាក់ ហើយគិតបែបនេះ ក៏នឹងអាចកើតមានជាកម្លាំងចិត្តដែលអាចធ្វើការបាន ហើយការធ្វើអំពើល្អជារឿយៗ ដោយមិនចាំបាច់រង់ចាំឲអ្នកដទៃមកផ្តល់កម្លាំងចិត្តក៏បានដែរ ដោយហៅថា ជាម្ចាស់ការលើខ្លួនឯងបាន។

www.elibraryofcambodia.org

# ៦៩.ភាពត្រឹមត្រូវ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សយើងទោះបីជា មាន ឬក្រ យ៉ាងណាក្តី ទោះបីជាលំបាកយ៉ាង ណាក៏ដោយ ជីវិតក៏ត្រូវតែមិនស្ទុះស្ទារដែរ ហើយទោះបីជាកើតនៅជាតិនរ ឋានព្រហ្ម ជីវិតក៏មានទុក្ខលំបាកផងដែរ ដោយអ្នកក្រ អ្នកមាន សុទ្ធតែ មានទុក្ខលំបាកទាំងអស់ គ្រាន់តែទុក្ខម្យ៉ាងម្នាក់តែប៉ុណ្ណោះ ហើយគ្រប់គ្នា ត្រូវប្រកបកិច្ចការផ្សេងៗ ដូចគ្នាល្អខ្លះ មិនល្អខ្លះផ្លាស់ប្តូរគ្នា ប៉ុន្តែសូមឲ្យកូន ចាំទុកថា នៅក្នុងផ្លូវជីវិតរបស់យើងនោះ កុំធ្វើតែអំពើអាក្រក់អី ពីព្រោះ នឹងកើតគ្រោះថ្នាក់ដល់ខ្លួនឯង និងសង្គម គួរតែធ្វើរឿងដែលត្រឹមត្រូវ និង រក្សាភាពត្រឹមត្រូវទុកខ្លះផង។

ការដែលធ្វើរឿងត្រឹមត្រូវ និងរក្សាភាពត្រឹមត្រូវបាន ទុកថាជាអំពើ ល្អ ដោយការធ្វើអំពើល្អបែបនេះ ទោះបីជាមានឧបសគ្គ និងមានគ្រោះថ្នាក់ ច្រើនក៏ដោយ អាចរាំងឲ្យមានភាពអស់កម្លាំងចិត្តដែលនឹងធ្វើបន្តទៀត ក៏ គួរតែលះបង់ តាំងសតិ តាំងចិត្តឲ្យច្បាស់ ពុះពារឧបសគ្គទាំងនោះដើម្បី រក្សាភាពត្រឹមត្រូវឲ្យបានគង់ ហើយឲ្យភាពត្រឹមត្រូវនោះសម្រេចបានផល។

www.elibraryofcambodia.org

ផងដែរ។

កូនសម្លាញ់អើយ ! អ្នកណាមកធ្វើឲយើងខឹង បើសិនកាត់ចិត្តបាន ក៏កាត់ទៅ បើសិនជាអត់ទោសឲបានក៏អត់ទៅ យើងនឹងសប្បាយចិត្ត និង សុខភាពចិត្តក៏មិនខូតដែរ ដោយការគិតចង់តែសងសឹកដើម្បីឲរំសាយគំនុំ ដើម្បីសប្បាយចិត្តនោះ ពេលខ្លះវាធ្វើឲយើងមានសេចក្ដីសុខតែមួយគ្រា ប៉ុណ្ណោះ ហើយលទ្ធផលពីការសងសឹកនោះ អាចធ្វើឲយើងរងទុក្ខវេទនា អស់មួយជីវិតក៏ថាបានដែរ ដូចជា សងសឹកហើយត្រូវត់គេច ចូលក្នុង សង្គមមិនបាន សងសឹកហើយខ្លួនឯងត្រូវទៅដេកគុក១០ ឬ២០ឆ្នាំ និង អាចឫយជីវិតក៏ថាបាន ដោយមើលទៅមិនសមនឹងតម្លៃជីវិតសោះ។

នៅក្នុងការពន្លត់ភ្លើងគំនុំឲបាននោះ ស្ថិតនៅលើការអភ័យទោសឲ ស្ថិតនៅលើការរំសាយគំនុំ មិនមែនស្ថិតនៅលើការសងសឹកទេ ហើយបើ សិនជាភ្លើងគំនុំមិនទាន់រលត់ ក៏ពិបាករកសេចក្ដីសុខក្នុងជីវិតបានដែរ។

www.elibraryofcambodia.org

# ៧០. កុំត្រចៀកស្រាលពេក

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលណាដែលកូនបានធ្វើធំ ជាប្រធាន ឬជាអ្នកគ្រប់គ្រងអ្នកដទៃ កូនត្រូវមានការប្រុងប្រយ័ត្នបំផុតចំពោះរឿងមួយដែលសំខាន់បំផុតនោះ គឺ **កុំត្រចៀកស្រាល** មានន័យថា កុំជឿអ្នកដទៃងាយៗ កុំទាន់អាលកាត់សេចក្តី មុននឹងមានការពិចារណាត្រឹមត្រូវចំពោះ ដោយពាក្យសម្តី ពាក្យណែនាំ ដែលអ្នកផ្សេងយកមកនិយាយឲ្យស្តាប់នោះ ត្រូវតែស្តាប់ត្រចៀកម្ខាង ទុកត្រចៀកម្ខាង ប្រើសតិពិចារណាឲ្យច្បាស់លាស់ ជាពិសេសសម្តីរបស់អ្នកជិតស្និទ្ធ រឹតតែត្រូវប្រយ័ត្នបន្តិច ពីព្រោះតែអ្នកដែលត្រចៀកស្រាលត្រូវវិនាសដោយសារតែអ្នកជិតស្និទ្ធច្រើនណាស់មកហើយ។

មិនមែនមិនឲ្យមានការទុកចិត្តលើអ្នកជិតស្និទ្ធនោះទេ គ្រាន់តែប្រាប់ឲ្យមានប្រយ័ត្នប៉ុណ្ណោះ ដោយពេលខ្លះអ្នកដែលស្និទ្ធស្នាលជាមួយយើង ឬអ្នកដែលបកនិយាយប្រាប់ទាំងនោះ អាចនឹងមានផែនការខ្ចីដៃយើងទៅកម្ចាត់សត្រូវរបស់គេ ឬទៅដើរទៅលើកតម្កើងមិត្តភក្តិរបស់គេក៏ថាបាន ឬក៏គ្នារបស់យើងទៅមានរឿងជាមួយនឹងអ្នកផ្សេង ហើយក៏ខ្ចីដៃរបស់យើងទៅធ្វើបាបអ្នកផ្សេងក៏ថាបានផងដែរ។

www.elibraryofcambodia.org

មួយជីវិតរបស់មនុស្សយើង ទោះបីជាសាងបាបកម្មទុកមកជាច្រើន ទោះបីជាត្រូវសង្គមប្រមាថមើលត្រភាលថា ជាមនុស្សអាក្រក់ថោកទាប ឬជាអ្នកក្រីក្រយ៉ាងណាក៏ដោយ ក៏គង់តែមានថ្ងៃណាមួយគេធ្វើនូវរឿងដែលមានភាពត្រឹមត្រូវ ហើយរក្សាភាពត្រឹមត្រូវនោះទុក ដោយធ្វើបានតែម្តង ក៏ចាត់ទុកជា មានអំពើល្អខ្លះដែរ មិនមែនអាក្រក់ទាំងអស់នោះទេ ហើយបើសិនរឿងដែលធ្វើនោះមានតម្លៃខ្ពស់ទៀតនោះ ក៏កាន់តែគួរឲកោតសរសើរទៅទៀត ក៏អាចដល់ថ្នាក់លុបបំបាត់ភាពក្រីក្រចាស់ៗចោលបានទាំងអស់ទៀតផង។

ដូច្នេះ សូមឲកូនចងចាំទុកទៅថា បើសិនមានឱកាសធ្វើរឿងដែលត្រឹមត្រូវ ធ្វើបានក៏ធ្វើទៅ ទោះបីជាពិបាកយ៉ាងណា ចូរកូនព្យាយាមធ្វើឲបានដើម្បីជាគ្រឿងសម្អាងសម្រាប់តុបតែងកាយចិត្ត ធ្វើឲមានសេចក្តីសុខពេលដែលធ្វើវា។

www.elibraryofcambodia.org

# ៧២.កុំធ្វើជាមនុស្សគ្មានទឹកចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

គេថាមនុស្សយើងត្រូវរស់នៅជាមួយគ្នាជាពួកជាក្រុម កូនក៏ត្រូវនៅជាមួយអ្នកដទៃ ត្រូវមានបក្សពួកជួយដល់គ្នាទៅវិញទៅមក ហើយពេលណាដែលកូននៅជាមួយអ្នកដទៃ កូនកុំធ្វើជាមនុស្សគ្មានទឹកចិត្តអី ដោយកុំមើលតែប្រយោជន៍ផ្ទាល់ខ្លួនអី ចូរធ្វើអ្វីដែលអាចជួយដល់អ្នកដទៃបាន ហើយសូមកូនចាំសម្តីចាស់បុរាណការពោលថា «នៅផ្ទះគេកុំនៅស្ងៀមឈរឱបដៃមើល ត្រូវចេះជួយធុរការសាអ្នកដទៃផង»។

គតិនេះពោកចង់ណែនាំឲយើងក្លាយជាមនុស្សដែលមានទឹកចិត្ត កុំអង្គុយស្ងៀមឈរឱបដៃមើល ដោយមនុស្សដែលគ្មានទឹកចិត្តនោះ តែងតែជួយដល់អ្នកផ្សេង ធ្វើអ្វីៗមានប្រយោជន៍ដល់អ្នកដទៃ និងសង្គមមិនសូវបាននោះទេ ដែលជារឿងតូចតាចធ្វើបានដោយងាយ ប៉ុន្តែក៏មិនធ្វើ គិតតែយកប្រៀបលើអ្នកដទៃ ហើយមិនព្រមចុះចាញ់ប្រៀបអ្នកណាឡើយ។

ចំណែកមនុស្សដែលមានទឹកចិត្ត គឺជួយស្រេចឡះពីក្នុង ជាមនុស្សមិនអាត្មានិយម ជួយអ្វីគេបានក៏ជួយ ទោះបីជាមើលទៅចាញ់ប្រៀបគេ ក៏មិនគិតអ្វីនោះដែរ ហើយកើតជាមនុស្សនៅសង្គមណាក៏ដោយកូន ទើបត្រូវ

www.elibraryofcambodia.org

# ៧១.ប្រយ័ត្ននឹងពាក្យសម្ដីផ្អែម

កូនសម្លាញ់របស់ពុកម៉ែអើយ !

ទោះបីចាស់បុរាណធ្លាប់បានពោលទុកថា «**ទឹកឃ្មុំខែប្រាំងសែនផ្អែមយ៉ាងណា ក៏នៅតែចាញ់សម្ដីផ្អែមរបស់មនុស្សផងដែរ**» ដូច្នេះកូនគួរតែចេះប្រយ័ត្នជាមួយពាក្យតវ៉ារបស់អ្នកដទៃ ជាពិសេសតវ៉ាផ្អែមរបស់មនុស្សខ្លះ ដោយទឹកអំពៅទឹកត្នោត ជាទឹកផ្អែម ទុកយូរទៅក៏អាចក្លាយទៅជាទឹកស្រវឹងបានដែរ ហើយពាក្យសម្ដីផ្អែមរបស់អ្នកខ្លះ ក៏អាចធ្វើឲយើងស្រវឹងបានដូចគ្នាផងដែរ ដោយពេលដែលស្រវឹងហើយ ក៏ធ្វើឲយើងវង្វេងភ្លេចខ្លួនគ្មានសតិ ចាញ់បោកគេ ពេលខ្លះអាចអស់ទាំងមាសប្រាក់ ទាំងដៃរមិនគួរឲអស់ផងនោះ ពីព្រោះតែជឿទៅលើសម្ដីផ្អែមៗរបស់គេ។

ប្រការនេះ សូមឲកូនពិចារណាឲបានល្អ អ្នកណាមកនិយាយស្ដីតវ៉ាផ្អែម បកសរសើរដល់យើងល្អបែបនេះ ល្អកែបែបនោះ កូនត្រូវតែប្រយ័ត្នប្រយែង កុំអាលទៅជឿជាក់លើសម្ដីគេភ្លាមៗនោះ ទើបកូននឹងមិនសោកស្ដាយនៅពេលក្រោយ ដោយត្រីដែលស្លាប់ភាគច្រើន ត្រូវបានគេបញ្ឆោតឲស៊ីចំណី ហើយបើសិនជាវាមិនស៊ីចំណីគេទេ វាក៏មិនស្លាប់ដែរ ដោយរឿងនេះ ទើបមនុស្សយើងត្រូវគេល្បួងលោម ហើយស្លាប់ដូចជាត្រី។

www.elibraryofcambodia.org

# ៧៣. ភាពលោភលន់

កូនសម្លាញ់របស់ពុកម៉ែអើយ !

ដើមឈើដែលដុះលើភ្នំ ទោះបីជាដើមឈើតូចល្អិតយ៉ាងណាក៏ដោយ ក៏នៅតែខ្ពស់ជាងដើមឈើធំៗនៅតាមជើងភ្នំដែរ ហើយទោះបីជាបែបនេះក៏ដោយ ដើមឈើនៅជើងភ្នំនោះអាចមានតម្លៃជាងដើមឈើនៅលើភ្នំក៏បានដែរ។

ការដែលលើកយករឿងដើមឈើមួយនេះមកនិយាយ ដើម្បីឲ្យកូនគិតពិចារណាថា ភាពមានមហិច្ឆតាចង់ធ្វើខ្លួនឯងឲ្យស្មើភាពជាមួយនឹងអ្នកមានយសស័ក្តិ ដែលគេជាអ្នកមានតាំងពីកំណើត ឬពីបុព្វបុរសនោះ ជាហេតុធ្វើឲ្យកើតមានទុក្ខ សោកស្តាយពេលដែលមិនសមតាមបំណងប្រាថ្នា។

កូនមិនគួរគិតមានមហិច្ឆតាបែបនេះទេ ពីព្រោះការគិតមានមហិច្ឆតាហួសពីសមត្ថភាពរបស់យើងនោះ វាអាចធ្វើមនុស្សយើងភ្លេចខ្លួន ហ៊ានធ្វើអាក្រក់ ហ៊ានធ្វើខុស ប៉ុន្តែការដែលមនុស្សយើងខំឧស្សាហ៍ព្យាយាមកសាងខ្លួនខំធ្វើការឲ្យមានជីវភាពស្ថិតស្ថេរ ឲ្យមានអំពើល្អ និងមានតម្លៃជាងអ្នកដទៃ គឺប្រៀបដូចជាដើមឈើធំនៅជើងភ្នំដែលគ្មានផលអាក្រក់ ឬមិនសមត្រង់ណានោះទេដែលល្អណាស់ ដោយកូនគួរតែធ្វើខ្លួនបែបនេះ វាប្រសើរ

www.elibraryofcambodia.org

រៀនធ្វើជាមនុស្សមានទឹកចិត្តទៅ កុំធ្វើជាមនុស្សគ្មានទឹកចិត្តអី ដោយដូចជាឃើញអ្វីនៅរាយប៉ាយតាមផ្លូវដើរ ដែលធ្វើឲកូនក្មេង ឬមនុស្សព្រុជាន់បណ្តាលឲដួលគ្រោះថ្នាក់ ក៏យកទៅបោះចោលទៅ ឬក៏បើកឡានតាមផ្លូវបើសិនជាឃើញឡានគេបត់នោះ ឲគេបត់មុនចុះ ទាំងអស់នេះជាការមានទឹកចិត្តហើយ។

រឿងតូចតាចៗបែបនេះ មិនពិបាកធ្វើនោះទេ ប៉ុន្តែមិននាំគ្នាធ្វើនោះពីព្រោះតែគ្មានទឹកចិត្តមែនទេ ! ហើយទាំងនេះ គឺជាឧទាហរណ៍សម្រាប់ឲកូនឃើញតែប៉ុណ្ណោះ។

www.elibraryofcambodia.org

# ៧៤.ការរិះគន់ តិះដៀល

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលដែលមានមនុស្សមកបន្ទាប ឬក៏សរសើរដល់យើងនោះ ត្រូវតែតាំងសតិឲ្យបានល្អ កុំបណ្តោយទៅតាមសម្តីរបស់គេឲ្យសោះ ឬបើសិនជាគេបន្ទោស ឬសរសើរ យើងក៏សាកគិតមើលថា យើងអាក្រក់ថោកទាប ដូចជាគេថាដែរឬទេ បើសិនជាបែបនោះមែនក៏មិនគួរខឹងនឹងគេដែរ។

បើសិនមិនពិតនោះទេ ក៏ពិតថាគេមិនទាន់ស្គាល់យើងច្បាស់ ដោយរឿងរ៉ាវកើតលោលាលមិនចំផងដែរ ហើយបើសិនយើងល្អដូចជាគេនិយាយសរសើរមែន ក៏បញ្ជាក់ថាគេពិតជាស្គាល់យើងមែន។

បើគិតបាន អាចធ្វើចិត្តបែបនេះបាន ក៏គ្មានអារម្មណ៍គិតពីនេះពីនោះ នៅពាក្យបន្ទោស ពាក្យសរសើររបស់អ្នកដទៃឡើយ ដោយពាក្យបន្ទោសសរសើរគ្រាន់តែជាពាក្យសម្តីចូលមកហើយ ក៏កន្លងហួសទៅ វាធ្វើឲ្យយើងល្អ ឬអាក្រក់មិនបាននោះទេ ហើយបើសិនអ្នកណាឈ្លក់វង្វេងជាមួយនឹងពាក្យសម្តីគេកោតសរសើរ គឺមានតែជាមនុស្សឆ្កួតនោះទេ។

www.elibraryofcambodia.org

ជាងទៅមានចិត្តមហិច្ឆតាលើរបស់ដែលពិបាកយក ឬមិនអាចឡួចនោះ។

មានដើមឈើនៅជើងភ្នំមិនប៉ុន្មានដើមទេកូនអើយ ! ដែលត្រូវគេប្តូរយកទៅដាំនៅលើភ្នំ ហើយបែកមែកសាខាបានល្អនោះ ដោយដើមឈើធម្មតាៗគ្រាន់តែដុះលូតលាស់បានធំនៅជើងភ្នំនោះ ក៏ជាការល្អណាស់ទៅហើយ ហើយអ្វីដែលក្រាក់បំផុតនោះគឺ ដើមឈើដែលដុះលើដីរាបដែលទាបស្រាប់ទៅហើយ នៅតែមិនព្រមធំ បែកបែកសាខា ចេញផ្កា ចេញផ្លែបាននោះ គឺហេនតែត្រូវគេជិះជាន់ថែមទៀតឯណោះកូន។

www.elibraryofcambodia.org

# ៧៦.មនុស្សមាត់អាក្រក់

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សខ្លះគេអាចនិយាយស្តីស្តាប់ទៅមិនចូលត្រចៀកនោះទេ ត្រង់ទៅត្រង់មក មាត់ និងចិត្តដូចគ្នា ដោយអ្នកស្តាប់តែងតែមិនចូលចិត្ត ប៉ុន្តែមនុស្សបែបនេះ ត្រូវតែមើលឲ្យបានជ្រៅឲ្យបានឆ្ងាយ ពីព្រោះតែគេជាមនុស្សល្អអាចរាប់អានជាមួយបាន ដោយនៅក្នុងប្រភេទ**មនុស្សមាត់អាក្រក់** គឺមានលក្ខណៈដូចជាថ្នាំល្វីង បើតាមធម្មតាថ្នាំល្វីង ជាថ្នាំដែលល្អមានប្រយោជន៍ ដូចជាពាក្យចាស់បុរាណតែងតែពោលថា មនុស្សស្មោះត្រង់តែងតែនិយាយស្តីមិនចូលត្រចៀក ប៉ុន្តែនឹងមានប្រយោជន៍ទៅថ្ងៃក្រោយ ប្រៀបបានជាថ្នាំល្អដែលល្វីងជាប់មាត់ តែងតែមានប្រយោជន៍ចំពោះអ្នកជំងឺនៅពេលក្រោយផងដែរ។

ផ្ទុយទៅវិញ មនុស្សខ្លះនិយាយស្តីពីរោះ ប៉ុន្តែនឹងអាចនាំគ្រោះថ្នាក់ចំពោះយើងបាន ព្រោះតែហេតុនេះការសម្រេចចិត្តថា អ្នកណាល្អ ឬមិនល្អដោយមើលទៅលើពាក្យសម្តីរបស់គេតែម្យ៉ាងនោះ មើលទៅជាការប្រថុយនឹងការខុសឆ្គងខ្លាំងណាស់ ដោយរឿងដែលសំខាន់ គឺកូនត្រូវតែគិត និងពិចារណាតាមសម្រួល មើលសម្តី និងចិត្តរបស់គេដូចគ្នាដែរឬទេ ថាគេជាមនុស្សប្រភេទ មនុស្សមាត់អាក្រក់ ឬផ្អែមដូចជាស្ករ ឬក៏ជាប្រភេទថ្នាំពុល ត្រូវមើលឲ្យបានច្បាស់ជាមុនសិន។

www.elibraryofcambodia.org

# ៧៥.ជីវិតមានតម្លៃ

កូនសម្លាញ់របស់ពុកម៉ែអើយ !

កូនមានដឹងដែរទេ របស់ដែលមានតម្លៃជាងគេនោះគឺ **ជីវិត** មិនថាជាជីវិតរបស់យើង ឬរបស់អ្នកណាទេ សុទ្ធតែមានតម្លៃដូចគ្នាទាំងអស់ មានតម្លៃទាំងសម្រាប់ខ្លួនឯង និងសម្រាប់អ្នកដទៃដែរ ដោយដូច្នេះហើយ នៅក្នុងសីលប្រាំ ទើបលោកយករឿងការហាមសម្លាប់សត្វជាចំណុចទី១ ពីព្រោះយល់ឃើញថា ជីវិតជាការសំខាន់នោះហើយ ទើបមិនគួរសម្លាប់ មិនគួរបៀតបៀនជីវិតទេ ពេលណាដែលកូនដឹងថា ជីវិតមានតម្លៃបែបនេះហើយ ទើបគួរថែរក្សា និងការពារឲ្យបានល្អ។

ភាពកតញ្ញូចំពោះខ្លួនឯងដែលបានប្រាប់មកនោះ ជាការចេះថ្នាក់ថ្នមជីវិតម្យ៉ាង ហើយម្យ៉ាងវិញទៀត គឺជាការព្យាយាមប្រើជីវិតឲ្យមានតម្លៃ ដោយការធ្វើនូវរឿងដែលមានប្រយោជន៍ចំពោះខ្លួនឯង និងចំពោះអ្នកដទៃឲ្យបានច្រើនបំផុត ហើយបែបនេះទើបគេហៅថា រស់នៅយ៉ាងមានតម្លៃ មិនមែនរស់នៅដោយឥតប្រយោជន៍ គិតតែពីដើរលេងស៊ីផឹកសប្បាយរកផលប្រយោជន៍ពីជីវិតមិនបាននោះទេ ដោយជីវិតដែលមានតម្លៃនោះ គឺជាការប្រើជីវិតទៅតាមផលប្រយោជន៍នោះទេ។

www.elibraryofcambodia.org

# ៧៨.ឱសថព្យាបាលចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានឈ្មោះជាគេរកក្ដីទុក្ខហើយនោះ ព្រោះគ្មានអ្នកណាម្នាក់នឹងប្រាថ្នាចង់បាននោះទេ ដោយមនុស្សទាំងឡាយ គឺសុទ្ធតែមានក្ដីទុក្ខផ្សេងៗទាំងអស់ តិច ឬច្រើនក្ដីត្រូវតែមាន ហើយព្រះពុទ្ធបានថា ទុក្ខមាន២យ៉ាង គឺទុក្ខផ្លូវកាយ និងទុក្ខផ្លូវចិត្ត ដោយទុក្ខផ្លូវកាយអាចបំបាត់ដោយអាហារ គ្រឿងស្លៀកពាក់ កន្លែងស្នាក់អាស្រ័យ និងថ្នាំសង្កូវ ប៉ុន្តែទុក្ខផ្លូវចិត្តវិញត្រូវដោះស្រាយដោយព្រះធម៌ ព្រះធម៌ជាថ្នាំព្យាបាលខាងផ្លូវចិត្ត ជាថ្នាំប៉ូវជំនួយដល់បេះដូង ជាទីពឹងខាងផ្លូវចិត្ត។

មនុស្សដែលមានទុក្ខខាងផ្លូវកាយ ពេលដែលបានចំណីអាហារមកព្យាបាលក៏ជាសះស្បើយ ប៉ុន្តែទុក្ខខាងផ្លូវចិត្តត្រូវប្រើព្រះធម៌មកព្យាបាល ដោយអ្នកដែលអត់មិនឃើញពីការពិតនៃរឿងនេះ ពេលដែលមានក្ដីទុក្ខខាងផ្លូវចិត្តក៏កើតមានទុក្ខធ្ងន់ តែម្ដង រអ៊ូរទាំ បន្ទោសនេះនោះ ហើយចំណែកអ្នកដែលមានព្រះធម៌ ហើយបានប្រតិបត្តិតាមនោះ នឹងមានប្រព័ន្ធការពារទុក្ខខាងផ្លូវចិត្តបានល្អជាងមនុស្សធម្មតា ទោះបីជាជួបជាមួយទុក្ខក៏អាចជួយរំសាយទុក្ខខ្លួនឯងបានដែរ ហើយអាចរកសេចក្ដីសុខបាន ដោយសូម្បីតែក្នុងពេលមានទុក្ខក៏ដោយ។

www.elibraryofcambodia.org

# ៧៧.មើលមនុស្សនៅក្នុងផ្លូវល្អ ឬផ្លូវអាក្រក់

កូនសម្លាញ់របស់ពុកម៉ែអើយ !

មុននឹងកូនកោតសរសើរ ឬទទួលស្គាល់អ្នកណាម្នាក់ថា ជាមនុស្សល្អនោះ កូនត្រូវមើលឲបានច្បាស់ឲប្រាកដជាមុនសិន ដោយមើលឲបានយូរ កុំឃើញតែសម្បកក្រៅ ដូចជាគិតថា គេម្នាក់នោះល្អចំពោះយើង គេជួយដល់យើង ឬគេនិយាយស្តីល្អចំពោះយើង ហើយយើងក៏យល់ថាគេជាមនុស្សល្អ។

តាមការពិតអ្នកដែលល្អចំពោះយើងនោះ មិនមែនមានន័យថា គេជាមនុស្សល្អនោះទេ ដោយតាមការពិតដែលគេល្អចំពោះយើងនោះ គេអាចមានបំណងអ្វីមកលើយើង ឬយើងអាចធ្វើនូវអ្វីជារបស់ដែលគេត្រូវការឲគេបាន ឬក៏យ៉ាងហោចណាស់ យើងមិនបានទៅរាំងផលប្រយោជន៍អ្វីរបស់គេនោះទេ ហើយគេល្អចំពោះយើងជាការធម្មតានោះដែរ។

មនុស្សល្អពិតនោះ ត្រូវល្អចំពោះយើង និងអ្នកដទៃដូចគ្នាដែរ ហើយដូចតែគ្នាទេ គេល្អចំពោះអ្នកផ្សេង ប៉ុន្តែមិនល្អចំពោះយើង ក៏មិនមែនមានន័យថា គេជាមនុស្សមិនល្អផងដែរ ហើយការដែលលើកយករឿងមួយនេះមកនិយាយ គឺដើម្បីឲកូនបានដឹងទុកជាមុន ដើម្បីកុំឲជឿមនុស្សងាយៗ ទើបមិនចាញ់បោកគេ ហើយមិនទៅមួលបង្កាច់អ្នកណាងាយៗថា គេជាមនុស្សមិនល្អ ។

www.elibraryofcambodia.org

ជីវិតខ្លះផង ដើម្បីឲ្យមនុស្សជំនាន់ក្រោយគេនិយាយដល់ពីរឿងរ៉ាវមានមោទនភាព ពោលគឺបើសិនជាកូនមិនបានធ្វើ តំណែង និងតួនាទីនោះនឹងធ្វើឲ្យកូនបាត់បង់ឱកាសមាស ហើយអាចធ្វើឲ្យខូចមនុស្សដោយមិនដឹងខ្លួនក៏ថាបានដែរ។

www.elibraryofcambodia.org

# ៧៩.ឱកាសមាសប្រាក់

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សខ្លះកោនរំណាច វាសនា មានបារមីខ្ពស់ មានឱកាសរង្គុយនៅកន្លែងខ្ពស់ ដែលនឹងអាចធ្វើឲមានប្រយោជន៍ និងអានភាពរីកចម្រើនដល់សង្គមជាតិបានច្រើនណាស់ ប៉ុន្តែ បើសិនជាមិនបានធ្វើទៅវិញ ពិតជាធ្វើឲបាត់បង់ឱកាសមាសប្រាក់នោះយ៉ាងគួរឲសោកស្តាយណាស់ ហើយរឿងដែលគេមិនបានធ្វើ ពីព្រោះតែគេមិនបានគិតពីបញ្ហានេះទេ គេគិតតែពីតំណែង និងតួនាទីដែលខ្លួនទទួលបាននោះជាកិត្តិយស និងកេរ្តិ៍ឈ្មោះសម្រាប់រូបគេដែលជាផ្លូវនាំមកនូវផលប្រយោជន៍ដល់ខ្លួន ទើបបានជាគេព្យាយាមរក្សាកិត្តិយសរក្សាតែផលប្រយោជន៍តែប៉ុណ្ណោះ។ តាមការពិតបើសិនជាគេប្រើឱកាសមាសប្រាក់ក្នុងពេលនោះ ធ្វើរឿងល្អៗឲដល់សង្គមជាតិទុកជាអនុស្សាវរីយ៍ក្នុងមួយជីវិតនោះ កិត្តិយស និងប្រយោជន៍របស់គេនឹងជិតជាប់រហូត ទោះបីជាអស់តំណែងនោះហើយក៏ដោយ ក៏នៅមានមនុស្សនិយាយដល់ដោយការគោរពសរសើរផងដែរ។

សម្រាប់កូនបើសិនមានឱកាសបាននូវឋានៈ មានបារមីខ្ពស់បែបនោះកុំភ្លេចខ្លួន ត្រូវឆក់ឱកាសមាសនោះ បង្កើតស្នាដៃជាអនុស្សាវរីយ៍សម្រាប់

www.elibraryofcambodia.org

បើសិនកូនដឹងបែបនេះហើយ គួរតែរៀនធ្វើខ្លួនឲ្យទៅជាមនុស្សមានការទទួលខុសត្រូវ ដោយវិធីរៀនមិនពិបាកនោះទេ គឺចាប់ផ្ដើមពីការដាស់តឿនខ្លួនឯងឲ្យបានជាមុនសិន ហើយដាស់តឿនដល់ខ្លួនឯងថា នេះគឺជាតួនាទីរបស់យើង ជាការងាររបស់យើង ជារឿងរបស់យើងដែលខ្លួនយើងត្រូវតែធ្វើ ហើយពេលដែលយើងធ្វើក៏ព្យាយាមធ្វើឲ្យបានល្អបំផុត ធ្វើឲ្យអស់ពីកម្លាំងកាយ កម្លាំងចិត្តដែលយើងមាន និងខិតខំឲ្យអស់ពីសមត្ថភាពរបស់យើង ដោយលទ្ធផលដែលទទួលបានប្រាកដជាធ្លាក់លើខ្លួនយើង។

កូនត្រូវដាស់តឿនដល់ខ្លួនឯងបែបនេះជានិច្ច ដោយការទទួលខុសត្រូវក៏ចាប់ផ្ដើមកើតឡើងចំពោះកូន យូរៗទៅ កូននឹងក្លាយជាមនុស្សដែលមានការទទួលខុសត្រូវដែលល្អប្រសើរជាមិនខានឡើយ។

www.elibraryofcambodia.org

# ៨០.ភាពទទួលខុសត្រូវ

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលដែលកូនធ្វើការរបស់ខ្លួនឯង ឬក៏ត្រូវបានគេប្រគល់អ្វីមួយឲធ្វើនោះ រឿងដែលកូនគួរតែគិតដល់ និងមានការប្រកាន់ភ្ជាប់ជានិច្ចនោះ គឺការទទួលខុសត្រូវ ហើយរបស់ដែលហៅថា ការទទួលខុសត្រូវនោះគឺ ការដែលមានចិត្តព្យាយាម មានភាពស្មោះត្រង់នឹងការងារ ធ្វើឲបានសម្រេចទៅដោយល្អ មានរបៀបរៀបរយ និងទាន់តាមពេលវេលាកំណត់ ដោយមិនចាំបាច់ឲអ្នកណាស្តីបន្ទោស មកបង្ខំឲធ្វើនោះទេ ត្រូវតែប្រាប់ខ្លួនឯងជានិច្ចថា នោះជាការងារដែលយើងត្រូវធ្វើ។

ចំពោះអ្នកដែលធ្វើបែបនេះបានគេហៅថា គឺជាមនុស្សដែលមានការទទួលខុសត្រូវខ្ពស់ ដោយអ្នកណាៗក៏ចង់បានគេផងដែរ ហើយមនុស្សបែបនេះដែរ មានភាពរីកចម្រើនបានលឿនជាងមនុស្សគ្មានការទទួលខុសត្រូវឆ្ងាយណាស់ ពីព្រោះមនុស្សដែលគ្មានការទទួលខុសត្រូវ គឺជាមនុស្សដែលមិនយកចិត្តទុកដាក់លើតួនាទីការងាររបស់ខ្លួន ឬជាមនុស្សដែលធ្វើការបែបមិនពេញចិត្ត ឬក៏មិនចង់ធ្វើ។

www.elibraryofcambodia.org

# ៨២.ការឈឺចាប់នៅក្នុងចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលខ្លះពុកម៉ែកំពុងធ្វើអ្វី ឬនិយាយអ្វីមួយចំពោះកូនធ្ងន់ធ្ងរនោះ ក៏អាចធ្វើឲ្យកូនមិនពេញចិត្តខ្លះដែរ ប៉ុន្តែសូមឲ្យកូនយល់ថា ទោះបីយ៉ាងណាក៏ពុកម៉ែនៅតែស្រឡាញ់ដល់កូនជានិច្ច ដោយកូនជាកែវភ្នែក ជាបេះដូងរបស់ពុកម៉ែរហូតទៅ ហើយពេលដែលកូនសម្លឹងមើលពុកម៉ែ ដោយការខឹងក្នុងចិត្តនោះ ឬមិនរវល់ជាមួយពុកម៉ែដូចជាអ្នកដទៃនោះ ពុកម៉ែពិតជាមានអារម្មណ៍ខ្លោចផ្សារ និងឈឺចាប់ណាស់។

អ្នកផ្សេងទៀតមើលស្រាល មើលងាយ ឬយល់ច្រឡំលើពុកម៉ែយ៉ាងណានោះ ក៏មិនឈឺដូចជាកូនមើលស្រាល ឬយល់ច្រឡំលើពុកម៉ែផងដែរ ហើយបើសិនជាកូនស្អប់ពុកម៉ែ ក៏ព្រោះតែការមិនពេញចិត្ត មិនចូលចិត្តនូវរឿងដែលពុកម៉ែធ្វើនៅពេលខ្លះនោះ ពុកម៉ែក៏អាចទ្រាំបានដែរ ប៉ុន្តែបើសិនជាស្អប់ខឹង ព្រោះតែកូនមិនយល់ដល់ចិត្ត និងអារម្មណ៍ពិតប្រាកដរបស់ពុកម៉ែនោះទេ ពុកម៉ែពិតជាខ្លោចផ្សារឈឺចាប់ក្នុងចិត្តខ្លាំងណាស់កូន។

www.elibraryofcambodia.org

# ៨១.សតិ

កូនសម្លាញ់របស់ពុកម៉ែអើយ !

នៅក្នុងចំណោមគុណធម៌ ឬអំពើល្អដែលមនុស្សយើងគួរតែមានការបដិបត្តិនោះគឺ **សតិ** ដោយសតិជាអ្វីដែលមានភាពអស្ចារ្យបំផុត នោះមានន័យថា សតិជាអ្វីដែលមានភាពសំខាន់បំផុត សតិជាការភ្ញាក់រឭក និងនឹកឃើញរួមផ្សំនឹងការភ្ញាក់ខ្លួនជានិច្ច មិនភ្លេចភ្លាំងឡើយ។ ការដែលចង់និយាយស្តីក៏ដោយ ត្រូវតែគិតមុខ គិតក្រោយឲបានច្បាស់ជាមុនសិន គិតឲបានច្បាស់លាស់ កុំឆេវឆាវ កុំឆាប់រហ័សពេក ទើបមិនកើតមានការខុសឆ្គង និងមិនថ្លោះធ្លោយ ដោយទោះបីខុសឆ្គងក្តីក៏ខាតបង់តិចដែរ ពីព្រោះយើងបានគិតពិចារណាច្បាស់មកហើយ ហើយការគិតយ៉ាងច្បាស់លាស់នេះហើយ គឺជាសតិនេះឯង។

ដូច្នេះ កូនគួរតែតាំងសតិឲបានល្អទៅ ដោយគិតទុកជាមុនជានិច្ចថា ថ្ងៃនេះយើងនឹងធ្វើអ្វីខ្លះ ថ្ងៃស្អែកយើងនឹងធ្វើអ្វីខ្លះ ? ទាំងនេះជាការរៀបចំផែនការទុកជាមុននោះអី ហើយនេះក៏ជាលក្ខណៈរបស់សតិដែរ ហើយអ្នកដែលមានសតិ មិនភ្លេចភ្លាំង មិនខុសឆ្គង ដោយគោរពតាមពេលវេលាជានិច្ច ក៏តែងតែទទួលបានផលល្អជានិច្ចដែរ ហើយក៏ខុសពីមនុស្សដែលគ្មានសតិ ដោយពេលដែលធ្វើអ្វីតែងតែមានការភ្លេចភ្លាំងខុសឆ្គង ធ្វើឲខូចខាតការងារមិនឈប់ ដែលគេហៅថា ជាមនុស្សដែលមិនចេះរក្សាសតិ។

www.elibraryofcambodia.org

មនុស្សដែលមានទឹកចិត្តបែបនេះហៅថា **មនុស្សមានចិត្តទូលាយ** ដោយសារមនុស្សដែលមានចិត្តទូលាយតែងតែបានគេរាប់អានជាច្រើន ដោយសារជួយពីគ្នាជាប្តូរ មនុស្សគ្មានចិត្ត ហៅថា **មនុស្សចិត្តចង្អៀត** ជាមនុស្សគ្មានមិត្តភ័ក្តិទេ ពេលដែលមានការលំបាកម្តងៗ ចង់ពឹងគេអត់ជួយនោះ គឺពិបាកណាស់ ត្រូវកែតម្រូវដោយខ្លួនឯង។

ពេលដែលកូនដឹងរឿងនេះហើយ សូមកូនធ្វើជាមនុស្សដែលមានចិត្តទូលាយ កុំធ្វើជាមនុស្សមានចិត្តចង្អៀតអី ហើយបើសិនជាមានរឿងអាចជួយដល់គេបានក៏ជួយទៅ កុំបែរធ្វើមើលមិនឃើញអី អ្នកណាពិបាកអ្វី បើសិនជាជួយគេបានក៏ជួយទៅ ទោះតិចណាស់ក៏ជួយផ្តល់កម្លាំងចិត្តគេដែរ ដូចជាទៅលេង ទៅមើលគេ ឬទៅលួងចិត្តគេក៏ល្អផងដែរ ដោយសារមនុស្សយើងពេលដែលមានទុក្ខ បានឃើញគេមកមើល មកលេងនោះ ក៏មានកម្លាំងចិត្តតស៊ូទៅមុខបានដែរ។

កើតមកជាមនុស្ស មិនមែនមានសេចក្តីសុខតាមបំណងប្រាថ្នារហូតទៅជានិច្ចនោះទេ អាចមានថ្ងៃណាមួយយើងត្រូវមានទុក្ខដែរ ដោយពេលថ្ងៃនោះមកដល់ យើងនឹងដឹងថា ទឹកចិត្តពីបងប្អូន មិត្តភ័ក្តិនោះ ជាថ្នាំព្យាបាលដ៏វិសេសសម្រាប់ឲ្យយើងកក់ក្តៅ និងមានសង្ឃឹមប៉ុណ្ណានោះ។

www.elibraryofcambodia.org

# ៨៣.ចិត្តទូលាយ ចិត្តចង្អៀត

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានមនុស្សខ្លះ ទោះបីជាក្រ ប៉ុន្តែក៏មានញាតិច្រើនណាស់ ហើយពេលដែលមានការរវល់អ្វីនោះ ក៏មានមនុស្សមកជួយគ្រប់បែបយ៉ាង រឿងពិបាកក៏ក្លាយជារឿងងាយស្រួលផងដែរ ដោយឡែកចំណែកអ្នកខ្លះ ដែលមានទ្រព្យសម្បត្តិ មានយសស័ក្តិ ប៉ុន្តែបែរជាខ្វះសាច់ញាតិ ទោះបីជាគេមកហែហមក៏ជាពួកមិនអាចទុកចិត្តបាន មកជួយព្រោះឃើញផលប្រយោជន៍តែប៉ុណ្ណោះ មនុស្ស២ប្រភេទនេះ មិនពិបាករកទេក្នុងសង្គមបច្ចុប្បន្ននេះ។

តាមការពិតការមានគ្នីគ្នាជាការចាំបាច់ខ្លាំងណាស់ បើសិនពួកយើងនៅក្នុងសង្គមត្រូវធ្វើការជាមួយគ្នានោះ ប្រាកដជាទាក់ទងគ្នាដោយវិធីមួយហើយរបស់ដែលធ្វើឲមនុស្សយើងមានមិត្តភ័ក្តិរាប់អាននឹងគ្នាពិត និងមានភាពស្មោះត្រង់ចំពោះគ្នាគឺ ការមានទឹកចិត្តចំពោះគ្នា មានការជួយយកអាសា និងព្រួយបារម្ភនឹងគ្នា ដោយពេលដែលមានការរវល់ចាំបាច់ត្រូវតែចេះជួយដល់គ្នាជានិច្ចដោយមិនចាំបាច់ទៅអង្វរ និងមានអ្វីត្រូវតែចេះចែកដល់គ្នា។

ផលកម្មរបស់ខ្លួនឯង ដោយមិនចាំបាច់មានអ្នកណាមកដាក់ទោសនោះទេ ពីព្រោះតែកម្មនោះជាអ្នកដាក់ទោសគេដោយខ្លួនឯង ធ្វើឲ្យគេចាញ់អំពើអាក្រក់របស់ខ្លួនឯងរហូតទៅ។

អ្នកដែលចាញ់អំពើអាក្រក់របស់ខ្លួនឯងនោះ ធ្វើអ្វី ក៏សម្រេច បាន ឧបសគ្គគ្រប់បែបយ៉ាង អ្វីដែលគួរបានក៏មិនបាន អ្វីដែលមិនគួរបាត់បង់ក៏បាត់បង់ទៅ ហើយទទួលបានតែអ្វីមួយៗនោះ ពិតជាពិបាកខ្លាំងណាស់។

អ្នកដែលចាញ់អំពើអាក្រក់របស់ខ្លួនឯង ពេលខ្លះក៏មិនដឹងខ្លួនទៀតថា ហេតុអ្វីទើបខ្លួនឯងក្លាយជាបែបនេះ ហើយបែរជាបន្ទោសដល់អ្នកដទៃ បន្ទោសព្រហ្មលិខិត បន្ទោសទេវតាទៅវិញ ដោយទាំងខ្លួនឯងជាអ្នកធ្វើសោះនោះ ទាំងនេះដោយសារតែខ្លួនឯងជាមនុស្សអកតញ្ញូ ជាមនុស្សប្រទូសរ៉ាយ និងជាមនុស្សរមិលគុណគេ។

www.elibraryofcambodia.org

# ៨៤.ការចាញ់អំពើអាក្រក់របស់ខ្លួនឯង

កូនសម្លាញ់របស់ពុកម៉ែអើយ !

ភាពកតញ្ញូនោះ តាមការពិតមិនចង់និយាយញឹកញាប់ពេកនោះទេ ខ្លាចកូនគិតថា ពុកម៉ែទាមទារភាពកតញ្ញូពីកូន ប៉ុន្តែចាំបាច់ត្រូវតែប្រាប់ ពីព្រោះវាមានផលល្អដល់ខ្លួនកូន ដោយអ្នកដែលគ្មានភាពកតញ្ញូចំពោះអ្នកមានគុណ ដូចជាឪពុកម្តាយ កន្លែងស្នាក់អាស្រ័យ ឬប្រទេសខ្លួននោះ ក៏ចាត់ទុកថា ជាមនុស្សចាញ់អំពើអាក្រក់របស់ខ្លួនឯង ហើយមិនអាចមានភាពរីកចម្រើនទៅមុខបានទេ ពីព្រោះតែគេជាមនុស្សអកតញ្ញូ ជាមនុស្សរមិលគុណ និងមានបាបធ្ងន់ខ្លាំងណាស់ ដូចជាព្រះពុទ្ធទ្រង់បានសម្តែងថា **«បានដេក ឬអង្គុយនៅក្រោមម្លប់ដើមឈើណា មិនគួរកាប់ដើម ស្លឹកមែកឈើនោះទេ ពីព្រោះអ្នកដែលប្រទូសរ៉ាយនឹងមិត្ត ជាមនុស្សបាប»**។ អ្នកដែលរមិលគុណនឹងដើមឈើដែលធ្លាប់ស្នាក់អាស្រ័យនោះ គឺលោកពោលថា ជាមនុស្សប្រទូសរ៉ាយនឹងមិត្ត ជាមនុស្សបាប ពីព្រោះបានបំផ្លាញដោយសូម្បីតែដើមឈើមានគុណចំពោះគេ ហើយចុះអ្នកវិញ បើសិនជាទៅរមិលគុណចំពោះអ្នកមានគុណ តើនឹងក្លាយជាមនុស្សបាប និងជាមនុស្សអាក្រក់យ៉ាងណាទៅ។ មនុស្សរមិលគុណនោះ តែងតែទទួលនូវ

www.elibraryofcambodia.org

បានច្បាស់ជាមុនសិនថា ពេលដែលសន្យាជាមួយនឹងគេហើយ តើយើងអាចធ្វើបែបនោះបានដែរឬទេ អាចមានរឿងនៅពេលក្រោយឬទេ? គិតឲបានច្បាស់ល្អិតល្អន់ជាមុនសិន ហើយបើគិតជាឃើញថា អាចធ្វើបាននោះចាំសន្យាជាមួយគេ ទើបជាមនុស្សត្រឹមត្រូវ និងមិនចាញ់បោកអ្នកណាងាយៗផងដែរ

មនុស្សយើង បើមិនជារក្សាពាក្យសម្ដីមិនបាននោះទេ តើអាចទៅរក្សាអ្វីបានទៀតទៅ ពីព្រោះតែសម្ដីនៅក្នុងខ្លួនរបស់យើងសោះក៏រក្សាមិនបានគង់វង្សផង ហើយតើរបស់ផ្សេងនៅខាងក្រៅ អាចនឹងរក្សាបានយ៉ាងម៉េចទៅ ដោយហេតុនេះ ទើបសូមឲកូនមានការពិចារណាឲបានច្បាស់មុននិយាយ មុននឹងពេលសន្យាជាមួយអ្នកណា និងកុំធ្វើជាមនុស្សងាយភ្លេចសម្ដីងាយៗ រក្សាពាក្យសច្ចៈឲល្អ ពីព្រោះមនុស្សដែលរក្សាពាក្យសច្ចៈបានទោះបីជាស្លាប់ទៅហើយ នៅតែមានគេសរសើរមិនដាច់ដែរ។

www.elibraryofcambodia.org

# ៨៥.ថែរក្សាពាក្យសម្ដី

កូនសម្លាញ់របស់ពុកម៉ែអើយ !

រឿងពាក្យសម្ដីនោះ ជារឿងដ៏សំខាន់មួយរបស់មនុស្ស ដោយយើងគួរតែមានការប្រយ័ត្នប្រយែងនូវសម្ដី ២ យ៉ាងគឺ មុនពេលនិយាយត្រូវគិតមុខក្រោយឲ្យច្បាស់ជាមុនសិន ហើយបើសិនជានិយាយទៅហើយត្រូវរក្សាពាក្យសម្ដីនោះទុក ពីព្រោះសម្ដីដែលនិយាយចេញទៅហើយ ជាចៅហ្វាយនាយជារបស់យើង ត្រូវបង្ខំឲយើងធ្វើតាម ដូចជាបានសន្យាអ្វី ជាមួយអ្នកណាម្នាក់ត្រូវធ្វើឲបានដូចដែលបានសន្យានោះ មិនថាត្រូវចំណាយពេលឬដើមទុន កម្លាំងប៉ុណ្ណានោះទេ ទោះបីជាត្រូវស្លាប់ក៏ព្រមដែរ ដើម្បីរក្សាពាក្យសម្ដីនោះៗ

រឿងពាក្យសម្ដីរបស់មនុស្សយើងគេប្រកាន់ខ្លាំងណាស់ បើសិនខូតរឿងពាក្យសម្ដីទៅហើយនោះ ទោះបីជាអ្វីផ្សេងល្អយ៉ាងណា ក៏អាក្រក់ទៅជាមួយផងដែរ ដែលដូចជាគេហៅថា អស់ប្រជាប្រិយភាពនោះអី ហើយក៏មានពាក្យចាស់បុរាណពោលថា មនុស្សគេយកសម្ដី ដំរីគេយកភ្លុតៗ

ដូច្នេះហើយ ពេលណាដែលកូនគិតថា ខ្លួនឯងត្រូវពិបាករក្សាពាក្យសម្ដី ក៏កុំទៅសន្យាជាមួយអ្នកណាងាយៗនោះអី ដោយចូរពិចារណាឲ

www.elibraryofcambodia.org

ចង់សួរថា សេចក្ដីសុខដែលមេគ្រួសារធនោះ ជាសេចក្ដីសុខពិត ឬក្លែងក្លាយ ប្រាកដជាឆ្លើយបានថា ជាសេចក្ដីសុខក្លែងក្លាយហើយ ដោយភរិយា និងកូននោះ ទទួលបានសេចក្ដីពិតប្រាកដនោះមកពីណា? គឺបានតែការឈឺចាប់ ទឹកភ្នែកហូរតក្បាលជង្គង់តែប៉ុណ្ណោះ តើសេចក្ដីសុខដែលពាក់ព័ន្ធនឹងភាពឯកានោះ ជាសេចក្ដីសុខពិតប្រាកដយ៉ាងម៉េចទៅ? ដោយកន្លែងដែលមានសេចក្ដីសុខពិតប្រាកដនៅក្នុងក្រុមគ្រួសារនោះ គឺជាក្ដីស្រឡាញ់ ភាពកក់ក្ដៅ និងការជួបជុំគ្នា ហើយចំណែករឿងលុយប្រាក់នោះ គ្រាន់តែជាគ្រឿងរួមផ្សំគ្នាតែប៉ុណ្ណោះ។

**«ស្វែងរកសេចក្ដីសុខពិតដល់គ្រួសារ ប្រសើរជាងរកសេចក្ដីសុខក្លែងក្លាយឲ្យគ្រួសារ ទើបចាត់ទុកថា ជាគ្រួសារដ៏ពិតប្រាកដមែន»។**

www.elibraryofcambodia.org

# ៨៦.សេចក្តីសុខពិត ឬសេចក្តីសុខក្លែងក្លាយ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សយើងសព្វថ្ងៃនេះ សុទ្ធតែខិតខំស្វះស្វែងរករកសប្រាក់ ទោះបីជាពេលរបេះព្រលប់ ពេលសម្រាកពេលយប់ ក៏បែកធ្វើការដើម្បីរកលុយផងដែរ ហើយក៏ពិតមែនហើយដែលថា មាសប្រាក់ជារបស់ដែលចាំបាច់សម្រាប់មនុស្សសម័យថ្មីនេះ ក៏ព្រោះតែលុយអាចទិញអ្វីៗគ្រប់យ៉ាងដែលខ្លួនត្រូវការបាន មិនថា របស់របរ កេរ្តិ៍ឈ្មោះ និងសេចក្តីសុខនោះឡើយ ដោយគេតែងតែនិយាយថា បើសិនមានលុយក៏មានសេចក្តីសុខគ្រប់បែបយ៉ាងហើយ ប៉ុន្តែត្រូវមើលឲ្យបានច្បាស់ថា សេចក្តីសុខនោះធ្លាក់លើអ្នកណា អ្នកទទួលបានសេចក្តីសុខពិតប្រាកដពីមាសប្រាក់នោះ។

នៅក្នុងគ្រួសារខ្លះ មេគ្រួសារគិតតែធ្វើការរកលុយមកឲ្យគ្រួសារ ដល់ថ្នាក់គ្មានពេលសម្រាប់គ្រួសារ បណ្តោយឲ្យប្រពន្ធកូននៅផ្ទះមើលថែគ្នាទៅវិញទៅមក ហើយមេគ្រួសារទៅមានប្រពន្ធចុងនៅខាងក្រៅផងដែរ ដោយបានត្រឹមតែផ្ញើលុយកាក់ឲ្យប្រពន្ធកូនចាយវាយរាល់ខែប៉ុណ្ណោះ និងយល់ថា ប្រពន្ធ និងកូន បើសិនមានលុយចាយ នឹងអាចមានសេចសុខហើយ។

www.elibraryofcambodia.org

ដែលគេល្អជាងតែប៉ុណ្ណោះ ហើយបើសិនជាអ្នកគ្រាន់បើជាងគេនោះ ចេះដឹងគ្រប់គ្រាន់ អារម្មណ៍ឈ្នានីសក៏មិនកើតបានឡើងដែរ។

ពេលដែលកូនដឹងបែបនេះហើយ កូនត្រូវតែប្រយ័ត្នអារម្មណ៍ប្រភេទនេះទៅ កុំឲ្យវាកើតមានឡើងបាន កូនត្រូវរៀនធ្វើជាមនុស្សទូលាយ ហើយមិនថាជាអ្នកផ្សេង ជាមិត្ត ឬសត្រូវ ទោះបីគេជាមនុស្សដែលយើងស្អប់ខ្ពើម ឬក៏មិនចូលចិត្តក៏ដោយ គេមានសិទ្ធិទទួលបានសេចក្តីនៅក្នុងរឿងផ្សេងៗដូចជាមនុស្សទូទៅ ដោយបើសិនជាយើងអរគេ និងជូនពរគេមិនបាននោះទេ ក៏ធ្វើជាមិនដឹងមិនឮ មិនចាំបាច់ទៅចាប់អារម្មណ៍គេទេ វាក៏ធ្វើឲ្យយើងសប្បាយចិត្តជាងដែលទៅច្រណែនឈ្នានីសនឹងគេ ឬរករឿងគេនោះ។

បើសិនការរើសអើងទៅឈ្នានីសគេ អ្នកដែលរងគ្រោះយ៉ាងពិតប្រាកដនោះ គឺជាយើងផ្ទាល់ មិនមែនជាគេនោះទេ ព្រោះរឿងអីដែលយើងទៅរកឃើញមកទុកក្នុងចិត្ត ធ្វើឲ្យក្តៅក្រហាយដោយឥតប្រយោជន៍ធ្វើអ្វី ទុកក៏មិនគេចចេញពីវា បើសិនបើលើកឃើញបែបនេះហើយ។

www.elibraryofcambodia.org

# ៨៧.ភ្លើងច្រណែន

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានអារម្មណ៍យ៉ាង ពេលដែលកើតមានឡើងចំពោះអ្នកណាហើយ ក៏ធ្វើឲ្យអ្នកនោះមានអារម្មណ៍ក្ដៅក្រហាយក្នុងចិត្ត មានភាពធុញទ្រាំ និងស្អុតស្អាញ ហើយអារម្មណ៍ទាំងនេះ គឺជាការច្រណែន ជាអាការៈខាងផ្លូវចិត្តដែលកើតមកពីការដែលឃើញអ្នកដទៃបានល្អ ឬមានភាពល្អជាងខ្លួន និងទ្រាំមិនបាននោះទេ បើសិនជាអ្នកល្អជាងសត្រូវនោះផង ឬជាគូប្រជែង ភាពច្រណែននិន្ទាក៏កាន់តែមានកម្លាំងច្រើនលើសដើមផងដែរ។

អ្នកដែលកេនភាពច្រណែននិន្ទា នឹងអស់សេចក្ដីសុខទៅដោយមិនដឹងខ្លួន ដោយឃើញអ្វីក៏ទើសមុខទើសភក់ ឆាប់ឆ្អៅ និងរករឿងមិនឈប់ឈរ មិនថាប្ដីប្រពន្ធកូនចៅក៏មិនលើកលែងផងដែរ។ ការអួតក៏ដែលឈ្នានីស គឺខ្លាំងក្លា ហើយក្ដៅក្រហាយណាស់កូនអើយ! រហូតដល់ថ្នាក់សម្លាប់គ្នាក៏មានផងដែរ ទើបគេប្រាប់ថាវាជាភ្លើង ជាភ្លើងនៃការឈ្នានីស នៅពេលដែលវាកើតឡើងហើយ វានឹងដុតរោលរាលដល់ចិត្តមនុស្សឲ្យក្ដៅក្រហាយ និងស្អុតស្អាញគ្រប់ពេលវេលា ប៉ុន្តែភ្លើងនេះមិនមែនវាចេះកើតមានឡើងងាយៗនោះទេ វាកើតនៅពេលដែលឃើញសត្រូវ ឬក៏គូប្រជែង

www.elibraryofcambodia.org

មុខ និងថយក្រោយ ព្រមទាំងរៀបចំផែនការទុកជាមុនយ៉ាងច្បាស់លាស់ ល្អិតល្អន់ និងបានការពិចារណាជាច្រើនលើកច្រើនសាររួចហើយ។

អ្នកដែលសម្លឹងមើលបានវែងឆ្ងាយ គេមិនគិតតែក្នុងពេលបច្ចុប្បន្ននោះទេ ប៉ុន្តែគេបានគិតទៅដល់អនាគតដ៏វែងឆ្ងាយផងដែរ ពីព្រោះតែការមើលបានឆ្ងាយនេះហើយ ទើបគេមាននិកាសជោគជ័យច្រើន និងផ្តល់សុខសប្បាយទៅដល់កូនចៅ ហើយកូនសាកហាត់ធ្វើជាមនុស្សមើលវែងឆ្ងាយទៅ ដោយមើលទៅមុខបានឆ្ងាយជាងមើលក្បែរទៅដល់កូនចៅ គឺកាន់តែល្អ កុំមើលជិតៗ ដោះស្រាយតែរឿងបានតែមួយភ្លែតៗ ត្រូវតែសម្រេចឱ្យបានត្រឹមនោះ រៀនមើលឱ្យបានវែងឆ្ងាយទៅ និងរៀបចំផែនការទុកជាមុនទើបល្អ។

បើសិនជាកូនធ្វើបែបនេះបាន កូនក៏ជាមនុស្សម្នាក់ដែលស្ថិតនៅក្នុងចំណោមអ្នកមើលវែងឆ្ងាយ ហើយនឹងទទួលបានភាពជោគជ័យយ៉ាងពិតប្រាកដ ដូចជាអ្នកដទៃដែរ។

www.elibraryofcambodia.org

# ៨៨.សម្លឹងមើលឲបានវែងឆ្ងាយ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានពាក្យសព្ទសម័យថ្មីមួយម៉ាត់ថា **«សម្លឹងមើលឲបានវែងឆ្ងាយ»** មានន័យថា ចង់អ្វីក៏ដោយឲសម្លឹងមើលមុខមើលក្រោយ មើលឲបានវែងឆ្ងាយទៅដល់អនាគត ដែលជាពាក្យមានអត្ថន័យល្អ ពីព្រោះមនុស្សដែលមើលវែងឆ្ងាយ នឹងទទួលបានជោគជ័យក្នុងការងារផ្សេងៗដែលគេធ្វើក្នុងពេលវេលាវែង ដោយមនុស្សមើលអ្វីចង្អៀតចង្អល់ ឬមើលតែចំពោះមុខ មើលផលប្រយោជន៍រយៈពេលខ្លី ក៏ទទួលបានផលសម្រេចរយៈពេលខ្លីៗ ហើយដួលរលំទៅវិញមិនស្ថិតស្ថេរនោះទេ ដូច្នេះ មិនថាកូនធ្វើកិច្ចការអ្វីនោះទេ កូនត្រូវតែគិតមើលឲបានវែងឆ្ងាយទៅ ការងារកាន់តែធំ ក៏កាន់តែមើលឲបានវែងទៅទៀតកូន។

អ្នកដែលមើលមិនបានវែងឆ្ងាយនោះ ពិបាកនឹងមានភាពរីកចម្រើន និងទទួលបានភាពជោគជ័យនៅក្នុងការងារណាស់ ដោយអ្នកដែលមើលបានវែងឆ្ងាយ គេតែងតែគិតមើលបានយ៉ាងហ្មត់ចត់ ហើយច្បាស់លាស់ គិតដល់ផលដែលបាន និងផលដែលបាត់បង់ មិនគិតតែពីបានផលម្យ៉ាងនោះទេ គិតតែពីបញ្ហាដែលត្រូវប្រឈមមុខទុកជាមុន គិតតែពីវិធីដើរទៅ

www.elibraryofcambodia.org

ក្ដាត់អ្វីក៏អាចជួយទាន់ពេលវេលាបាន ឬក៏ត្រៀមបញ្ហា ត្រៀមចិត្ត គិតទុកជាមុនថា ថ្ងៃក្រោយកើតយ៉ាងណា និងធ្វើអ្វីយ៉ាងណាជាដើម។

ការត្រៀមទុកបែបនេះ ខាងព្រះពុទ្ធសាសនាបានហៅថា **មិនប្រមាទ** អ្នកដែលមានភាពហ្មត់ចត់ គេបានត្រៀមខ្លួនទុកជានិច្ច ដោយហេតុដែលបានបញ្ហា មានហេតុការណ៍បន្ទាន់នោះ ក៏អាចឆ្លងកាត់បញ្ហា និងហេតុការណ៍នោះបានដោយមិនពិបាកនោះទេ ហើយដូច្នេះ ទើបលោកមានការប្រៀនប្រដៅទុកថា កុំធ្វើជាមនុស្សប្រមាទ ត្រូវត្រៀមខ្លួនទុកដូចជាត្រៀមការពារជាមុន ប្រសើរជាងព្យាបាល ហើយក៏មានសុភាសិតមួយឃ្លាបានពោលថា **ប្រហែសបាត់ ប្រយ័ត្នគង់** ពីលោកចង់ទូន្មានថា ពេលចោរលួចគោបាត់ហើយ ទើបធ្វើក្រោល តើបានប្រយោជន៍អ្វីទៅ? ។

www.elibraryofcambodia.org

# ៨៩.ការត្រៀមខ្លួនទុករួចជាស្រេច

កូនសម្លាញ់របស់ពុកម៉ែអើយ !

នៅក្នុងជីវិតមួយថ្ងៃៗរបស់មនុស្សយើងនោះ មានរឿងដែលត្រូវដោះស្រាយច្រើនណាស់មិនឈប់ឡើយ បន្តិចរឿងនេះ រឿងនោះ ជួនកាលក៏នាំទុក្ខលំបាកមកថែមទៀតដោយដោះស្រាយមិនបាន ស្ងប្បីតែកូនធ្លាប់បានជួបប្រទះរឿងនេះខ្លះហើយក៏ដោយ។

ចង់ប្រាប់វិធីម្យ៉ាងដែលទាក់ទងនឹងរឿងនេះ នោះគឺ **ការត្រៀមខ្លួនទុករួចជាស្រេច** ដែលមានន័យថា ការត្រៀមខ្លួនការពារដោះស្រាយទុកជាមុនដោយមុនពេលដែលមានបញ្ហា ឬរឿងនោះនឹងមកដល់ឆាប់ៗ ដូចជារឿងការដែលធ្វើដំណើរវែងឆ្ងាយ យើងត្រូវតែត្រៀមលក្ខណៈទុកជាមុន បិនថាជាផែនការធ្វើដំណើរ ខោអាវ ស្បៀង ឬយានជំនិះ ព្រមទាំងពរុយកាក់សម្រាប់ចាយវាយផងដែរ ដោយដល់ពេលដែលចេញដំណើរយើងក៏អាចទៅបានភ្លាម មិនបាច់ភ័យព្រួយពីបញ្ហាខ្វះខាតនោះឡើយ។

ការត្រៀមខ្លួនទុករួចជាស្រេច ជាការការពារ និងដោះស្រាយចំពោះបញ្ហាដែលល្អបំផុត ដោយពេលដែលមានបញ្ហាក៏ដោះស្រាយបានភ្លាម វាប្រៀបបានដូចជាការត្រៀមថ្នាំដែលចាំបាច់ទុករួចជាស្រេច ពេលដែលឈឺ

www.elibraryofcambodia.org

យើង ដូចជាកូនល្អិត ឬកូនចៅជាដើម យើងគួរតែមានទឹកចិត្តចំពោះរូបគេឲ្យបានច្រើន បើសិនជាពិបាក ឬត្រូវការអ្វីក៏ជួយគេតាមដែលយើងអាចជួយដល់បាន អ្នកណាធ្វើល្អ ធ្វើប្រយោជន៍ដល់យើងកុំភ្លេចគុណរបស់គេ ឲ្យរង្វាន់កម្លាំងចិត្តដល់គេ យ៉ាងហោចណាស់ក៏គួរនិយាយសរសើរដល់គេឲ្យបានសប្បាយចិត្តបន្តិចក៏ល្អដែរ។

ការជួយគេដោយទឹកចិត្តបែបនេះ ជាមន្តវិសេសដែលអូសទាញឲ្យគេស្រឡាញ់រាប់អានដល់យើង គោរពចំពោះយើង ដោយការមានទឹកចិត្តជារបស់វិសេសវិសាលណាស់កូនសម្លាញ់អើយ! ហើយមនុស្សយើង ទោះបីជារូបរាងមិនសូវស្អាតក៏មានបន្តស្នេហ៍បានដែរ ដោយការមានទឹកចិត្តនេះឯង ប៉ុន្តែ ផ្ទុយទៅវិញ ទោះបីជាមានរូបរាងសង្ហាស្អាតប៉ុណ្ណា បើសិនជាគ្មានទឹកចិត្តទេនោះ ក៏ធ្វើឲ្យរស់មន្តស្នេហ៍ទៅច្រើនណាស់ ទើបជាចាស់បុរាណតែងតែពោលថា **«មានទឹកចិត្តជាមន្តស្នេហ៍ គ្មានទឹកចិត្តជាមនុស្សដែលមិនល្អ»**។

www.elibraryofcambodia.org

# ៩០.ការមានទឹកចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

ធ្លាប់ប្រាប់ដល់កូនខ្លះហើយថា មនុស្សយើងពេលទៅទីកន្លែងណា ឬក៏នៅជាមួយអ្នកណាក៏ដោយ សូមធ្វើជាមនុស្សមានទឹកចិត្ត ខ្វះអីក៏ខ្វះទៅ គ្មានអ្នកណាស្តីបន្ទោសទេ ប៉ុន្តែសូមកុំចំពែខ្វះទឹកចិត្តបានហើយ កុំធ្វើជាមនុស្សដែលគ្មានទឹកចិត្ត កុំមានចិត្តចង្អៀតចង្អល់ គិតតែពីចង់តែបាន ដោយមិនគិតដល់ចិត្តអ្នកណា ជួយអ្នកណាក៏មិនបាន។

មនុស្សយើង បើសិនជាមនុស្សគ្មានទឹកចិត្តហើយនោះ ក៏គ្មានអ្នកណាគេមកចង់រាប់អាន ឬចង់មកនៅជាមួយផងដែរ ហើយបើសិនជាទ្រាំរស់នៅជាមួយ ក៏ព្រោះតែគ្មានផ្លូវទៅប៉ុណ្ណោះ ប្រៀបដូចដីដែលគ្មានទឹក មនុស្ស សត្វ រុក្ខជាតិ និងដើមឈើក៏ចង់រស់នៅ មិនចង់ទៅកើតនៅបរិវេណនោះដែរ ដោយចង់ទៅរស់នៅលើទឹកដីដែលមានភាពសម្បូរជាងនេះ ហើយចំណែកមនុស្សដែលមានទឹកចិត្ត ក៏មានអ្នកពឹងពាក់អាស្រ័យ និងមិនចង់បែកទៅណាផងដែរ ទោះបីពេលខ្លះនៅក្នុងកន្លែងតូចក៏ដោយ។

កូនដឹងបែបនេះហើយ គួរតែព្យាយាមធ្វើជាមនុស្សដែលមានទឹកចិត្តទៅ ជាពិសេស អ្នកជិតស្និទ្ធ អ្នកដែលយើងត្រូវពឹងពាក់គេ ចជួយការងារ

www.elibraryofcambodia.org

ស្តាយក្រោយផងដែរ ដូចជាយើងមិនដាក់ខ្លួនគោរពចំពោះមនុស្សមិនគោរព មិនលើកដៃសំពះចំពោះមនុស្សដែលមិនសំពះតបយើង ឬយើងទៅជួយការងារផ្សេងៗដល់គេ ដោយគេមើលមិនឃើញទឹកចិត្តរបស់យើង។

កូនសម្លាញ់អើយ! មនុស្សយើងក៏មិនដូចគ្នាទាំងអស់នោះទេ កូនកុំគិតថាគេដូចជាយើង ឬយើងដូចជាគេនោះ ដោយយើងគិតផ្សេងៗ គេគិតផ្សេងៗ ត្រូវមើលឲ្យបានច្បាស់ គិតឲ្យបានល្អមុននឹងបណ្ដោយក្ដីសង្ឃឹម ឬចង់ធ្វើអ្វីឲ្យអ្នកណាម្នាក់នោះ ទើបមិនកើតមានការខូចចិត្ត ឬសោកស្ដាយនៅពេលក្រោយ ហើយការធ្វើអ្វីដោយមិនបានគិតមុខក្រោយឲ្យច្បាស់លាស់ អាចជាការខាតបង់ប្រយោជន៍ពុំខានណាកូន។

www.elibraryofcambodia.org

# ៩១.ធ្វើអ្វីដែលមានប្រយោជន៍

កូនសម្លាញ់របស់ពុកម៉ែអើយ !

កាមផុតា បើសិនមនុស្សយើងមានពេលធ្វើអ្វីមួយ តែងតែគិតជាពេលដែលធ្វើហើយបេទទួលបានផលយ៉ាងណា ខាតបង់ ឬចំណេញជាដើម វាពិតជាត្រឹមត្រូវណាស់ ពីព្រោះតែវាជាការបង្ហាញភាពហ្មត់ចត់គិតមុខគិតក្រោយយ៉ាងច្បាស់លាស់ បើសិនមិនគិតឲបានច្បាស់ជាមុនសិនទេ អាចនឹងខ្ជះខ្ជាយបាត់បង់ ឬមិនបានប្រយោជន៍ក៏ថាបាន ដោយនៅវិស័យព្រះពុទ្ធសាសនា លោកបានណែនាំបែបនេះដូចគ្នាថា **«មានការគោរពចំពោះអ្នកដែលគួរគោរព គួរសេពគប់នឹងអ្នកដែលពេញចិត្តសេពគប់ជាមួយនឹងយើង គួរតែជួយកិច្ចការចំពោះអ្នកដែលព្យាយាមធ្វើកិច្ចការ មិនគួរធ្វើប្រយោជន៍ដល់អ្នកមិនត្រូវការប្រយោជន៍ទេ កុំរាប់អានជាមួយអ្នកមិនចង់រាប់អានជាមួយនឹងយើង»**។

ពាក្យណែនាំនេះបានផ្តល់គំនិតល្អណាស់កូន ច្បាស់លាស់ល្អដល់ថ្នាក់មិនចង់អធិប្បាយនោះទេ ជាពាក្យណែនាំមិនឲចង់មនុស្សយើងខាតបង់ពេលវេលាទៅធ្វើរឿងដែលគ្មានប្រយោជន៍ ហើយកូនធ្វើតាមនូវពាក្យណែនាំនេះបាន យើងនឹងមិនខាតពេលវេលា មិនខាតកម្លាំង ហើយក៏មិន

www.elibraryofcambodia.org

ចាប់ផ្តើមពិត ចាប់ផ្តើមល្អ ទៅនឹងក្លាយជាទម្លាប់មិនខាន ហើយចង់ជួយអ្វីដល់អ្នកដទៃ ចង់ធ្វើអ្វីដល់អ្នកដទៃ ក៏អាចធ្វើបានយ៉ាងត្រូវចិត្ត គ្មានអ្វីទើសទាល់នោះទេ។

ការនឹកដល់អ្នកដទៃច្រើនជាងខ្លួនឯង អ្នកដែលគិត និងធ្វើបែបនេះបានណាកូន ទើបក្លាយជាមនុស្សដែលទទួលបានផល ដូចជាការពោលខាងលើនេះ ប៉ុន្តែផ្ទុយទៅវិញ បើសិនធ្វើខ្លួនជាអ្នកពូកែស៊ី ចូលចិត្តទទួលច្រើនជាងគេ ក៏នឹងក្លាយជាមនុស្សដែលមានចិត្តចង្អៀត ជាមនុស្សដែលអាត្មានិយម ដោយមនុស្សអាត្មានិយម គឺចូលចិត្តតែស៊ីរញ្ជឹង នឹងក្លាយជាទីស្អប់ខ្ពើមរបស់ទូទៅ ពិបាករកមិត្តភក្តិណាស់ ទោះបីជាមានមនុស្សមករាប់អានជាមួយ គឺមកដើម្បីតែផលប្រយោជន៍របស់គេតែប៉ុណ្ណោះ នឹងរកភាពស្មោះត្រង់មិនបាននោះទេ។

www.elibraryofcambodia.org

# ៩២.រៀនឲបានច្រើន ប្រសើរជាងទៅរៀនសុំ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានពាក្យទូន្មានរបស់ព្រះពុទ្ធបានពោលថា **អ្នកឲតែងគេស្រឡាញ់ អ្នកសុំច្រើនតែងតែគេស្អប់ខ្ពើម** ជាពាក្យពិតដែលត្រឹមត្រូវណាស់ មើលដោយខ្លួនយើងក៏បានដែរ ដោយបើសិនជាមានគេសុំអ្វីពីយើងលើកទីមួយគ្មានអារម្មណ៍នោះទេ ប៉ុន្តែជាញឹកញាប់ពេកនោះ ទោះបីជាមានការពាំពាក់ យើងក៏កើនអារម្មណ៍មិនសូវចូលចិត្តដែរ ប៉ុន្តែផ្ទុយទៅវិញនោះ បើសិនជាមានអ្នកណាមកអ្វីមកឲយើងជាញឹកញាប់នោះ យើងបែរជាចូលចិត្ត ទោះបីជារបស់នោះតូចតាចគ្មានតម្លៃអ្វីក៏ដោយ ក៏យើងពេញចិត្តផងដែរ។

តាមអត្ថន័យនេះ បើសិនជាកូនធ្វើខ្លួនជាអ្នកឲច្រើនជាងអ្នកទៅសុំ នោះកូននឹងក្លាយជាមនុស្សជាទីស្រឡាញ់រាប់អានរបស់អ្នកនៅទីនោះ គេនឹងមិនស្អប់ខ្ពើមកូននោះទេ ហើយកូនពិតជាមានអ្នកគោរពរាប់អានច្រើនណាស់ ព្រមទាំងមិនត្រូវគេធ្វើបាប និងមានអ្នកជាជួយផងដែរ ដោយពេលដែលមានការអ្វី គេមិនទុកយើងចោលម្នាក់ឯងនោះទេ។

ភាពត្រឹមត្រូវ ការនៅជាមួយគ្នា ជាក្រុម ជាពួក ត្រូវតែគិតថា **តើយើងអាចធ្វើអ្វីដល់គេបានខ្លះ ច្រើនជាងគិតថា យើងបានអ្វីពីគេខ្លះ** ដោយកូន

www.elibraryofcambodia.org

អត់ដាច់តែចិត្តល្អ ត្បិតយើងមានការអត់ធ្មត់ជាមួយគេបាន។

បើសិនកូនបានធ្វើការជាមួយមនុស្សស្លូតថ្លៃថ្នូរ ប៉ុន្តែចិត្តអាក្រក់ គ្មានភាពយុត្តិធម៌ មានភាពលំអៀង ហើយត្រូវធ្វើការក្រោមគេនោះ ត្រូវមានការប្រុងប្រយ័ត្នផង ធ្វើការដើម្បីការងារ ធ្វើការកុំឲ្យតែខុសទៅបានហើយ កុំទៅសង្ឃឹមបានអ្វីច្រើនពីគេអី ដោយការប្រៀនប្រដៅកូនបែបនេះ មិនមែនចង់ឲ្យកូនក្លាយជាមនុស្សអាត្មានិយមនោះទេ ប៉ុន្តែចង់ឲ្យកូនចេះការពារខ្លួន ដោយមិនចាំបាច់ទៅកាត់ទៀងលះបង់ចំពោះការងារគេនោះទេ ពីព្រោះតែពេលទទួលបាននោះ គឺជាការឈឺចាប់ និងអន់ចិត្ត ដោយសារតែថ្នាក់លើមិនមានភាពយុត្តិធម៌។

មានលុយកាក់ពីមួយពាន់ហា ធ្វើល្អបាន ប៉ុន្តែកុំស្រួលពេក ពីព្រោះមិនភ្លាមៗនោះព្រោះថ្នាក់ គ្មាននរណាគេចង់អើពើជាមួយកូនពេលនោះទេ លើកមិនអាចនៅជាអាចតាមអាទៀតទេ។ ការធ្វើអំពើល្អនោះជារឿងដែលកូនត្រូវ ប៉ុន្តែធ្វើល្អចេះមើលមនុស្សផង ទើបបានផលល្អពិតប្រាកដ។

www.elibraryofcambodia.org

# ៩៣.ធ្វើល្អបាន ប៉ុន្តែកុំជ្រុលពេក

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលណាដែលយើងធ្វើការជាមួយអ្នកណា មិនថា ជាការងាររដ្ឋ ឬឯកជននោះទេ សូមកូនព្យាយាមស្វែងយល់ពីចរិត និងនិស្ស័យរបស់អ្នកធំ ឬចៅហ្វាយនាយរបស់យើងឲ្យបានច្បាស់ ពីព្រោះថ្នាក់លើម្នាក់ៗមិនដូចគ្នានោះទេ ប្រភេទនឹងលើរង្គើក្រោមក៏មាន ប្រភេទសម្ដីផ្អែម ប៉ុន្តែចិត្តអាក្រក់ក៏មាន ប្រភេទនិយាយបាតដៃខ្នងដៃក៏មាន ប្រភេទនិយាយស្រួលជាមួយនឹងយើង សរសើរយើងដើម្បីបោកប្រើឲ្យយើងធ្វើការឲ្យគេ ប៉ុន្តែរិះ ដែលធ្វើជាដុំកំភួននោះក៏មានដែរ។

បើសិនយើងជឿតាមសម្ដីបែបនេះ យើងនឹងហត់នឿយរហូតទៅ ដោយរបស់ល្អៗគេឲ្យគ្នា ប្អូនចៅរបស់គេអស់ហើយ ហើយនិយាយលើកទឹកចិត្តឲ្យយើងខិតខំធ្វើឲ្យល្អទៀតទៅ កុំមានការរាថយ ប្រភេទសម្ដីផ្អែមចិត្តអាក្រក់បែបនេះ អាក្រក់ណាស់កូនសម្លាញ់អើយ! ហើយចំណែកប្រភេទនឹងលើរង្គើក្រោមនោះទាល់តែមើលយូរៗទៅ ទើបដឹងថា ល្អពិត ឬក៏អត់នោះ គួរតែមើលលើទង្វើរបស់គេ គេអាចមិនសរសើរយើងទេ ប៉ុន្តែដល់ពេលណាមួយគេអាចឲ្យរង្វាន់ដល់យើងក៏ថាបាន និងប្រភេទមនុស្ស

www.elibraryofcambodia.org

តែមុខមាត់ សម្បកក្រៅ ពីព្រោះតែវាជាការបំភាន់ភ្នែកក៏ថាបាន ដោយកូនត្រូវតែមើលដល់ទង្វើ និងគំនិតការគិតរបស់គេ មើលទាំងខាងមុខ និងខាងក្រោយ ហើយបើសិនជាកូនមិនមើលឲ្យល្អទេ ទៅគេបញ្ឆោត ឬទៅទុកចិត្តផ្តល់ការគោរពចំពោះគេ វាពិតជានាំការសោកស្តាយនៅពេលក្រោយក៏ថាបានដែរ។

អ្នកដទៃគេធ្វើបាបយើងតាមការរស់នៅរបៀបនោះ គឺយើងគ្រាន់តែក្តៅក្រហាយតែប៉ុណ្ណោះ ប៉ុន្តែអ្នកដែលត្រូវទុកចិត្ត អ្នកដែលយើងគោរពរាប់អាន បែរធ្វើបាបយើងរស់សម្ងំវិញ វាពិតជាធ្វើឲ្យយើងឈឺចាប់ និងអន់ចិត្តយ៉ាងណាស់ ពីព្រោះហេតុនេះហើយ ទើបមានការប្រដៅថា **«កុំទុកចិត្តមេឃ កុំទុកចិត្តផ្កាយ កុំទុកចិត្តមនុស្សខ្លាំងពេកប្រយ័ត្នស្តាយក្រោយដោយចង់ទុកចិត្តអ្នកដទៃ កុំទុកចិត្តទាំងស្រុងពេកអី ចង់ស្រឡាញ់ចង់គោរពអ្នកណាត្រៀមចិត្តខកបំណងខ្លះទៅ នឹងមិនសោកស្តាយខ្លាំងនៅពេលដែលខកបំណង»។**

www.elibraryofcambodia.org

# ៩៤. ស្គាល់មុខ ប៉ុន្តែមិនស្គាល់ចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានសុភាសិតមួយឃ្លាបានពោលថា **មនុស្សយើងស្គាល់មុខ ប៉ុន្តែមិនស្គាល់ចិត្ត** ជាពាក្យដែលប្រើបានរហូត ជាពិសេសនៅសម័យនេះកាន់តែមើលឃើញយ៉ាងច្បាស់ ដោយអ្នកដែលពូកែធ្វើមុខពោកព្រាស់ មើលតែសម្បកក្រៅ មើលទៅដូចជាមនុស្សល្អ មានមេត្តា ប៉ុន្តែចិត្តនៅខាងក្នុងបែរជាគិតផ្សេងៗ។

អ្នកដែលសាងរូបភាពខ្លួនឯង ឲ្យមើលទៅល្អនោះ ចាំបាច់ត្រូវតែតុបតែងមុខ កិរិយាឫកពា និងការបង្ហាញចេញផ្សេងៗ ឲ្យមើលទៅជាទីគាប់ភ្នែករបស់អ្នកមើលដែលលាក់បាំងរូបភាពខាងក្នុង ដែលវាមិនស្រស់ស្អាតបែបនោះទេ ទើបជាមានពាក្យពោលថា **ស្គាល់មុខ ប៉ុន្តែមិនស្គាល់ចិត្ត** នោះដោយយើងដឹងបានតែមុខ តែសម្បកខាងក្រៅរបស់គេទេ ប៉ុន្តែចិត្តរបស់គេនោះពិបាកនឹងដឹងណាស់ ពីព្រោះអាចខុសពីគ្នាបាន ដូចជារូបពិតនិងរូបគំនូរអញ្ចឹង។

ដូច្នេះ បើសិនជាកូនសេពគប់ជាមួយអ្នកណា ចង់ទុកចិត្តអ្នកណា ឬធ្វើការងាររួមជាមួយអ្នកណា គួរតែគិតឲ្យបានល្អ មើលឲ្យបានយូរ កុំមើល

www.elibraryofcambodia.org

កូនសម្លាញ់អើយ! កើតមកជាមនុស្ស បើសិនជាយើងឆ្អែតហើយ គួរគិតដល់អ្នកដែលឃ្លានផង បើសិនយើងសុខគួរគិតដល់អ្នកមានទុក្ខផង ហើយបើសិនយើងមានគួរគិតដល់អ្នកក្រផង ដោយកូនគិតបែបនេះបាន កូននឹងជាអ្នកឈ្លាសវៃ និងយល់ចិត្តអ្នកដទៃ ជួយដល់អ្នកដទៃបាន ព្រមទាំងជាទីគោរពស្រឡាញ់រាប់អានរបស់អ្នកដទៃទាំងឡាយទៀតផង ហើយបើសិនជាកូនជាមនុស្សអាត្មានិយម កូននឹងក្លាយទៅជាមនុស្សនៅឯកា និងពេលដែលកូនជួបនឹងការលំបាក គ្មានអ្នកណាជួយយកអាសាកូននោះទេ ចាំទុកទៅកូនអើយ! ។

www.elibraryofcambodia.org

# ៩៥.ចិត្តគេ ចិត្តយើង

កូនសម្លាញ់របស់ពុកម៉ែអើយ !

ការរស់នៅជាមួយអ្នកផ្សេង មិនថានៅជាមួយគ្នាបែបស្វាមីភរិយា ឬបែបគ្រួសារឪពុកម្ដាយកូន បែបញាតិមិត្ត បែបមិត្តរួមការងារ អ្នកជិតខាង និងអ្នកនៅលើលោកនេះជាមួយក៏ដោយ ការគិតពីអារម្មណ៍របស់អ្នកដទៃជារឿងសំខាន់ណាស់ ពីព្រោះការរស់នៅប្រកបទៅដោយភាពសុខសាន្តបានយូរប៉ុណ្ណា ឬមានតែសេចក្ដីទុក្ខនោះ ត្រង់ចំណុចនេះក៏សំខាន់ដែរ។

ការយកចិត្តយើងទៅដាក់ចិត្តគេ ការយកចិត្តគេមកដាក់ចិត្តយើង ជារឿងដែលយើងគួរតែធ្វើ ដោយមានន័យថា យើងធ្វើអ្វីក៏ដោយក៏ត្រូវតែគិតពីផលប៉ះពាល់ដែលកើតមានឡើងដល់អ្នកដទៃផង ពេលខ្លះយើងគិតថាធ្វើហើយ យើងទទួលបានផលប្រយោជន៍ ប៉ុន្តែអ្នកផ្សេងគេអាចពិបាកដោយសារទង្វើរបស់យើងក៏ថាបានដែរ។ យើងគួរតែជៀសវាងអំពីចំណុចទាំងអស់នេះឲបានច្រើន មិនគួរសាងភាពជោគជ័យលើគំនរទុក្ខរបស់អ្នកដទៃនោះឡើយ ដោយយើងមិនចូលចិត្តអ្នកណាមកធ្វើឲយើងពិបាក អ្នកផ្សេងក៏មិនចូលចិត្តឲយើងទៅធ្វើឲគេពិបាកដូចគ្នាដែរ ហើយអ្នកដែលគិតតែពីបាននោះ គេហៅថាជាមនុស្សអាត្មានិយម។

www.elibraryofcambodia.org

ចិត្តនៅពេលក្រោយ ដោយមនុស្សត្រចៀកស្រាលនឹងធ្វើខ្លួនឯងឲ្យមានទុក្ខ ពិបាក បាត់បង់កិត្តិយសរបស់ប្រជាប្រិយភាព គ្មានអ្នកណាគេចង់គោរពរាប់អាននោះទេ ហើយអ្នកត្រចៀកស្រាលនោះ អាចធ្វើឲ្យប្តីប្រពន្ធលែងលះគ្នា បែកផ្លូវគ្នា ធ្វើឲ្យវិនាសគ្រួសារ រស់នៅគ្មានសេចក្តីសុខ សង្ស័យលើគ្នា ឬត្រូវរៀបទុក្ខទាំងសងខាងមកច្រើនណាស់ហើយ ដូច្នេះ សូមកូនប្រយ័ត្នខ្លួនទៅទើបជាការល្អ។

www.elibraryofcambodia.org

# ៩៦.ស្តាប់ត្រចៀកម្ខាង ទុកម្ខាង

កូនសម្លាញ់របស់ពុកម៉ែអើយ !

នៅក្នុងក្រុមសន្ទនានោះ តែងតែគេចមិនផុតឡើយពីការនិយាយរស្តីផ្តេសផ្តាស ដោយលើកយករឿងអ្នកនោះ អ្នកនេះមកនិន្ទានិយាយដើមគ្នា កូនត្រូវធ្វើចិត្តធូធ្ងន់ចំពោះរឿងនេះ កុំត្រចៀកស្រាលទៅឆាប់ជឿសម្តីអ្នកណាងាយៗ ជាពិសេស បើសិនកូនជាអ្នកធំ ជាមេបញ្ជាការ ជាប្រធាន ឬជាមេគ្រួសារក៏ដោយ ពីព្រោះអ្នកខ្លះនិយាយហើយ គ្មានការទទួលខុសត្រូវអោះឡើយ និយាយតាមតែចិត្តចង់និយាយ មិនគិតពីផលប៉ះពាល់ថា អាចធ្វើឲគេក្តៅក្រហាយ ឬបាត់បង់កិត្តិយសយ៉ាងណានោះទេ គិតចង់និយាយក៏និយាយចេញមក ហើយអ្នកខ្លះនិយាយដើម្បីសប្បាយមាត់ពេង ដោយចង់ឃើញស្តាប់សប្បាយជាមួយសម្តីរបស់គេ គេហៅមនុស្សប្រភេទនេះថា **អ្នកពូកែប្រឌិតរឿង** និងមានអ្នកខ្លះទៀតនិយាយ ក៏ព្រោះចង់ឲគេមានការបែកបាក់គ្នា ចង់ជិះជាន់អ្នកដទៃ មានគ្រប់រឿង គ្រប់យ៉ាងតាមតម្រូវការ។

កូនស្តាប់រឿងទាំងអស់នេះហើយ ត្រូវតែមានការថ្លឹងថ្លែងចិត្តមើលឲបានច្បាស់ កុំអាលជឿគេភ្លាមអី ស្តាប់ម្ខាងទុកម្ខាង ត្រូវពិសោធពិចារណាឲបានច្បាស់ ទើបកូនមិនសោកស្តាយ មិនខកបំណង មិនក្តៅក្រហាយ

www.elibraryofcambodia.org

មនុស្សបែបនេះហើយកូន ពិតជាគួរឲ្យមានការកោតសរសើរណាស់ សំពះបានពេញដៃ គោរពបានយ៉ាងពេញចិត្ត ប៉ុន្តែពិបាករកណាស់កូន សូមឲ្យកូនយកមនុស្សបែបនេះជាគំរូទៅ ទោះបីជាកើតទៅគ្មានបុណ្យស័ក្តិ ក្រីក្រ ប៉ុន្តែមើលទៅមានភាពថ្លៃថ្នូរណាស់ អាចគោរពរាប់អានយ៉ាងពេញចិត្ត ហើយភាពសុចរិតនេះជាអាវក្រោះការពារយើងបាន គឺការពារយើងមិនឲ្យធ្លាក់ចូលទៅក្នុងរណ្ដៅនៃអំពើអាក្រក់។

មនុស្សដែលប្រកាន់ភ្ជាប់នូវអំពើសុចរិតបាន តែងតែទទួលបានការគោរពពីមនុស្សទាំងឡាយ ទៅណាមកណាមិនចាំបាច់ភ័យខ្លាចទេ រកស៊ីអ្វីក៏រកបានរីកចំរើន ហើយភាពសុចរិតជាហេតុធ្វើឲ្យយើងរស់នៅយ៉ាងសុខសាន្ត គ្មានគ្រោះភ័យខ្លាចចំពោះអ្នកណាឡើយ។

**«ភាពសុចរិតបែបនេះហើយ កូនគួរតែប្រកាន់ភ្ជាប់ឲ្យបានល្អ ទោះបីជាត្រូវបង្ខំចិត្ត និងអត់ធ្មត់ប្រព្រឹត្តក៏សមនឹងតម្លៃផងដែរ»។**

www.elibraryofcambodia.org

# ៩៧.ភាពសុចរិតទៀងត្រង់

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលវេលានេះមានរបស់ដែលពិបាកនឹងរកបានកាន់តែច្រើនឡើងៗ នៅលើលោកយើងនេះ ដូចជាគម្ពុលនៅបាតសមុទ្ររញ្ជឹង ដោយរបស់នោះគឺ **ភាពសុតចរិត** ដោយនៅគ្រប់ទីកន្លែងនៅក្នុងសង្គមសុទ្ធតែត្រូវការនិងស្វែងរកភាពសុចរិតទាំងអស់ ប៉ុន្តែភាពសុចរិតនោះ ពិបាកស្វែងរកខ្លាំងណាស់ ពីព្រោះរកបានដោយកម្រ ទើបបានជាភាពក្តៅក្រហាយអាចកើតមានឡើងគ្រប់ពេលវេលា ភាពសង្ស័យ ភាពយកប្រៀបលើគ្នាបានរាលដាលទៅគ្រប់ទីកន្លែង។

សម្រាប់អ្នកដែលប្រកាន់ភ្ជាប់ជាមួយភាពសុចរិតនោះ អ្នកខ្លះត្រូវរស់នៅដោយចេះប្រមាណខ្លួន រស់នៅមិនសូវសប្បាយចិត្តនោះទេ ត្រូវតែស៊ូបន្ទោសរករឿងធ្វើឲ្យយើងអស់កម្លាំងចិត្ត ដោយគ្មានផ្លូវអាចតដៃជាមួយនឹងគេបាន ទើបមនុស្សសុចរិតខ្លះទ្រាំនឹងសភាពនេះមិនបាន សុខចិត្តធ្វើជា**ឆ្កែកន្ទុយកំបុត** ទៅជាមួយគេយ៉ាងគួរឲ្យសោកស្តាយ ប្រហែលជាមានតែមនុស្សមានចិត្តនឹងនរពិតប្រាកដប៉ុណ្ណោះទេ ទើបនឹងអាចគ្រប់គ្រងនូវភាពសុចរិតនេះបាន។

www.elibraryofcambodia.org

ចេញមិនចាំបាច់រាល់ថ្ងៃ មិនឃ្លានឆាប់ក៏អស់ដូចគ្នាផងដែរ ហើយគ្រោះភ័យទាំងពីរយ៉ាងនេះ សូម្បីមានតែមួយក៏អាចធ្វើឲ្យខូចមនុស្ស ឬខូចអនាគតបានផងដែរ មិនចាំបាច់និយាយដល់ទាំងពីរនោះទេ ប៉ុន្តែមនុស្សភាគច្រើនបណ្ដោយឲ្យគ្រោះភ័យទាំងនេះមកគ្របសង្កត់ និងបំផ្លាញខ្លួនឯងបានគ្រប់ពេលវេលាដោយមិនដឹងខ្លួន ឬអ្នកខ្លះអាចដឹងខ្លួនដែរ ប៉ុន្តែដកខ្លួនមិនរួចអណ្ដាតរបស់ក្លាយជាទាសកររបស់វា ត្រូវកាត់ទៀយកវាមកបម្រើជីវិត ពិតជាគួរឲ្យខ្លាចការណ៍នេះណាស់កូនអើយ! កូនដឹងច្បាស់ហើយ សូមឲកូនប្រយ័ត្នចំពោះគ្រោះភ័យទាំងពីរយ៉ាងនេះឲ្យល្អទៅកូនៗ

www.elibraryofcambodia.org

# ៩៨.គ្រោះភ័យបីយ៉ាង

កូនសម្លាញ់របស់ពុកម៉ែអើយ !

ចាស់បុរាណបានប្រៀនប្រដៅថា អ្នកដែលកំពុងកសាងអនាគត ឬកំពុងកសាងឋានៈនោះ ត្រូវចេះប្រយ័ត្នគ្រោះភ័យបីយ៉ាងគឺ ប្រយ័ត្នភ្លើងឆេះ ប្រយ័ត្នទឹកជំនន់ និងប្រយ័ត្នខ្មោចលង។

តាមការពិតគាត់ចង់ប្រដៅតាមបែបប្រស្នា ដោយគាត់មិនមែនចង់ឲ្យប្រយ័ត្នភ្លើង ប្រយ័ត្នទឹក ខ្មោចធម្មតានោះទេ ប្រស្នាដែលគាត់ចោទនោះគឺ **ភ្លើងមានន័យថា បារី ទឹកមានន័យថា សុរា ខ្មោចមានន័យថា ល្បែងស៊ីសង គាត់ចង់ឲមានការប្រយ័តភ្លើងឆេះ គឺកុំជក់បារី។ ប្រយ័ត្នទឹកជនន់ គឺកុំផឹកស្រា ហើយប្រយ័ត្នខ្មោចលង គឺកុំលេងល្បែងស៊ីសង។**

គ្រោះភ័យទាំងបីយ៉ាងនេះ ជាអ្នកដែលបំផ្លាញអនាគតរបស់មនុស្ស ពីព្រោះជាហេតុឲអស់លុយកាក់ដោយឥតប្រយោជន៍ ទោះបីជាមើលទៅមិនច្រើន ប៉ុន្តែបើសិនបាត់បង់ទៅរាល់ថ្ងៃ លុយកាក់ក៏បាត់បង់ទៅដោយឥតប្រយោជន៍រាល់ថ្ងៃ ទើបធ្វើឲសាងអនាគតបានយឺត ឬក៏អាចមិនបានសោះ ដោយទឹកដែលជ្រាបចេញពីពាង ទោះបីជាមិនច្រើន ប៉ុន្តែបើសិនរាល់ថ្ងៃ យូរៗទៅ ទឹកនឹងអស់ពីពាង យ៉ាងណាមិញ លុយកាក់ដែលហូរ

www.elibraryofcambodia.org

កងចក្រខ្វងក្បាល ទើបដឹងថាជាកងចក្រ ប៉ុន្តែហួសពេលទៅហើយ។

កាលបើបានដឹងរឿងដំណាលនេះ ទើបមានការប្រដៅតៗគ្នាតាំងពីបុរាណមកថា **កុំឃើញកងចក្រថាជាផ្កាឈូក** ដោយកុំធ្វើជាមនុស្សចេះពេករឹ កុំអាងតែថាជាគំនិតរបស់ខ្លួន អ្នកណាប្រាប់អ្នកណាប្រដៅក៏មិនស្ដាប់ ទោះបីជាអ្នកប្រដៅនោះជាឪពុកម្ដាយក៏ដោយ កុំធ្វើជាមនុស្សឃើញខុសជាត្រូវ ឃើញអាក្រក់ថាល្អ។ អ្នកដែលឃើញកងចក្រថាជាផ្កាឈូក នឹងយល់ឃើញប្លែកពីមនុស្សទូទៅ ដោយមនុស្សទូទៅយល់ថា របស់នោះមិនល្អមិនត្រូវ ជារឿងអាក្រក់ ប៉ុន្តែគេបែរជាយល់ថារបស់នោះជារបស់ល្អ ជារឿងត្រឹមត្រូវ មិនមានខាតបង់អ្វីនោះទេ និងយល់ថាគំនិតគេត្រូវ គ្នាមិនត្រឹមត្រូវទេ ហើយគេក៏ផ្ដុំខ្លួនធ្វើ ទម្រាំតែដឹងថាខ្លួនឯងខុស នោះក៏ហួសពេលទៅហើយ កែខ្លួនលែងបាន ពាក្យបុរាណមួយនេះ មានតម្លៃណាស់កូនអើយ! ។

# ៩៩.ឃើញកងចក្រថាជាផ្កាឈូក

កូនសម្លាញ់របស់ពុកម៉ែអើយ !

កូនប្រហែលជាធ្លាប់បានឮពាក្យថា **ឃើញកងចក្រថាជាផ្កាឈូក** មកខ្លះហើយ ដោយពាក្យនេះមកពីរឿងដំណាលខាងវិស័យព្រះពុទ្ធសាសនា ដែលមានបុរសម្នាក់បានសុំម្ដាយទៅជួញដូរខាងផ្លូវសមុទ្រ ហើយម្ដាយក៏មិនអនុញ្ញាតឲទៅ ពីព្រោះមានគ្រោះថ្នាក់ បុរសនោះមិនពេញចិត្តក៏បានច្រានម្ដាយឲដួល ហើយគាត់ក៏ចេញដំណើរទៅបាត់។

ក្រោយមកសំពៅដែលគាត់ជិះទៅនោះ បានកៀងកណ្ដាលសមុទ្រ គាត់ក៏បានហែលទឹកទៅដល់កោះមួយ កោះនោះជាកោះនរក ជាទីកន្លែងដាក់ទោសអ្នកវាយម្ដាយ ហើយសត្វនរកនៅលើកោះនោះ ត្រូវកងចក្រវិលនៅលើក្បាលដែលបណ្ដាលឲឈឺចាប់រងទុក្ខវេទនាគ្រប់ពេលវេលា ស្លាប់ហើយរស់ឡើងវិញជារៀយៗ។ បុរសនោះឃើញកងចក្រនោះជាផ្ការប្រពៃងផ្កាដ៏ស្រស់ស្អាត ពីព្រោះមានបាបកម្មដែលធ្វើបាបម្ដាយ ទើបគាត់ទៅសុំកងចក្រពីសត្វនរកមួយនោះ សត្វនរកនោះគិតថា គេម្នាក់នេះប្រហែលជាធ្លាប់វាយដំឪពុកម្ដាយដូចខ្លួនហើយ ទើបបានឃើញកងចក្រថាជាផ្កាឈូក ហើយមកទទួលបន្តពីខ្លួន ទើបលើកកងចក្រឲគេ ដោយពេលដែលត្រូវ

ឬជាភាពបរាជ័យនោះ អាចធ្វើឲ្យយើងខកបំណងខាតកម្លាំងទទេៗបាន ឬជាកម្លាំងជំរុញចិត្តឲ្យយើងធ្វើនូវរឿងផ្សេងៗដែលខុស ដើម្បីឲ្យបានតម្រេក តាមដែលយើងត្រូវការក៏ជាបានដែរ។

ដូច្នេះ បើសិនជាយើងកើតការស្រមើស្រមៃអ្វីមួយហួសព្រំដែន មើលរំលងសភាពដែលកើតទៅរួច និងមើលស្ថានភាពខ្លួនឯងច្បាស់ទៅជាមួយគ្នាផង ហើយបើសិនការស្រមើស្រមៃហួសពីលទ្ធភាព ឬហួសពីសមត្ថភាពរបស់ខ្លួនឯងនោះ អាចក្លាយជារឿងរវើរវាយ ឬជាបញ្ហាតែប៉ុណ្ណោះ ពីព្រោះបើសិនជារឿងយល់សប្តិ ឱកាសដែលសមតាមបំណងនឹងមានតិចណាស់ ពេលណាដែលមិនសមតាមបំណងអាចឲ្យមានការរាំងរានៅជីវិតក្រោយ។

ទោះបីជាយ៉ាងណាក៏ដោយ យើងគួរតែសរាងភាពស្រមើស្រមៃទុក ពីព្រោះរឿងដែលយើងស្រមៃទុកនោះ ប្រៀបបានដូចជាគោលដៅនៅក្នុងជីវិតរស់នៅគម្រោងផ្លូវទៅមុខ ប្រសើរជាងដើរដោយគ្មានគោលដៅ គ្មានទិសដៅ ហើយចំណុចសំខាន់នោះ កុំឲ្យការស្រមើស្រមៃក្លាយជារឿងយល់សប្តិទៅបានហើយកូន។

www.elibraryofcambodia.org

# ១០០.ក្តីស្រមៃ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សគ្រប់គ្នាតែងតែធ្លាប់មានក្តីស្រមៃ ជាពិសេសភាពដែលនៅពីក្មេងចេះតែស្រមៃចង់ធ្វើនេះធ្វើនោះ ដោយការស្រមើស្រមៃជារឿងល្អ អ្នកដែលមិនដែលមានការស្រមើស្រមៃអ្វីនោះ ទើបមិនល្អវល្អ ពីព្រោះតែការស្រមើស្រមៃជាការភ្លើ និងជាកម្លាំងជំរុញឲមនុស្សយើងមានការព្យាយាមដើម្បីធ្វើឲការស្រមើស្រមៃនោះក្លាយជាការពិតបាន។

អ្នកដែលមានការស្រមើស្រមៃខ្លាំងនោះជាមនុស្សដែលរឹងមាំ ហើយជាអ្នកតស៊ូនៅក្នុងជីវិតមិនព្រមចុះចាញ់ងាយៗនោះទេ និងអ្នកដែលបានសម្រេចជោគជ័យក្នុងជីវិតនោះ ភាគច្រើនចាប់ផ្តើមមកពីការស្រមើស្រមៃទាំងអស់ ប៉ុន្តែផ្ទុយទៅវិញ អ្នកដែលគ្មានការស្រមើស្រមៃអ្វីនោះជាមនុស្សសោះកក្រោះ គ្មានរសជាតិជីវិត ពីព្រោះតែខ្វះកម្លាំងជំរុញចិត្ត ធ្វើអ្វីក៏បែបធ្វើគ្មានគោលដៅ ទើបបានជាទទួលផលជោគជ័យតិចណាស់ ឬបរាជ័យតែម្តងក៏ជាបាន។

ប៉ុន្តែភាពស្រមើស្រមៃរបស់មនុស្សយើងនោះ ក៏មានចំណុចដែលគួរឲប្រយ័ត្នផងដែរ បើសិនជាការស្រមើស្រមៃនោះគ្រាន់តែជាការយល់សប្តិ

www.elibraryofcambodia.org

ការជោគជ័យនឹងកើតឡើងយ៉ាងងាយ និងឆាប់រហ័សមិនខ្ជះខ្ជាយ។

បើស្ត្រីតែខ្លួនឯងមិនយល់ពីចិត្តខ្លួនឯង នៅមិនទាន់ស្គាល់ខ្លួនឯងច្បាស់ផង ទៅធ្វើការអ្វីក៏ពិបាកមិនងាយរកផ្លូវត្រូវនោះដែរ ដូចជាមនុស្សធ្វើដំណើរគ្មានផែនទីអញ្ចឹងដែរ ដូចជាសង់ផ្ទះគ្មានគំរូ ទោះបីជាធ្វើបានក៏វាល្អមិនបានល្អដែរ ដោយមានតែខាតទាំងពេលវេលា អស់ទាំងកម្លាំងទៅដោយឥតប្រយោជន៍។

ដូច្នេះ មុនពេលដែលធ្វើជំនួញអ្វីមួយនោះ គួរតែស្វែងយល់ពីខ្លួនឯងបានច្បាស់ ត្រូវមើលខ្លួនឯងផ្ទុះសិនចាំធ្វើ ទើបមិនបណ្ដាលឲ្យមានការឈ្លោះឈ្លាយនាំឲ្យកើតឡើងបានតាំងពីចាប់ផ្ដើមដំបូង។

www.elibraryofcambodia.org

# ១០១.មើលខ្លួនឯងឲបានធ្លុះ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានមូលដ្ឋានក្នុងការអភិវឌ្ឍន៍ខ្លួនឯងឲមានភាពរីកចម្រើន គឺមានបីប្រការដែលសូមប្រាប់ដល់កូនឲបានដឹង នោះគឺ **មើលខ្លួនឯងឲធ្លុះ ប្រាប់ខ្លួនឯងឲបាន ចេះសម្របខ្លួនឯង** ហើយប្រការដំបូង មើលខ្លួនឲធ្លុះ មានន័យថា ត្រូវពង្រឹងមើលពីខ្លួនឯង ពិនិត្យមើលខ្លួនឯង ដើម្បីឲបានដឹងពីភាពពិតរបស់ខ្លួនឯង ជាពិសេសត្រូវតែស្គាល់ពីខ្លួនឯងឲច្បាស់ថា ខ្លួនឯងមានចំណេះដឹង មានសមត្ថភាព មានសតិបញ្ញាប៉ុណ្ណា មានសភាពយ៉ាងម៉េច មានកម្លាំងប៉ុន្មាន? ហើយសំខាន់បំផុតត្រូវតែស្គាល់ពីខ្លួនឯងថា ត្រូវការអ្វីពិតប្រាកដនោះ ត្រូវមើលឲខ្លួនឲធ្លុះ ឲឃើញដូចជាមើលសៀវភៅ ត្រូវយល់ចិត្តខ្លួនឯងឲបានល្អគ្រប់យ៉ាងដូចជាអ្នកធ្វើដំណើរឆ្ងាយៗ ដែលពូកែមើលផែនទីបានយ៉ាងល្អ ឬដូចជាសង់ផ្ទះ មើលគំរូផ្ទះយល់បានយ៉ាងល្អអញ្ចឹងផងដែរ។

ដូច្នេះ ការរស់នៅ ឬការប្រកបការងារអ្វីមួយ ក៏ដូចជាការធ្វើដំណើរ ឬការសង់ផ្ទះអញ្ចឹងដែរ ដោយត្រូវចេះប្រមាណមើលខ្លួនឯងឲបានកាន់តែច្បាស់លាស់ ក៏កាន់តែល្អ ហើយជីវិត និងការងារនឹងដំណើរបានយ៉ាងល្អ

www.elibraryofcambodia.org

ធម្មតារឿងធ្វើការតែងតែមានការភ្លេះភ្លោះ និងខុសឆ្គងបាន ហើយម្នាក់ៗតែងតែមានការភ្លេះភ្លោះ និងខុសឆ្គងបានគ្រប់គ្នា ប៉ុន្តែពេលដែលឃើញការភ្លេះភ្លោះខុសឆ្គងហើយ គួរតែប្រាប់ខ្លួនឯង ប្រដៅខ្លួនឯងថា មិនគួរធ្វើបែបនោះទៀតទេ ដោយខំសម្រាប់ដាស់តឿនដល់ខ្លួនឯងកែលម្អការងារ កែលម្អខ្លួនឯងឲ្យបានត្រឹមត្រូវ ពីព្រោះជាផ្លូវនាំឲ្យកើតភាពជោគជ័យនៅឱកាសខាងមុខបាន ប៉ុន្តែផ្ទុយទៅវិញ បើពិនអ្នកដទៃគេមិនព្រមប្រាប់ មិនប្រដៅ ហើយខ្លួនឯងមិនអាចប្រដៅ ឬដាស់តឿនខ្លួនឯងបានទេ ឬក៏មិនព្រមប្រាប់ មិនព្រមប្រដៅ ពីព្រោះគិតថាខ្លួនឆ្លាតគ្រប់ ក៏ប្រហែលជាស្មារតីវង្វេងបានហើយ មានតែឈានទៅរកក្តីវិនាសប៉ុណ្ណោះ ពិតជាគួរឲ្យខ្លាចណាស់។

កូនគួរតែហាត់ដាស់តឿនដល់ខ្លួនជានិច្ច បើពិនជាចាំឲ្យអ្នកដទៃមកដាស់តឿននោះ មិនសូវល្អទេ អ្នកណាគេអត់ធ្មត់ចិត្តតាមប្រាប់រហូតរាល់ថ្ងៃ ដោយការដាស់តឿនដល់ខ្លួនឯងនេះហើយជាការល្អបំផុត។

www.elibraryofcambodia.org

# ១០២.ប្រាប់ខ្លួនឯងឲបាន

កូនសម្លាញ់របស់ពុកម៉ែអើយ !

មូលដ្ឋានក្នុងការអភិវឌ្ឍន៍ខ្លួនឯងឲមានភាពរីកចម្រើនប្រការទី២ គឺ **ប្រាប់ខ្លួនឯងឲបាន** មានន័យថា តាមធម្មតារបស់មនុស្សយើងមិនសូវបាន ប្រដៅដល់ខ្លួនឯង ដាស់តឿនដល់ខ្លួនឯងនោះទេ ដោយប្រដៅដល់អ្នកដទៃ ដាស់តឿនដល់អ្នកដទៃគ្រប់យ៉ាង ប្រាប់ឲគេធ្វើបែបនេះបែបនោះ ប៉ុន្តែដល់ពេលខ្លួនឯងបែរជាមិនព្រមប្រាប់មិនព្រមប្រដៅ ទើបជួបប្រទះនឹងការផ្លោះផ្លោយ ជួបជាមួយទុក្ខលំបាករហូតទៅ ដោយតាមពិតទៅខ្លួនយើងនេះហើយ ដែលពិបាកប្រាប់ ពិបាក្រដៅជាងគេនោះ ប្រាប់ក៏ពិបាក ប្រដៅក៏ពិបាក។

ដូច្នេះហើយ ទើបបានជាក្នុងព្រះពុទ្ធសាសនាមានការដាស់តឿនចិត្តថា **«ចូរដាស់តឿនខ្លួនរបស់ខ្លួនឲចាកផុតកំហុស ខ្លួនដាស់តឿនចិត្តខ្លួនឯងឲបាន អ្នកណាដូចនោះ បើសិនដាស់តឿនខ្លួនឯងមិនបាន អ្នកណាដាស់តឿនឲ ហើយបើសិនយើងមិនបានការ អ្នកណាមកដាស់តឿនឲនាំតែហត់»។**

www.elibraryofcambodia.org

បែបនេះ មិនព្រមនៅស្ងៀម មិនព្រមនៅទំនេរនោះឡើយ ឃើញអ្នកផ្សេងគេធ្វើការអ្វី បើសិនជាជួយបានក៏ទៅជួយគេភ្លាម ហើយបើសិនជាកូនត្រូវការភាពជោគជ័យ និងជាមនុស្សមានមន្តស្នេហ៍ គឺត្រូវតែចេះប្រើខ្លួនឯងបែបនេះ កុំឈរឱបដៃមើល ជួយដល់អ្នកដទៃដោយមានទឹកចិត្ត កុំធ្វើជាមនុស្សគ្មានទឹកចិត្ត កុំធ្វើជាមនុស្សឃើញតែចង់បានអី។

មនុស្សដែលគ្មានទឹកចិត្ត គិតតែពីចង់បាន ហៅថាជាមនុស្សមិនល្អ មិនគួរគោរព ដោយទីបំផុតក្លាយជាមនុស្សគួរឲ្យស្អប់ខ្ពើមសម្រាប់មនុស្សទូទៅ ហើយការកសាងមន្តស្នេហ៍ប្រសើរជាងការសាងភាពមិនល្អ ដោយការកសាងមន្តស្នេហ៍មិនពិបាកនោះទេ គ្រាន់តែដាស់តឿនខ្លួនឯង កុំក្លាយជាមនុស្សឈរឱបដៃមើល ត្រូវចេះសម្របខ្លួន ពេលនោះមន្តស្នេហ៍ក៏មានពេញខ្លួនបាត់ទៅហើយ។

www.elibraryofcambodia.org

# ១០៣. ត្រូវចេះសម្រួលខ្លួន

កូនសម្លាញ់របស់ពុកម៉ែអើយ !

មូលដ្ឋានក្នុងការអភិវឌ្ឍន៍ខ្លួនឯងឲ្យមានភាពរីកចម្រើនប្រការទី៣ គឺត្រូវចេះសម្រួលខ្លួនឯង មានន័យថា មនុស្សយើងរាល់ៗគ្នាសុទ្ធតែចង់អ្នកដទៃនិយាយសរសើរដល់យើង ប៉ុន្តែដោយមនុស្សដែលគេគោរព និងសរសើរនោះជាមនុស្សមានមន្តស្នេហ៍នៅក្នុងខ្លួន ហើយបើសិនជាគ្មានមន្តស្នេហ៍ក៏គ្មានអ្នកណាមកគោរព មកស្រឡាញ់នោះដែរ ដោយវិធីសាងមន្តស្នេហ៍ឲ្យគេស្រឡាញ់នោះគឺ ត្រូវចេះសម្រួលខ្លួន។

ការចេះសម្រួលខ្លួន គឺជាការដាស់តឿនខ្លួនឯងឲ្យធ្វើការ ធ្វើឲ្យខ្លួនឯងមានប្រយោជន៍ ធ្វើការដោយខ្លួនឯង និងជួយដល់អ្នកដទៃដោយខ្លួនឯងដោយមិនចាំបាច់ឲ្យអ្នកណាមកប្រើ មិនចាំបាច់មានណាមកបញ្ជាក៏ធ្វើបានផងដែរ ឬបើសិនជាឃើញថាសមរម្យយ៉ាងណាក៏ធ្វើទៅ បើសិនយល់ថានោះជាអំពើល្អ ជារឿងដែលត្រឹមត្រូវ ហើយមានប្រយោជន៍ក៏ធ្វើទៅ។

ការចេះសម្រួលខ្លួននេះ ក្រៅអំពីការជួយអភិវឌ្ឍន៍ដល់ខ្លួនឯងហើយថែមទាំងជាការសាងមន្តស្នេហ៍ឲ្យខ្លួនឯងទៀតផង ដោយអ្នកដែលចេះប្រើខ្លួនឯងបែបនេះហើយ ដែលគេហៅថាជាមនុស្សអភិវឌ្ឍន៍ខ្លួនឯង មនុស្ស

www.elibraryofcambodia.org

ពីព្រោះតែហេតុនេះ មនុស្សវៃឆ្លាតតែងតែជ្រើសរើសមិនខុសនោះទេ ផ្ទុយទៅវិញអ្នកមិនវៃឆ្លាត តែងតែប្រញាប់សម្រេចចិត្តជ្រើសរើស និងមិនពិចារណាឲ្យបានច្បាស់ជាមុននោះទេ មើលមិនដឹងថារបស់ណាល្អ ឬរបស់ណាអាក្រក់នោះទេ ទើបខុសឆ្គងឆ្លោះឆ្លោយជានិច្ច ហើយចំណុចនេះកូនត្រូវមានការប្រយ័ត្នទៅល្អហើយ កូនស្តាប់ពាក្យចាស់ទុំពោលទៅ មិនអត់ប្រយោជន៍នោះទេ ហើយក៏មិនខាតបង់អ្វីឡើយ ប៉ុន្តែបើសិនកូនមានចិត្តអន្ទះសារពេក ប្រាកដមិនបានផលល្អហើយ ព្រមទាំងកើតការស្តាយពេលដែលសម្រេចចិត្តខុសទៀតផង។

www.elibraryofcambodia.org

# ១០៤.ជ្រើសរើសតែអ្វីល្អ។

កូនសម្លាញ់របស់ពុកម៉ែអើយ !

មានសុភាសិតចាស់បុរាណមួយពោលថា **«កុំស្រឡាញ់ចៃជាងសក់ កុំស្រឡាញ់ខ្យល់ជាទឹក កុំស្រឡាញ់ល្អាងជាងផ្ទះ កុំស្រឡាញ់ខែជាងថ្ងៃ»** ដោយសុភាសិតមួយនេះ ជាការដាស់តឿនចិត្តយើងចេះជ្រើសរើសនូវអ្វី ដែលល្អជាង មានប្រយោជន៍ជាងគេ សក់ល្អជាងចៃ ទឹកល្អជាងខ្យល់ ផ្ទះល្អជាងល្អាង ថ្ងៃល្អជាងខែ។

នៅក្នុងការជ្រើសរើសនេះ កូនប្រាកដជាបានជួបនៅថ្ងៃណាមួយ ដោយសារ កូនត្រូវតែសម្រេចចិត្តជ្រើសរើសអ្វីមួយ ហើយការសម្រេចចិត្តនោះ ពីជាការពិបាកចិត្តម្យ៉ាង។ ការដែលសម្រេចចិត្តជ្រើសរើសឲ្យត្រឹមត្រូវមិនឲ្យខុសឆ្គងនោះ ជារឿងនៃភាពឆ្លាតវៃ និងបទពិសោធ ដោយមនុស្សដែលឆ្លាតនោះ មុនពេលដែលជ្រើសរើស គេពិចារណា និងថ្លឹងថ្លែងជាមុនសិនថា របស់ណាដែលមានប្រយោជន៍ ហើយរបស់ណាដែលគ្មានប្រយោជន៍ ឬរបស់ណាល្អ របស់ណាក្រក់ជាង ព្រមទាំងចេះសម្របចិត្តថាអ្វីគួរ ឬអ្វីមិនគួរ គេហ្មត់ចត់មិនប្រញាប់ពេក គិតមុខក្រោយមុនពេលជ្រើសរើស មុនពេលដែលសម្រេចចិត្តជានិច្ច។

www.elibraryofcambodia.org

ពេលដែលមិត្តភក្តិមានការថ្លោះធ្លោយ ឬក៏បរាជ័យចំពោះរឿងអ្វីមួយ ត្រូវតែអាណិតចិត្តគេ ឲ្យកម្លាំងចិត្ត និងមិនបោះបង់ចោលគេនោះទេ ហើយបើសិនជាជួយមិនបាននៅស្ងៀមទៅ មិនគួរជាន់បន្ថែមទេ ដោយមិត្តភក្តិដែលចោលគ្នា ជាន់ពន្លិចគ្នា ឬរាប់អានគ្នាដើម្បីផលប្រយោជន៍នោះ មិនមែនជាជាមិត្តស្មោះត្រង់នោះទេ អាចធ្វើបានត្រឹមតែអ្នកស្គាល់គ្នា រាប់អានគ្នាតែប៉ុណ្ណោះ ហើយកុំថាជាមិត្តស្មោះត្រង់អី ទោះបីជាមិត្តធម្មតាក៏ពិបាកធ្វើផងដែរ។

ពេលដែលត្រូវការមិត្តភក្តិស្មោះត្រង់ គឺត្រូវបង្ហាញពីភាពស្មោះត្រង់ដល់មិត្តភក្តិជាមុនសិន ហើយបើសិនខ្លួនឯងធ្វើជាមិត្តភក្តិស្មោះត្រង់របស់មិត្តមិនបានផងនោះ តើមានអ្នកណាគេព្រមធ្វើជាមិត្តភក្តិស្មោះត្រង់របស់យើងនោះ។

www.elibraryofcambodia.org

# ១០៥.មិត្តស្មោះត្រង់

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សយើងគ្រប់គ្នាត្រូវតែមានមិត្តភ័ក្តិ មិនអាចរស់នៅម្នាក់ឯងបាននោះទេ សូម្បីតែកូនក៏កេនត្រូវមានមិត្តភ័ក្តផងដែរ ហើយពាក្យថា **មិត្តភ័ក្តិ** នេះមានន័យថាជ្រៅជ្រះណាស់ ព្រមទាំងរឹតតែជ្រៅជាងនេះទៅទៀតនោះ បើសិនឈានទៅដល់មិត្តស្និទ្ធស្នាល ដោយនោះវាអាចធ្វើឲមានអារម្មណ៍ស្និទ្ធស្នាលហួសពីបងប្អូនទៅទៀត ពីព្រោះអាចស្លាប់ជំនួសគ្នាបាន ប៉ុន្តែមិត្តភ័ក្តិដែលប្រសើរជាងគេនោះ គឺមិត្តភ័ក្តិស្មោះត្រង់ មិត្តស្មោះត្រង់នោះ គឺជាមិត្តដែលរួមសុខទុក្ខជាមួយនឹងគ្នា និងជាមិត្តដែលមិនបោះបង់ចោលគ្នា ដោយនៅពេលដែលកេនទុក្ខ ឬពេលដែលធ្លាក់ខ្លួន និងទៅរកគ្នាទៅវិញទៅមកដូចតែពីពេលមុនៗ ឬក៏ញឹកញាប់ជាងមុនទៅទៀតក៏ជាបាន។

ដូច្នេះ បើសិនជាចង់រាប់អានមិត្តស្មោះត្រង់នោះ ត្រូវតែមើលឲបានច្បាស់សិនថា គេជាមិត្តប្រភេទណា តើអាចធ្វើមិត្តស្មោះត្រង់បានដែរឬទេ ហើយនៅក្នុងពេលតែមួយ យើងក៏ត្រូវតែធ្វើខ្លួនជាមិត្តស្មោះត្រង់របស់មិត្តភ័ក្តិរបស់យើងដែរ ដោយចេះផ្តល់ភាពសំខាន់នៅក្នុងចំណងមិត្តភាព ផ្តល់កិត្តិយសជួយត្រេកអរពេលដែលមិត្តភ័ក្តិបានល្អ។

www.elibraryofcambodia.org

ដោយត្រូវលុយការផ្ដុំធ្វើដោយមិនដឹងខ្លួននោះទេ។ មនុស្សយើងពេលដែលអត់លុយ បានពេលវេលាសម្រាកស្រួលពេញមួយយប់ ហើយពេលដែលបានលុយ បែរជាគ្មានពេលសម្រាក ដោយបានសម្រាកក៏បានតិចដែរ ឬសូម្បីតែរកពេលញ៉ាំបានឆ្ងាញ់នោះក៏ពិបាកផងដែរ ចំណែកអ្នកខ្លះទៀតមនុស្សយើងកាលដែលមានលុយតិច មានពេលនៅជាមួយគ្រួសារ ប៉ុន្តែពេលដែលមានលុយច្រើន បែរជាគ្មានពេលនៅជាមួយក្រុមគ្រួសារទៅវិញ ធ្វើឲ្យគ្រួសារខ្វះភាពកក់ក្ដៅ។

នេះហើយកូនសម្លាញ់អើយ! លុយវាប្រើយើង ពីព្រោះតែយើងល្ងង់វង្វេងជាមួយនឹងវា ដោយអ្នកខ្លះពេលដែលមានលុយហើយរកគំនិត គិតរឿងចំការបញ្ជាឲ្យសម្លាប់មនុស្សក៏មាន ចិញ្ចឹមអ្នកលេងក៏មានដែរ លុយច្រើនធ្វើទាំងអស់ ដោយបើសិនជាគ្មានលុយ គេក៏មិនអាចធ្វើបែបនេះបានទេ ឬក៏ធ្វើមិនកើតទៀតផង ដូច្នេះ កូនកុំឲ្យលុយធ្វើជាចៅហ្វាយលើយើងយើងត្រូវធ្វើជាចៅហ្វាយលើលុយ យើងធ្វើជាអ្នកប្រើលុយ ហើយប្រើនៅក្នុងផ្លូវដែលត្រឹមត្រូវ ទើបមិនពិបាកនៅពេលក្រោយ។

www.elibraryofcambodia.org

# ១០៦.ចូរប្រើលុយ កុំឲលុយប្រើយើងវិញ

កូនសម្លាញ់របស់ពុកម៉ែអើយ !

នៅសម័យនេះអ្នកណាៗក៏ចាត់ទុកលុយជាព្រះជាម្ចាស់ដែរ ពីព្រោះតែយល់ថាលុយអាចទិញ អាចធ្វើអ្វីៗគ្រប់យ៉ាងដែលយើងត្រូវការបាន ឬទិញសូម្បីតែចិត្តមនុស្សយើងផងដែរ ហើយទើបសព្វថ្ងៃនេះ មនុស្សយើងព្យាយាមរកលុយតាមគ្រប់វិធីសាស្ត្រ ទោះបីជាត្រូវធ្វើខុសធ្វើររាក្រក់ និងសាងបាបកម្មឲអ្នកផ្សេងគេពិបាកយ៉ាងណាក៏ដោយ ក៏ព្រមធ្វើដើម្បីឲបានលុយមកដែរ ទើបពិភពលោកក្តៅស្ទើរក្លាយជាភ្លើងទៅហើយ។

លុយជារបស់សំខាន់ពិតមែនកូន ប៉ុន្តែកុំផ្តល់ភាពសំខាន់ចំពោះលុយរហូតដល់ថ្នាក់ភ្លេចអំពើល្អ ភ្លេចគុណធម៌ ឬក៏ភ្លេចភាពត្រឹមត្រូវឲសោះ ហើយបើសិនជាយើងផ្តល់ភាពសំខាន់ចំពោះលុយពេកនោះ លុយពិតមកធ្វើជាចៅហ្វាយរបស់យើងជាមិនខាន ដោយបើសិនណាជាលុយមកធ្វើជាចៅហ្វាយហើយនោះ លុយនឹងបង្ខំឲយើងធ្វើនេះ ធ្វើនោះជាមិនខាន។

កូនមើលខ្លួនឯងក៏បានដែរ ពេលដែលគ្មានលុយ កូនគ្មានចង់បានអ្វីច្រើននោះទេ ដោយចង់បាន ចង់ទិញ ចង់ញ៉ាំ របស់អ្វីណាដែលចាំបាច់តែប៉ុណ្ណោះ ប៉ុន្តែពេលដែលមានលុយ គឺចង់ញ៉ាំ ចង់ប្រើរបស់ល្អៗ ថ្លៃៗ

www.elibraryofcambodia.org

ប្រៀបដូចតាមចិត្តហាត់ត្រូវទ្រាំពិបាកដើម្បីទៅរកវិជ្ជាបេមកបំពេញ ពីព្រោះគាត់ទាមទារចង់ញ៉ាំតែរបស់ឆ្ងាញ់ៗ ល្អៗ និងតាមចិត្តភ្នែក ត្រចៀក ក៏ត្រូវស្ទុះស្ទាទៅមើល ទៅស្តាប់ ឬទៅរករបស់ណាដែលភ្នែកចង់មើល។

ហេតុអ្វីបានជាយើងមកធ្វើជាទាសករអារម្មណ៍ចិត្ត ភ្នែក និងត្រចៀកជ្រុលពេកនោះកូនអើយ ដោយបើសិនជាយើងពិបាកចិត្ត ក៏ព្រោះតាមចិត្តរបស់ខ្លួនឯងនោះ ហេតុអ្វីយើងមិនកាត់បង្ខំចិត្តខ្លួនឯងពេកមើល សាកកាត់ធ្វើជាចៅហ្វាយរបស់ចិត្តម្តងមើល មិនចង់ទៅក៏ដោយ មិនចង់ទៅស្តាប់ម្តងមើល តើវានឹងយ៉ាងម៉េច? ជំនះបានញឹកញាប់ទៅក៏ក្លាយជាទម្លាប់ហើយកូន។

www.elibraryofcambodia.org

# ១០៧.តាមចិត្តរបស់ខ្លួនឯង

កូនសម្លាញ់របស់ពុកម៉ែអើយ !

ភាពទុក្ខលំបាករបស់មនុស្សយើងនោះ មានមកពីមូលហេតុផ្សេងៗ ប៉ុន្តែដោយធ្លាប់ឃើញជាញឹកញាប់នោះ គឺកើតចេញពីការប្រព្រឹត្តិរបស់ខ្លួនឯងផ្ទាល់ កាន់តែធ្វើតាមចិត្តខ្លួនឯងប៉ុណ្ណា ក៏កាន់តែកើតទុក្ខប៉ុណ្ណោះដែរ ដោយបើតាមចិត្តខ្លួនឯងម្ដង ក៏កើតមានទុក្ខម្ដង តាមចិត្តរបស់ខ្លួនឯង៥ដង ក៏កើតមានទុក្ខ៥ដង ហើយអ្នកដែលចូលចិត្តធ្វើតាមចិត្តខ្លួនឯង តែងតែជួបទុក្ខ អស់សង្ឃឹម ក្ដៅក្រហាយ និងមានការសង្ស័យគ្រប់ពេលវេលា ដោយបើសិនជាគេចង់ធ្វើអ្វីនោះ គេត្រូវខំប្រឹងស្វះស្វាករកមក ពេលដែលរកមកបានហើយ គេត្រូវរក្សាទុកឲ្យល្អ មិនឲ្យបាត់ចេញទៅណាទេ ហើយពេលដែលរបស់នោះបាត់ចេញទៅក៏កើតមានទុក្ខខាងផ្លូវចិត្ត ចិត្តក៏នៅមិនសុខ អារម្មណ៍មិនជាប់នឹងខ្លួន ទើបមិនមែនជាខ្លួនរបស់ខ្លួនឯង ផ្ញើរបស់នៅនឹងរបស់អ្នកដែលត្រូវការជានិច្ច។

តាមការពិតទៅ មនុស្សយើងមិនគួរនៅក្រោមអំណាចចិត្តខ្លាំងពេកនោះទេ ពីព្រោះចិត្តមនុស្សយើងមិនចេះពេញទេ ថែមយ៉ាងណាក៏មិនពេញនោះដែរ ហើយបើសិនជាតាមចិត្តរបស់ខ្លួនឯងនោះ ត្រូវកើតមានទុក្ខរហូត

www.elibraryofcambodia.org

ស្តាយ ឬក៏ប្រកាន់ភ្ជាប់ជាមួយនោះ វាពិបាកដាក់ចុះណាស់ ដាក់មិនបាន ទើបវាធ្វើឲ្យយើងពិបាកចិត្តនៅមិនបានសុខ។

បើសិនជាមានសម្ដាយ ឬស្ដាយសម្ដាយអ្វីនោះ ប៉ុន្តែមិនប្រកាន់ភ្ជាប់ពេកនោះ ពេលណាដែលគួរដាក់ក៏ដាក់ចុះខ្លះទៅ ពេលណាគួរទុកក៏គួរទុកខ្លះទៅ ពេលណាគួរស្ដាយទៅក៏ស្ដាយទៅ បើសិនធ្វើបានបែបនេះ យើងប្រាកដជាសប្បាយចិត្តបាន ហើយមានអារម្មណ៍ថាធូរស្រាល និងអាចមានសេចក្ដីសុខបានខ្លះដែរ ប្រសើរជាងទៅតែពុះ ឬប្រកាន់ភ្ជាប់ជាមួយគ្រប់ពេលវេលា។

www.elibraryofcambodia.org

# ១០៨.ភាពប្រកាន់ភ្ជាប់

កូនសម្លាញ់របស់ពុកម៉ែអើយ !

ជីវិតរបស់យើងម្នាក់ៗតែងតែជួបប្រទះផលពិបាកយ៉ាងច្រើន ហើយនៅក្នុងចំនួនផលវិបាកទាំងអស់នោះ មានផលពិបាក ក៏ព្រោះតែមានការប្រកាន់ភ្ជាប់របស់នៅជាមួយយើងដែរ ដោយការប្រកាន់ភ្ជាប់ដែលថានេះគឺការដែលមនុស្សយើងទៅប្រកាន់ភ្ជាប់នៅរបស់អ្វីមួយជ្រុលពេក ដូចជាការប្រកាន់នូវមនុស្ស នូវរបស់ នូវតួនាទីការងារ នូវអារម្មណ៍ និងរហូតដល់គំនិតខ្លួនឯងជ្រុលពេក ប្រកាន់ថា អ្នកនេះជាកូនរបស់យើង អ្នកនោះជាភរិយារបស់យើង ឬរបស់នោះជាទ្រព្យសម្បត្តិរបស់យើងជាដើម។

ការប្រកាន់ភ្ជាប់បែបនេះហើយ ដែលនាំមកនូវផលវិបាកដល់មនុស្សយើង ដោយការប្រកាន់ភ្ជាប់ជាមួយអ្វីហើយនឹងកើតទុក្ខព្រោះតែរបស់នោះ ហើយបើសិនជាមិនប្រកាន់ភ្ជាប់ជាមួយអ្វីទេ ក៏គ្មានទុក្ខអ្វីដែរ។ បើសិនជាកូនចង់ឲជីវិតបានសុខស្រួលពិតមែននោះ កូនត្រូវតែព្យាយាមលះបង់អ្វីខ្លះចោលទៅ កុំទៅស្ដាយសម្ដាយអ្វីច្រើនពេក វាធ្ងន់ហើយ ពិបាកទៀត ដោយធម្មតាសំពាយដែលស្ពាយលើស្មានោះយូរៗទៅ ក៏កាន់តែធ្ងន់ទៅៗ ពេលដែលបានដាក់ចុះក៏ស្រាលហាក់នឿយហើយ ចំណែកសម្ពាយដែលចិត្ត

www.elibraryofcambodia.org

ចំណេះដឹងក៏ល្អ យសស័ក្តិក៏ល្អ មាសប្រាក់ក៏សម្បូរ មិនមែនសុទ្ធតែអាចជួយឲ្យមនុស្សយើងអាចរួចផុតទោសបានរាល់ពេលនោះឡើយ ដោយពេលខ្លះរបស់ទាំងនោះ មិនអាចជួយអ្វីដល់យើងបាននោះទេ មានតែចិត្តមេត្រីភាពជាមិត្តភក្តិតែប៉ុណ្ណោះដែលអាចជួយយើងបានគ្រប់ករណី យ៉ាងហោចណាស់ក៏ពីធ្ងន់ទៅជាស្រាលដែរ។

មនុស្សយើងមិនគួរទៅបង្កការស្អប់ខ្ពើម ឲកើតមានឡើងចំពោះអ្នកនៅជុំវិញខ្លួន ដោយការមើលស្រាលដល់គេ ឬជិះជាន់ដល់គេនោះទេ កូនគួរតែរាប់អានមិត្តច្រើនជាងបង្កើតសត្រូវ ហើយពាក្យនេះ ចាស់បុរាណគាត់បានប្រៀនប្រដៅជាយូរណាស់មកហើយកូនសម្លាញ់អើយ! ។

www.elibraryofcambodia.org

# ១០៩.ការវាយឫក និងការប្រកាន់ខ្លួន

កូនសម្លាញ់របស់ពុកម៉ែអើយ !

ការវាយឫក ឬការប្រកាន់ខ្លួននោះ ក៏ធ្លាប់បានប្រាប់ដល់កូនរួចខ្លះមកហើយ ប៉ុន្តែសូមនិយាយម្តងទៀត គឺកូនត្រូវមានប្រយ័ត្នកុំធ្វើជាមនុស្សវាយឫក ប្រកាន់ខ្លួន ហើយកុំទៅមើលស្រាលអ្នកដទៃ ជាពិសេសមិត្តរួមការងារ ឬអ្នកដែលទាក់ទងជាមួយ ព្រមទាំងអ្នកជិតខាងរបស់យើងដែរ ពីព្រោះការវាយឫក និងការប្រកាន់ខ្លួននោះ សូម្បីតែខ្លួនយើងក៏មិនចូលចិត្តផងដែរ។

ឫកពាដែលចាត់ទុកថាជាការវាយឫក ការប្រកាន់ខ្លួននោះ គឺការចូលចិត្តធ្វើខ្លួនទៅតំរាមអ្នកដទៃ ចូលចិត្តគិតថា ខ្លួនឯងល្អជាងគេ ហើយចូលចិត្តធ្វើខ្លួននៅពីលើក្បាលគេ មើលស្រាលគេ ឬបង្ហាញឫកពាស្អប់ខ្ពើមអ្នកដែលអន់ជាងជាដើម ដោយអ្នកដែលបញ្ចេញឫកពាបែបនេះចេញមកនោះ អ្នកនៅជុំវិញខ្លួនប្រាកដជាស្អប់ខ្ពើម មិនចូលចិត្តទៅជិត ឬមិនចង់រាប់អានជាមួយនោះទេ។ មនុស្សវាយឫកប្រកាន់ខ្លួនបែបនេះ តែងតែនៅឯកា និងតស៊ូនៅម្នាក់ឯងពេលដែលមានរឿងអ្វីកើតមានឡើង។

www.elibraryofcambodia.org

សតិនោះ ក៏ធ្វើអ្វីឆេវឆាវណាស់ ដោយមិនទាន់បានគិតផងក៏មានការហោះ និតខំទៅមុខ ពេលដែលមានការផ្លោះផ្លោយ ឬមានការខាតបង់នោះ តែង តែស្ដាយក្រោយថា បើដឹងបែបនេះ មិនធ្វើប្រសើរជាង។

បើសិនមានសតិនោះ គ្រប់យ៉ាងនឹងមិនកើតការលំបាកនាំឲ្យខូចខាត នោះឡើយ នឹងអាចសម្រេចបានទៅយ៉ាងល្អ ដូច្នេះហើយ ទើបជាមាន ពាក្យពោលថា សតិ និងប្រាជ្ញា ជារបស់ដែលមានគុណណាស់នៅក្នុងការ ធ្វើការគ្រប់យ៉ាង ហើយទាំងពីរយ៉ាងនេះក៏ត្រូវដើរទន្ទឹមគ្នាផងដែរ បើសិន មានសតិ ប៉ុន្តែខ្វះប្រាជ្ញា ឬមានប្រាជ្ញា ប៉ុន្តែខ្វះសតិវិញនោះ ក៏ពិបាកនឹងល្អ បានផងដែរ។

www.elibraryofcambodia.org

# ១១០.មានសតិធ្វើឲកើតប្រាជ្ញា

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលណាដែលយើងមិនចង់ឲកើតមានភាពភ្លោះភ្លាយ និងមិនចង់ឲមានការបាត់បង់នូវរឿងដែលខ្លួនបានធ្វើ ឬនិយាយនោះ ត្រូវតែមានការគិតមុនធ្វើ និងគិតមុននិយាយជានិច្ច ដោយការគិតមុននិយាយ ពីដើម្បីការពារភាពភ្លោះភ្លាយ នោះជាអត្ថន័យរបស់ពាក្យថា **សតិ**។

**សតិ**មានន័យថា ការគិតពិចារណា ការនឹកឃើញដោយមិនភ្លេច ហើយសតិនេះជាការចាំបាច់ណាស់នៅក្នុងការរស់នៅ មនុស្សយើងត្រូវតែមានសតិជានិច្ច ដោយមនុស្សដែលគ្មានសតិតែងតែធ្វើអ្វី និយាយអ្វីខុសជានិច្ច ភ្លេចនេះ ភ្លេចនោះ។ បើសិនជាអត់សតិនឹងធ្វើឲយើងខាតបង់ពេលវេលានៅក្នុងការកែលម្អថ្មី ឬក៏ដោះស្រាយនៅពេលក្រោយធ្វើឲស្មុគស្មាញជាងមុន ហើយការមានសតិប្រៀបបាននឹងមានឧបករណ៍សម្រាប់ការពារភាពភ្លោះភ្លាយ ឬការពារការខាតបង់។

សតិនោះត្រូវទៅនាំយកបញ្ញាមក គឺចំណេះដឹង សមត្ថភាព ហើយបញ្ញាត្រូវមានសតិរង់ចាំការពារមួយជាន់ទៀត ដោយសតិជាអ្នកនាំ បញ្ញាជាអ្នកតាម។ អ្នកដែលមានបញ្ញាឆ្លាតវៃដឹងគ្រប់បែបយ៉ាង ប៉ុន្តែបើសិនខ្វះ

www.elibraryofcambodia.org

ដូចជា ការឲ្យរបស់ញ៉ាំ របស់ប្រើប្រាស់ ឬការជូនរង្វាន់អ្វីមួយជាដើម ប៉ុន្តែ ការផ្ដល់កម្លាំងចិត្តដែលសំខាន់ និងល្អបំផុត គឺជាពាក្យសម្ដី ដោយការនិយាយស្ដីល្អ និយាយសរសើរនៅពេលដែលគេធ្វើល្អធ្វើត្រូវ ទុកជា ល្អណាស់ទៅហើយ ហើយបើសិនជាគេធ្លោះធ្លោយនោះ ត្រូវតែនិយាយផ្ដល់កម្លាំងចិត្តដល់គេជាថ្មី មិនស្ដីបន្ទោសគេទេ ប៉ុន្តែណែនាំវិធីធ្វើដែលត្រឹមត្រូវដល់គេ បែបនេះចាត់ទុកជា ជាការផ្ដល់កម្លាំងចិត្តផងដែរ និងរួមទាំងនៅពេលដែលគេមានការអស់សង្ឃឹម ត្រូវតែបង្ហាញពីក្ដីករុណាពិតប្រាកដ ធ្វើខ្លួនជាមិត្តរួមទុក្ខរបស់គេ។

កំហុសដោយសារការធ្វើឲ្យអ្នកដទៃបាត់បង់កម្លាំងចិត្ត គឺជាការដែលមិនអាចមានភាពច្នៃប្រឌិតឡើយ ដោយមានតែបង្កឲ្យមានសត្រូវច្រើនតែប៉ុណ្ណោះ ហើយការផ្ដល់កម្លាំងចិត្តដល់អ្នកដទៃ ទើបប្រសើរជាងធ្វើឲ្យអ្នកដទៃបាត់បង់កម្លាំងចិត្ត។

www.elibraryofcambodia.org

# ១១១.ការផ្តល់កម្លាំងចិត្តគ្នាទៅវិញទៅមក

កូនសម្លាញ់របស់ពុកម៉ែអើយ !

នៅក្នុងពេលដែលមនុស្សមានការអស់សង្ឃឹមនោះ កើតមាននូវភាពរួញរាចិត្ត ឬកំពុងប្រឈមមុខជាមួយនឹងហេតុការណ៍ដែលពិបាកចិត្តយ៉ាងខ្លាំងនោះ ដោយរបស់ដែលត្រូវការជាងគេពេលនោះ គឺជាកម្លាំងចិត្តពីអ្នកដទៃ ជាពិសេសអ្នកដែលស្និទ្ធស្នាលជាមួយ។

**កម្លាំងចិត្ត គឺជាថ្នាំប៉ូវពិសេស ជាថ្នាំប៉ូវជំរុញឲមនុស្សយើងមានកម្លាំងចិត្តតស៊ូនៅក្នុងជីវិតតទៅទៀត ធ្វើឲភាពរួញរាអស់សង្ឃឹមបាត់បង់ទៅអស់** ហើយយើងក៏ត្រូវការកម្លាំងចិត្តពីអ្នកដទៃ និងអ្នកដទៃក៏ត្រូវការកម្លាំងចិត្តពីយើងដូចគ្នាផងដែរ។

ដូច្នេះ មនុស្សយើងគួរតែផ្តល់កម្លាំងចិត្តឲគ្នាទៅវិញទៅមក មិនមែនចាំតែទទួលកម្លាំងចិត្តពីអ្នកដទៃនោះឡើយ ដោយការឲកម្លាំងចិត្តដល់អ្នកដទៃនោះ ជារឿងល្អ ជារឿងដែលគួរធ្វើណាស់ កូនគួរតែរៀនធ្វើជាទម្លាប់ទៅ ជាពិសេសចំពោះអ្នកនៅជិតខ្លួន ឬអ្នកដែលគេល្អចំពោះយើង ជួយដល់យើង ហើយមានទឹកចិត្តចំពោះយើង យើងត្រូវតែផ្តល់កម្លាំងចិត្តដល់គេជានិច្ចកុំឲខ្វះខាត ការផ្តល់កម្លាំងចិត្តចិត្តនោះធ្វើបានច្រើនណាស់

www.elibraryofcambodia.org

ដោយការទៅសេពគ្រឿងញៀន ដែលនឹងធ្វើឲគេទន់ខ្សោយទ្រុឌទ្រោម និងកុំនាំគេដើរលេងគិតពេលយប់រវី ដល់ភ្លេចគិតការសម្រាក នោះជាការធ្វើបាបដល់គេ ពីព្រោះតែការដែលធ្វើឲអវយវៈផ្សេងៗ ទន់ខ្សោយទ្រុឌទ្រោម ដោយមិនបានមើលថែ មិនបានសម្រាកឲបានគ្រប់គ្រាន់នោះ ជាការដែលគេហៅថា អកតញ្ញូចំពោះបេដ្ឋា អកតញ្ញូចំពោះខ្លួនឯង។

មនុស្សដែលអកតញ្ញូចំពោះខ្លួនឯងបែបនេះ នឹងមានអាយុខ្លី ហើយត្រូវរោគភ័យអាក់រៀករៀនធ្វើឲមានជំងឺរាក្ចូត គឺត្រូវតែធ្វើឲខ្លួនឯងពិបាកទាំងអស់។

www.elibraryofcambodia.org

# ១១២.ភាពកតញ្ញូចំពោះខ្លួនឯង

កូនសម្លាញ់របស់ពុកម៉ែអើយ !

កូនប្រហែលជាធ្លាប់បានឮពាក្យទូន្មានរបស់ព្រះពុទ្ធខ្លះហើយ ដោយទ្រង់បានអប់រំដល់មនុស្សយើង ឲចេះដឹងគុណអ្នកដទៃដូចជាកតញ្ញូចំពោះឪពុកម្ដាយ កតញ្ញូចំពោះគ្រូបាអាចារ្យ ហើយភាពកតញ្ញូនោះ មិនត្រឹមតែធ្វើចំពោះអ្នកដទៃនោះទេ យើងគួរតែធ្វើចំពោះខ្លួនឯងផងដែរ។

ពោលគឺ អវយវៈគ្រប់យ៉ាងនៅក្នុងរាងកាយរបស់មនុស្សយើងមិនថាជាដៃ ជើង ភ្នែក ត្រចៀក រួមទាំងបេះដូងនោះទេ សុទ្ធតែមានគុណរាចំពោះរាងកាយទាំងអស់ ដោយយើងប្រើការដល់គេ យើងអាស្រ័យលើគេទៅណាមកណា គេតែងតែជួយដល់យើងរហូតតាំងពីកើតមក ទើបយើងគួរតែមានភាពកតញ្ញូចំពោះអវយវៈផង។ ភាពកតញ្ញូចំពោះអវយវៈនោះ យើងអាចធ្វើបានដោយមិនប្រើគេឲលើសពីកម្លាំង ឲគេសម្រាកបានខ្លះ មើលថែទាំយកចិត្តទុកដាក់ចំពោះគេឲបានល្អ ប៉ូវដល់គេឲឆាប់ធំ ហើយរឹងមាំ និងបើសិនជាគេខុសពីធម្មតា គេឈឺថ្កាត់នោះ ឆាប់ព្យាបាលគេទៅ កុំឲគេនៅម្នាក់រងទុក្ខវេទនា ដោយការយកចិត្តទុកដាក់ដល់គេ ទើបគេនឹងបានមើលថែយើងបានយូរ មិនពិការ មិនទំរន់ទុរា ជាពិសេសនោះ កុំបំផ្លាញគេ

www.elibraryofcambodia.org

យើងត្រូវមកទទួលទោសនោះ ឬក៏អ្នកផ្សេងគេមកពិបាកជាមួយដែរនោះ ពិតជាមិនសមគួរនោះទេ។

ការតបស្នងបុណ្យគុណដល់គ្នានោះដែរ មិនមែនធ្វើបានតែម្តងពីរម្តង ឬមួយថ្ងៃពីរថ្ងៃ ឬធ្វើបានមួយលើកពីរលើកប៉ុណ្ណោះទេ ដោយពេលវេលានៅតែមាន ឡើងដដែល យើងអាចតបគុណដល់គេបានច្រើនយ៉ាង ច្រើនវិធី ឲ្យតែការតបគុណនោះ មិនខុសគន្លងធម៌ទៅបានហើយ។

www.elibraryofcambodia.org

# ១១៣.ការតបស្នងសងគុណ

កូនសម្លាញ់របស់ពុកម៉ែអើយ !

ការតបស្នងសងគុណចំពោះអ្នកដែលមានគុណនោះ គឺជារឿងដែលគួរធ្វើ ជាអំពើល្អ មានមនុស្សគេគោរពកោតសរសើរ ហើយការសងគុណនោះ គឺត្រូវធ្វើត្រឹមត្រូវទៅតាមគន្លងធម៌ និងមិននាំទុក្ខ មិនចងពៀរដល់អ្នកដទៃ និងខ្លួនឯងនោះឡើយ។

ពេលដូចជា ចង់សងគុណដល់ឪពុកម្តាយ ប៉ុន្តែបែរជាទៅប្លន់ ឬបោកប្រាស់គេ ដើម្បីយកលុយ និងយករបស់មកឲឪពុកម្តាយ ដោយបែរអាងថា ធ្វើដើម្បីជាការសងគុណដល់ឪពុកម្តាយ ឬព្រមធ្វើខុសធ្វើអាក្រក់ដើម្បីសងគុណ បែបនេះហៅថា ជាការសងគុណដោយមិនត្រូវតាមគន្លងធម៌ មិនគួរគោរពសរសើរ និងមិនគួរធ្វើនោះឡើយ។

ការដែលយើងចង់សងគុណដល់អ្នកណាយ៉ាងម៉េចនោះ ត្រូវមានការពិចារណាឲបានច្បាស់លាស់ជាមុនសិន បើសិនសងគុណនូវផ្លូវត្រឹមត្រូវក៏មានគុណ សងគុណនូវផ្លូវមិនត្រឹមត្រូវក៏មានទោស នៅស្ងៀមៗមិនសងគុណអ្វីសោះប្រសើរជាង ទោះបីជាមិនបានល្អក៏មិនខាតដើមដែរ ដោយរកផ្លូវសងគុណដល់គេដែលមិនខុសទៅ ប្រសើរជាសងគុណគេបែបបានតែ

www.elibraryofcambodia.org

បើសិនយើងគិតបានច្បាស់លាស់បែបនេះហើយ ឬបានឃើញពីការពិតនៅពេលដែលបានជួបនឹងការពិតដោយខ្លួនឯងហើយ ក៏អាចកាត់ចិត្តបាន និងនៅពេលដែលកាត់ចិត្តបាន រឿងធំក៏ក្លាយជារឿងតូច រឿងតូចក៏ក្លាយជារឿងធម្មតា ហើយយើងក៏សប្បាយចិត្ត ពីព្រោះអាចដោះស្រាយបញ្ហាបានដោយគំនិត និងសតិបញ្ញារបស់ខ្លួនឯង។

កូនសម្លាញ់អើយ! សេចក្តីទុក្ខ គឺវាកើតមានឡើងនៅក្នុងចិត្ត ហើយបើសិនជាចិត្តព្រមទទួល ឬប្រកាន់ភ្ជាប់ជាមួយវានោះ ទុក្ខនឹងអាស្រ័យក្នុងចិត្តបានយ៉ាងស្រួល ឬចិត្តរបស់យើងប្រែជាមានទុក្ខ ពីព្រោះទៅរែកពុនទុក្ខជាច្រើន ដោយបើសិនជាយើងមិនព្រមទទួល មិនខ្វល់ និងមិនរែកពុនទុក្ខនោះ តើចិត្តរបស់យើងមានទុក្ខយ៉ាងម៉េចទៅ? ។

www.elibraryofcambodia.org

## ១១៤.បើសិនជាកាត់ចិត្តបាន មិនក្តៅក្រហាយនោះទេ

កូនសម្លាញ់របស់ពុកម៉ែអើយ !

ពេលណាដែលយើងកើតមានទុក្ខ កើតមានការមិនសប្បាយចិត្ត ឬមានបញ្ហាជីវិតកើតមានឡើង ដោយវិធីដោះស្រាយដែលល្អបំផុតត្រូវធ្វើឲបានលំដាប់ទីមួយនោះគឺ **ធ្វើចិត្ត** យើងត្រូវកាត់ចិត្តជាមុនសិន ចាំទៅគិតដោះស្រាយបញ្ហាផ្សេងៗនៅពេលក្រោយ រឿងខ្លះគ្រាន់តែកាត់ចិត្តបានតែប៉ុណ្ណោះ គ្រប់យ៉ាងក៏ចប់ទាំងអស់ បើសិនយើងកាត់ចិត្តមិនបានទេនោះពិបាកនឹងមកគិតដោះស្រាយបញ្ហាណាស់ ឬអាចស្មុគស្មាញជាងមុនក៏ថាបានដែរ ដោយវិធីធ្វើចិត្ត គឺជាការតាំងសតិឲល្អ បន្ទូរអារម្មណ៍ឲស្រួលពិចារណាមើលសិន គិតមើលរឿងរ៉ាវដែលកើតមានឡើងឲបានច្បាស់ រកមូលហេតុពិតប្រាកដឲបានឃើញ។ ការដែលមើលឃើញការពិតថា រឿងឬបញ្ហាដែលកើតមានឡើងនោះ វាកើតឡើងចំពោះយើង មានចំពោះតែយើងម្នាក់ ឬក៏កើតមានឡើងចំពោះអ្នកផ្សេងនោះ សូមឲកូនគិតដល់ថាមានអ្នកផ្សេងគេមានបញ្ហា មានរឿងដូចជាយើងដែរ និងធ្ងន់ធ្ងរជាងយើងទៅទៀត ដោយរឿងបែបនេះជារឿងធម្មតារបស់គ្រប់ជីវិតទៅហើយ។

www.elibraryofcambodia.org

រាជ័យពាក់កណ្ដាលទី ព្យាយាមកែសម្រួលកំហុសខុសឆ្គងទាំងអស់ ឬកែប្រែការងារ និងប្ដូរវិធីធ្វើការថ្មីទាំងអស់ ក៏អាចជួបភាពជោគជ័យនៅទីបំផុតបានផងដែរ។

ដរាបណានៅតែក្រោកឈរបន្តតស៊ូបាន ដរាបនោះ ក៏នៅតែមានឈ្មោះថា មិនទាន់បរាជ័យនោះទេ ដោយព្រះពុទ្ធទ្រង់បានសម្ដែងថា **កើតមកជាមនុស្សត្រូវព្យាយាមឲសម្រេចឲទាល់តែបានប្រយោជន៍** ទោះបីជារបស់ដែលព្យាយាមនោះ អាចមានលទ្ធផលបានសម្រេចតិចតួច ប៉ុន្តែក៏មានឈ្មោះថា បានប្រើការព្យាយាមហើយ ដោយអ្នកដទៃមកមើលងាយមើលស្រាលដល់យើងមិនបាននោះទេថា ជាមនុស្សបរាជ័យ ជាអ្នកចាញ់ និងជាអ្នកព្រមចុះចាញ់នៅក្នុងជីវិតនោះ ដូច្នេះ បើសិនកូនមិនត្រូវការបរាជ័យ ក៏មិនត្រូវធ្វើការបញ្ឈប់ដែរ ហើយបើសិនមិនទាន់បញ្ឈប់នោះ ក៏មិនទាន់បរាជ័យផងដែរ។

www.elibraryofcambodia.org

# ១១៥.ការបរាជ័យដែលពិតប្រាកដ

កូនសម្លាញ់របស់ពុកម៉ែអើយ !

មនុស្សយើងគ្រប់គ្នា គឺសុទ្ធតែខ្លាចការបរាជ័យទាំងអស់ ដោយជាពិសេសនោះនៅក្នុងក្រោមរុក្ខវិនិយោគទុន និងក្នុងគ្រួសារ ហើយតាមការពិតទៅគ្រប់គ្នាប្រហែលជាធ្លាប់បានឆ្លងកាត់ការបរាជ័យខ្លះមកហើយ មិនតិចក៏ច្រើនផងដែរ ដោយអ្នកខ្លះស្គាល់រសជាតិរបស់ការបរាជ័យច្បាស់ ក៏អាចឆ្លងកាត់មកបានយ៉ាងល្អ ពីព្រោះមិនរាថយ មិនព្រមចុះចាញ់ចំពោះការបរាជ័យ ហើយតស៊ូយកឈ្នះឲ្យទាល់តែបាន ប៉ុន្តែការបរាជ័យដែលកន្លងមកនេះ មិនមែនជាការបរាជ័យដ៏ពិតប្រាកដនោះទេ ពីព្រោះវានៅពេនភាពជោគជ័យខ្លះដែរ។

**ភាពបរាជ័យដ៏ពិតប្រាកដ គឺជាការបញ្ឈប់** ដោយការបញ្ឈប់ គឺជាការបរាជ័យយ៉ាងពិតប្រាកដរបស់មនុស្សយើង ពីព្រោះមិនអាចទៅដល់គោលដៅភាពជោគជ័យបាននោះទេ។ តាមការពិតមិនថា យើងធ្វើការអ្វីនោះទេ តែងតែមានឧបសគ្គទាំងអស់ មានខុសខ្លះ មានខាតដើមខ្លះ ខ្លះក៏មិនបានសមបំណង នោះក៏មិនបង្ហាញពីភាពបរាជ័យនោះដែរ ប៉ុន្តែជាយើងដាស់តឿនយើងថា យើងនៅមានកំហុសខុសឆ្គង ហើយបើសិនយើងមិនឈប់

www.elibraryofcambodia.org

វិធីបន្ធូរបន្ថយអារម្មណ៍ និងភាពស្មុគស្មាញដែលល្អបំផុតនោះ គឺជាការនិយាយឲ្យអ្នកដទៃស្តាប់ អ្នកដែលយើងគួរប្រាប់ឲ្យស្តាប់មុនគេនោះ គឺឪពុកម្តាយ យើងមានរឿងពិបាកចិត្តអ្វីក៏ប្រាប់ដល់ឪពុកម្តាយជាមុន ព្រោះឪពុកម្តាយគ្រប់គ្នាគ្មានគ្រោះភ័យអ្វីសម្រាប់កូននោះឡើយ ឪពុកម្តាយគ្រប់គ្នាតែងតែយល់ចិត្តដល់កូន និងអាណិតដល់កូនជានិច្ច ទោះបីជាពេលខ្លះដោះស្រាយឲ្យកូនមិនបាន ប៉ុន្តែក៏ជាទីកន្លែងជួយរំលែកក្តីទុក្ខកូននោះដែរ។

កូនប្រាប់ កូនយំ អាចបញ្ចេញអារម្មណ៍អ្វីចំពោះមុខឪពុកម្តាយបានទាំងអស់ ឪពុកម្តាយតែងតែព្រមស្តាប់ ព្រមទទួលដឹង និងអាណិតដល់កូនជានិច្ច ដោយកុំទុកឪពុកម្តាយជាអ្នកដទៃ ការស្អប់ សេចក្តីទុក្ខកង្វល់ទាំងពួងរបស់កូន កូនគួរតែលើកមកនិយាយឲ្យពុកម៉ែបានស្តាប់ កុំលាក់ទុកនៅក្នុងចិត្តតែម្នាក់ឯង ពុកម៉ែព្រមជួយដល់កូនជានិច្ច។

www.elibraryofcambodia.org

# ១១៦.មានការបន្ធូរបន្ថយខ្លះទៅនឹងសប្បាយចិត្ត

កូនសម្លាញ់របស់ពុកម៉ែអើយ !

ប្រាកដជាថ្ងៃណាមួយដែលមនុស្សយើងជួបទុក្ខ ឬក៏បញ្ហាដែលធ្វើឲមានការទាស់ទាល់នៅក្នុងចិត្ត ហើយចង់ប្រាប់ទៅដល់អ្នកណាក៏មិនបាន មនុស្សដឹងច្រើនក៏មិនបាន ឬទុក្ខព្រួយដែលខ្លួនឯងគិតថា អ្នកផ្សេងមិនអាចជួយបានទេ ទុក្ខព្រួយបែបនេះដែរនឹងធ្វើឲស្មុគស្មាញ គិតច្រើនរហូតដល់ប្តាក់ឈឺក្បាល ស៊ីមិនបាន ដេកមិនលក់ អាចមានជំងឺសរសៃប្រសាទបានយ៉ាងងាយផងដែរ។

បើសិនជាកូនជួបប្រទះនឹងបញ្ហាបែបនេះ កូនកុំមានការលាក់ទុកក្នុងចិត្តម្នាក់ឯងធ្វើអ្វី ត្រូវមានការបន្ធូរបន្ថយចេញមកខ្លះនឹងបានសប្បាយចិត្ត ប្រៀបបាននឹងមនុស្សពរពោះអញ្ជឹងកូន ពេលដែលបានបត់ជើងហើយក៏មានអារម្មណ៍ធូរស្រាលក្នុងខ្លួន។ ភាពស្មុគស្មាញ និងការបារម្ភនៅក្នុងរឿងផ្សេងៗ ដែលមាននៅក្នុងចិត្តក៏ដូចគ្នាដែរកូន ត្រូវមានការបន្ធូរបន្ថយចេញមក កុំទៅបន្ធូរបន្ថយដោយការទៅបំផ្លាញរបស់របរ ឬក៏ទៅជេរស្តីបន្ទោសអ្នកជិតខាងនោះ វាកាន់ថែមទុក្ខ និងថែមរឿងកាន់តែច្រើនទេកូនសម្លាញ់អើយ! ។

www.elibraryofcambodia.org

សៀវភៅមួយក្បាលនេះ គឺជាអ្នកដែលមានការយកចិត្តទុកដាក់ និងមានបំណងប្រាថ្នាចំពោះអ្វីដែលល្អបំផុត អាចជួយលោកអ្នកមានវិធីនៅក្នុងការបង្ហាត់បង្រៀនកូនឲមានជីវិតដែលល្អ និងជាមនុស្សដែលចេះតស៊ូនៅក្នុងឆាកជីវិត មិនព្រមចុះចាញ់ចំពោះបញ្ហា និងឧបសគ្គទាំងឡាយ។

សៀវភៅមួយក្បាលនេះ គឺត្រឹមតែចង់ឲលោកអ្នកអ្នកអានមានគំនិតបានកម្លាំងចិត្ត និងវិធីសាស្ត្រល្អៗ ពីពាក្យប្រៀនប្រដៅអប់រំដែលមិនអាចកាត់ថ្លៃបានរបស់ឪពុកម្តាយ ដែលនឹងអាចធ្វើអោយកូនរបស់លោកអ្នកមានជីវិតដែលល្អប្រសើរឡើងបានជារៀងរហូត។

)8200693 006036 08200693

www.elibraryofcambodia.org

សៀវភៅមួយក្បាលនេះ គឺជាអ្នកដែលមានការយកចិត្តទុកដាក់ និងមានបំណងប្រាថ្នាចំពោះអ្វីដែលល្អបំផុត អាចជួយឲលោកអ្នក មានវិធីនៅក្នុងការបង្ហាត់បង្រៀនកូនឲមានជីវិតដែលល្អ និងជាមនុស្សដែលចេះតស៊ូនៅក្នុងឆាកជីវិត មិនព្រមចុះចាញ់ចំពោះបញ្ហា និងឧបសគ្គទាំងឡាយ។

សៀវភៅមួយក្បាលនេះ គឺត្រឹមតែចង់ឲលោកអ្នកអ្នកអាន មានគំនិត មានកម្លាំងចិត្ត និងវិធីសាស្ត្រល្អៗ ពីពាក្យប្រៀនប្រដៅ អប់រំ ដែលមិនអាចកាត់ថ្លៃបានរបស់ឪពុកម្តាយ ដែលនឹងអាចធ្វើអោយកូនរបស់លោកអ្នកមានជីវិតដែលល្អប្រសើរឡើងបានជារៀងរហូត។



9 789924 507079

www.elibraryofcambodia.org
SB_18_12000